# ថ្ងៃទី០៣ ខែ មេសា ឆ្នាំ២០២៣

## សម្តេច ស ខេង ជំរុញឱ្យខេត្តព្រះសីហនុបង្កើនការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបង្ក្រាបល្បែងខុសច្បាប់

https://www.kampucheathmey.com/local-news/488361 ថ្ងៃសៅរ៍ ១ មេសា ២០២៣ដោយ deth leng

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានជំរុញឱ្យរដ្ឋបាលខេត្តព្រះសីហនុបង្កើនការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបង្ក្រាបល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទដើម្បីរក្សាសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពក្នុងសង្គមឱ្យបានល្អប្រសើរ។ ថ្លែងបិទសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់រដ្ឋបាលខេត្តព្រះសីហនុ កាលពីរសៀលថ្ងៃទី ៣១ ខែមីនា សម្តេចក្រឡាហោម ស ខេង បានមានប្រសាសន៍ថា រដ្ឋបាលខេត្តព្រះសីហនុ ត្រូវបង្កើនការថែរក្សាពង្រឹងសន្តិសុខជាតិ ដោយត្រូវសហការទប់ស្កាត់ និងបង្ក្រាបឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពនូវអំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ បទល្មើសបច្ចេកវិទ្យា និងបទល្មើសមិនប្រពៃណីនានា (Non-Traditional Crime) ដែលកំពុងមានការវិវត្តប្រែប្រួលកាន់តែស្មុគស្មាញ។

សម្តេចក្រឡាហោមបានបន្តថា ចំពោះអំពើជួញដូរមនុស្សត្រូវបានកំណត់យកខេត្តព្រះសីហនុ ជាគោលដៅនៃការស្រាវជ្រាវ លើពាក្យបណ្តឹងនានាដែលអះអាងថា មានការជួញដូរមនុស្ស ឬការកេងប្រវ័ញ្ចកម្លាំងពលកម្មដែលអាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចបានរកឃើញមុខសញ្ញាពាក់ព័ន្ធពាក្យបណ្តឹងទាំងនោះ ភាគច្រើននៅតាមទីតាំងល្បែងភ្នាល់អនឡាញខុសច្បាប់នានា។

សម្តេចក្រឡាហោម បានណែនាំបន្ថែមដល់អាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់នៃខេត្តព្រះសីហនុ ត្រូវបន្តអនុវត្តឱ្យកាន់តែសកម្មថែមទៀតនូវយុទ្ធនានា, បង្កើនការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់, ប្រតិបត្តិការបង្ក្រាបល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទទាំងល្បែងភ្នាល់តាមប្រព័ន្ធអនឡាញខុសច្បាប់ និងល្បែងស៊ីសងនៅតាមមូលដ្ឋាន ព្រមទាំងការចុះធ្វើអធិការកិច្ចហត្ថពលកម្មបរទេស ដោយត្រូវសហការអនុវត្តការងារទាំងនេះឱ្យប្រកបដោយតម្លាភាព គណនេយ្យភាព និងមានការទទួលខុសត្រូវខ្ពស់ សំដៅរក្សាសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និង សុវត្ថិភាពក្នុងសង្គមឱ្យបានល្អប្រសើរ, ពង្រឹងកិច្ចសហការគ្រប់គ្រងការចេញចូល និងសន្តិសុខតាមលំហសមុទ្រក្នុងភូមិសាស្ត្រខេត្តព្រះសីហនុ និងខិតខំជំរុញការអនុវតគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាពផងដែរ។

លោកគួច ចំរើន អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ បានមានប្រសាសន៍ថា គិតចាប់ពីថ្ងៃទី០១ ខែមករា រហូតដល់ ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២ កម្លាំងជំនាញបានធ្វើការស្រាវជ្រាវស្វែងរកជនបរទេស ដែលបានប្តឹងចូលប្រព័ន្ធមជ្ឈមណ្ឌលប្រចាំបញ្ជាអគ្គស្នងការដ្ឋាននគរបាលជាតិ (Hotline១១៧), ផេកហ្វេសប៊ុកផ្លូវការរបស់ ឯកឧត្តម គួច ចំរើន , Hotline របស់ស្នងការដ្ឋាននគរបាលខេត្ត, សំណើរបស់ស្ថានទូត ឬស្ថានកុងស៊ុល ស្នើសុំឱ្យជួយសង្គ្រោះបានសរុបចំនួន ១៣៥ករណី, ស្វែងរកឃើញតាមបណ្តឹងសរុបចំនួន ៦០៦នាក់ ស្រី ១០០នាក់ ស្មើ ១២សញ្ជាតិ។ ជាមួយគ្នានេះដែរបានបង្ក្រាបល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ បានចំនួន ២៩ករណី ឃាត់ខ្លួន ១៣៧នាក់ បានកសាងសំណុំរឿងបញ្ជូនជនសង្ស័យ ១៥នាក់ ទៅសាលាដំបូងខេត្ត ធ្វើកិច្ចសន្យាអប់រំចំនួន ១២២នាក់។

លោក អភិបាលខេត្ត បានប្តេជ្ញារួមគ្នាបន្តថែរក្សា ការពារឱ្យបាននូវសុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពក្នុងសង្គម ខិតខំរួមគ្នារៀបចំពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ ឆ្នាំថោះ ឱ្យ

ប្រព្រឹត្តិទៅដោយរលូន និងសប្បាយរីករាយ ចូលរួមរក្សាសុវត្ថិភាពឱ្យបានទាំងស្រុង ក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំការងារទេសចរណ៍លើកទី៥១ និងវេទិកាទេសចរណ៍មេគង្គឆ្នាំ២០២៣ ការរៀបចំព្រឹត្តិការណ៍កីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ដែលខេត្តព្រះសីហនុធ្វើជាម្ចាស់ផ្ទះ រៀបចំកីឡា ៣ប្រភេទរួមមាន កីឡាទូកក្តោង កីឡាម៉ូតូទឹក និងកីឡាបាល់ទះលើឆ្នេរខ្សាច់។ ជាពិសេសជានាឱ្យការបោះឆ្នោតជាតិលើកទី៧ នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ប្រព្រឹត្តទៅប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌៕សំអឿន

## អភិបាលរងខេត្តកំពង់ធំ អំពាវនាវឲ្យបងប្អូនប្រជាពលរដ្ឋទាំងអស់ ចូលរួមទប់ស្កាត់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

https://freshnewsasia.com/index.php/en/localnews/284519-2023-03-30-08-41-30.html 2023-03-30 03:41pm

**(កំពង់ធំ)៖** លោកស្រី លំ គន្ធារី អភិបាលរងខេត្តកំពង់ធំ បានអំពាវនាវឲ្យបងប្អូនប្រជាពលរដ្ឋទាំងអស់ចូលរួមក្នុងការទប់ស្កាត់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ លោកស្រី លំ គន្ធារី បានថ្លែងនេះ ក្នុងកិច្ចប្រជុំបូកសរុបត្រីមាសទី១ និងលើកទិសដៅការងារត្រីមាសទី២ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តកំពង់ធំថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ មានការចូលរួមពីប្រធានមន្ទីរអង្គភាព អាជ្ញាធរក្រុងស្រុក អង្គការដៃគូជាច្រើន។ លោកស្រីសូមគោរពថ្លែងអំណរគុណដល់អង្គការដៃគូ និងមន្ទីរ-អង្គភាព ដែលបានសហការជាមួយគណៈកម្មាធិការ និងលេខាធិការដ្ឋាន ព.ខ.ប.ជ ថ្នាក់ខេត្តក្នុងការជួយពង្រឹងការអនុវត្តវិធីសាស្ត្រគាំទ្រ និងការពារប្រកបដោយ ប្រសិទ្ធភាពខ្ពស់ និងធ្វើឲ្យប្រសើរឡើងវិញនូវការអង្កេត ការប៉ះទង្គិចផ្នែកផ្លូវចិត្ត របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សសំដៅ ការពារសុខុមាលភាព និងការកសាងទំនុកចិត្តរបស់ជនរងគ្រោះ ម្យ៉ាងវិញទៀតជួយសម្រួលដល់ ការសហការយ៉ាងប្រសើរជាមួយអ្នកអនុវត្តច្បាប់។

**លោកស្រីបន្តថា អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គឺជាបរិបទសកល ដែលនៅតែបន្តកើតមានអាស្រ័យកត្តាសំខាន់៣ រួមមាន៖** *ការអប់រំសង្គម ការអនុវត្តច្បាប់ និងការធក់ឱកាសពីជនល្មើស។ រូបភាពនៃអំពើជួញដូរមនុស្សមិនត្រឹមតែជាការជួញដូរ ឬកេងប្រវ័ញ្ចកម្លាំងពលកម្មនិងផ្លូវភេទប៉ុណ្ណោះទេ តែក្នុងឆ្នាំកន្លងទៅ ក៏មានលេចចេញនូវបាតុភាពមួយចំនួន ដែលមានទំនោរទៅរកអំពីជួញដូរសេរីរាង្គ និងបទល្មើសរត់ពន្ធ ឬជួញដូរទារកឆ្លងដែនដែលហៅថា អំពើជួលពពោះជំនួស។ លោកស្រីបន្តទៀតថា ការធ្វើទេសន្តរប្រវេសន៍គឺជាជម្រើសរបស់ប្រជាពលរដ្ឋ ដែលមិនអាចហាមឃាត់បានហើយក៏មិនមែនសុទ្ធតែជាហានិភ័យគួរចៀសវាងដែរ។ គោលនយោបាយរបស់រាជរដ្ឋាភិបាល គឺផ្តល់ឱកាសជូន ប្រជាពលរដ្ឋក្នុងការងារ បង្កើនប្រាក់ចំណូលទាំងនៅក្នុងស្រុក និងក្រៅស្រុកហើយពលករមួយចំនួនទទួលបានកម្រៃ និងលើកកម្ពស់ជីវភាពបានយ៉ាងល្អតាមការរំពឹងទុក ប៉ុន្តែអ្វីដែលជាការព្រួយបារម្ភនោះ គឺការធ្វើទេសន្តរប្រវេសន៍ដោយប្រថុយប្រថាន មិនមានការធានាផ្នែកច្បាប់ និងមិនមានការគ្រប់គ្រងច្បាស់លាស់ដែលនាំឱ្យប្រឈមនឹងហានិភ័យដោយអំពើកេងប្រវ័ញ្ច និងជួញដូរមនុស្ស។ ចុងក្រោយលោកស្រី លំ គន្ធារី ជំរុញទៅដល់ក្រុមការងារ ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់ត្រូវផ្សព្វផ្សាយបញ្ច្រាបពីល្បិចកលរបស់ក្រុមជួញដូរនិងវីដេអូរឿងអាភាសរឿងដល់បងប្អូនប្រជាពលរដ្ឋ៕

# តុលាការកំពូល តម្កល់ទោសប្ដីប្រពន្ធបង់ក្លាដេស-ខ្មែរមួយគូ ជាប់គុក ក្នុងម្នាក់ៗ ៧ ឆ្នាំ ពាក់ព័ន្ធការរត់ពន្ធមនុស្សឆ្លងដែនខុសច្បាប់

https://cen.com.kh/archives/641700.html Posted ByPen Srey NeatMarch 31, 2023

ភ្នំពេញ: តុលាការកំពូល កាលពីព្រឹកថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២៣ បានប្រកាសសាលដីកា តម្កល់ទណ្ឌកម្មរបស់បុរសជាប់ចោទ ជនជាតិបង់ក្លាដេសម្នាក់ និង ស្ត្រីខ្មែរម្នាក់ ដែលត្រូវជាប្ដីប្រពន្ធ នឹងគ្នា ជាប់ពន្ធនាគារ ក្នុងម្នាក់ៗ កំណត់ ០៧ ឆ្នាំ ជាប់ពាក់ព័ន្ធនឹងការរត់ពន្ធ ពលករជនជាតិ បង់ក្លាដេស ចំនួន១៦ នាក់ ឆ្លងដែនខុសច្បាប់ មកធ្វើការក្នុងប្រទេសកម្ពុជា ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុង ឆ្នាំ២០២០។

លោក សឹង បញ្ញាវុឌ្ឍ ជាប្រធានចៅក្រមប្រឹក្សាជំនុំជម្រះ នៃ តុលាការកំពូល បានថ្លែងឲ្យដឹងថា ជនជាប់ចោទ២នាក់ ខាងលើមាន៖ ទីប១- ឈ្មោះ ម៉ម សុខុម ភេទស្រី អាយុ ២៧ ឆ្នាំ ជនជាតិខ្មែរ ។ និងទី ២- ឈ្មោះ MOHAMMED JAHANGIA ភេទប្រុស អាយុ ៣៧ ឆ្នាំ ជនជាតិបង់ក្លាដេស មានមុខរបរមុនចាប់ខ្លួន ជានាយកក្រុមហ៊ុន CEB BIC CIES CO,Lld ។

ពួកគេទាំង២ នាក់ គឺ ត្រូវជាប្ដីប្រពន្ធនឹងគ្នា និង មានទីលំនៅ មុនចាប់ខ្លួន ផ្ទះគ្មានលេខ ផ្លូវលំ ភូមិថ្មគោល ២ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ នៅក្នុងសំណុំរឿងនេះ ជនជាប់ចោទ ទាំង២នាក់ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២១ ផ្តន្ទាទោស ដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ ក្រោមការចោទប្រកាន់ពីបទ : លក់ដូរមនុស្សសម្រាប់នាំឆ្លងដែន តាមបញ្ញត្តិមាត្រា ៨ និង មាត្រា ១២ នៃ ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ ។ ពួកគេ ប្ដឹងឧទ្ធរណ៍ តែ សាលាឧទ្ធរណ៍ រាជធានីភ្នំពេញ បានតម្កល់ទណ្ឌកម្មរបស់គាត់រក្សាទុកជាបានការដែល ។ ពួកគេ ក៏បានបន្តប្ដឹងសារទុក្ខ មកកាន់តុលាការកំពូលទៀត។ ពួកគេ ត្រូវបានចាប់ឃាត់ខ្លួន កាលពីថ្ងៃទី ៣០ខែ កក្កដា ឆ្នាំ ២០២១ នៅភូមិថ្មគោល សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ៕ រក្សាសិទ្ធដោយ ៖ ចន្ទា ភា

# តុលាការខេត្តកំពង់ឆ្នាំងសម្រេចឃុំខ្លួនប្រធានក្រុមហ៊ុន រាជ្យសុផាន់ត្បូង និងបក្ខពួក៣នាក់ពីបទឆបោក

https://www.kampucheathmey.com/security/488038 ថ្ងៃសុក្រ ៣១ មីនា ២០២៣ដោយ Sokhom Khon

ប្រធានក្រុមហ៊ុន រាជ្យសុផាន់ត្បូង ខូអិលធីឌី ម្នាក់ និងបក្ខពួក៣នាក់ទៀត នៅព្រឹកថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣នេះ ត្រូវបានតុលាការខេត្តកំពង់ឆ្នាំង សម្រេចឃុំខ្លួនហើយ បន្ទាប់ពីសមត្ថកិច្ចចាប់ខ្លួនកាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ នៅទីស្នាក់ការក្រុមហ៊ុន ស្ថិតក្នុងភូមិទី៣ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង។

នៅរសៀលថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ មន្ត្រីនគរបាលព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំងបានឲ្យដឹងថា លោកស្រីប្រធានក្រុមហ៊ុន រាជ្យសុផាន់ត្បូង រួមនឹងបក្ខពួក៣នាក់ទៀតត្រូវបានតុលាការសម្រេចឃុំខ្លួនហើយនៅវេលាម៉ោង១២ព្រឹក ថ្ងៃទី៣១ ខែមីនានេះ។ នៅក្នុងសំណុំរឿងឆបោកនេះ គឺក្រុមហ៊ុន រាជ្យសុផាន់ត្បូង បានឆបោកយកលុយពីពលករ២៣នាក់ ជាដើមបណ្ដឹងអស់ ១៤៧.៥០០ដុល្លារ ដើម្បីបញ្ជូនពលករទៅធ្វើការនៅប្រទេសអូស្ត្រាលី។ ប៉ុន្តែចាំបាត់ៗ១ខែជា២ ខែមិនឃើញបញ្ជូនពួកគាត់ទៅប្រទេសអូស្ត្រាលីតាមការសន្យា ទើបបងប្អូនពលករដាក់ពាក្យប្ដឹងទៅស្នងការនគរបាលខេត្តចំណាត់ការតាមផ្លូវច្បាប់។

ប្រជាពលរដ្ឋជាពលករ និងជាជនរងគ្រោះចាញ់បោកក្រុមហ៊ុនខាងលើនេះសុំសំណូមពរដល់ស្ថាប័នតុលាការខេត្តកំពង់ឆ្នាំង មេត្តាជួយចំណាត់ការតាមផ្លូវច្បាប់ យកលុយពីក្រុមហ៊ុននេះ ឬលក់ឡៃឡុងរថយន្តម៉ាកហ្វ

ត ពណ៌ខ្មៅទំនើប របស់ប្រធានក្រុមហ៊ុននេះមកសងពលកររងគ្រោះផង។ យ៉ាងហោចណាស់ក៏សងបានពលករ ២៣នាក់បានពាក់កណ្តាលផងដែរ ព្រោះរថយន្តនេះមានតម្លៃប្រមាណ៨ម៉ឺនដុល្លារ។ ដោយឡែក ឮថាមានបងប្អូនពលករមួយក្រុមទៀតក៏កំពុងដាក់ពាក្យបណ្តឹងប្តឹងប្រធានក្រុមហ៊ុនមួយនេះពីបទឆបោកដូចគ្នាផងដែរទៅកាន់តុលាការ។ ប៉ុន្តែមិនទាន់ដឹងមានចំនួនប៉ុន្មាននាក់ និងឆបោកយកប្រាក់អស់ប៉ុន្មានដុល្លារនោះឡើយ៕ ឈៀង ថារិទ្ធ

## សមត្ថកិច្ចកម្ពុជា បន្តទទួលបានបណ្តឹង ៦ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៩នាក់

https://freshnewsasia.com/index.php/en/localnews/284654-2023-03-31-09-15-39.html 2023-03-31 04:15pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី២៩ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៦ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០៩នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៨២៣ករណី មានមនុស្ស ២,០៧៧នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៧៧៣សំណើ និងបិទសំណុំរឿង ២៦៣សំណើ (រកឃើញមនុស្ស ១,១៧៧នាក់, ឃាត់ខ្លួនជនសង្ស័យ ១២៥នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៥០ករណី៕

## វគ្គបណ្តុះបណ្តាល ស្តីពីការយល់ដឹងការបង្ការ ទប់ស្កាត់ អំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាញ !

https://www.information.gov.kh/articles/101009 ចេញផ្សាយ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២៣

នាព្រឹកថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣នេះ នៅសណ្ឋាគារសោមាទេវី ក្រុងសៀមរាប នាយកដ្ឋានគោលនយោបាយ ICT ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានសហការជាមួយអង្គការ APLE បើកវគ្គបណ្តុះបណ្តាល ស្តីពីការយល់ដឹងការបង្ការ ទប់ស្កាត់ អំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាញ ដោយមានការចូលរួមពីតំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មកពីតាមបណ្តារាជធានី ខេត្តនានា អង្គការដៃគូរ រួមនឹងវិស័យឯកជនពាក់ព័ន្ធ សិស្សានុសិស្សជាច្រើនរូប។

លោកស្រី ហ៊ឹម សោភណ្ឌ ប្រធានកម្មវិធីគាំទ្រ និងផ្តល់ជំនួយសម្រាប់កុមាររងគ្រោះអង្គការ APLE បានបញ្ជាក់ថា វគ្គបណ្តុះបណ្តាលនាពេលនេះ មានគោលបំណង ដើម្បីលើកកម្ពស់ការយល់ដឹងបន្ថែមអំពីហានិភ័យដែលអាចកើតមានឡើងចំពោះកុមារ លើការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ។ ជាមួយគ្នានោះដែរ វគ្គបណ្តុះបណ្តាលនេះ ក៏នឹងធ្វើការពង្រឹងបន្ថែមទៅដល់អ្នកពាក់ព័ន្ធ ធ្វើយ៉ាងណាចូលរួមទាំងអស់គ្នាក្នុងការទប់ស្កាត់ឲ្យបាននូវបញ្ហាទាំងអស់នេះ ឲ្យឆ្លើយតបចំពោះហានិភ័យ និងទម្រង់ពាក់ព័ន្ធទាំងនោះ វិធានសុវត្ថិភាពចំពោះកុមារតាមប្រព័ន្ធអនឡាញ Blocking, Filtering, Reporting វិធានការបង្ការ ទប់ស្កាត់ផ្សេងៗទៀត។

បើតាមលោកស្រី តាន់ សុដានី ប្រធាននាយកដ្ឋានគោលនយោបាយ ICT ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានឲ្យដឹងថា អំពើជួញដូរមនុស្ស គឺជាវិបត្តិសកលមួយ ដែលបណ្ដាប្រទេសជាច្រើនលើសកលលោកបានជួបប្រទះ ហើយក្នុងនោះប្រទេសកម្ពុជារបស់យើងក៏បានទទួលរងនូវវិបត្តិនេះផងដែរ ដែលធ្វើឱ្យរាជរដ្ឋាភិបាល ក៏ដូចជាប្រជាពលរដ្ឋទាំងអស់មានការព្រួយបារម្ភជាខ្លាំង។ បន្ទាប់ពីព្រះរាជាណាចក្រកម្ពុជា បានផ្ដល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិ ដើម្បីធានាការអភិវឌ្ឍន៍ផ្ដល់ការងារសមស្រប សមភាព ប្រសិទ្ធភាព និងធានាឱ្យសម្រេចបានតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦ -២០៣០ រួមទាំងបង្កើតយន្តការជាច្រើននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីសម្របសម្រួលដល់ការអនុវត្តលិខិតបទដ្ឋានគតិយុត្តរួមទាំងគោលនយោបាយ និងផែនការសកម្មភាពលើការងារពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចលើកុមារ សំដៅការពារសិទ្ធិ និងផលប្រយោជន៍ដល់កុមារ។

លោកស្រីបន្ថែមថា ជាមួយនឹងការដាក់ផែនការទាំងនេះ ប៉ុន្តែក្នុងនោះក៏មានកុមារកម្ពុជានៅតែជួបបញ្ហាប្រឈមមួយចំនួននៅឡើយដូចជា អំពើហិង្សាលើកុមារ ការកេងប្រវ័ញ្ច ការជួញដូរកុមារ ការប្រើប្រាស់គ្រឿងញៀន និងសារធាតុញៀន កុមារបម្លាស់ទី កុមាររងផលប៉ះពាល់ដោយការធ្វើចំណាកស្រុក កុមារបោះបង់ការសិក្សា កុមារកង្វះហារូបត្ថម្ភ ជាដើម និងកុមាររងការរំលោភបំពានតាមប្រព័ន្ធអនឡាញ ដែលជាប្រព័ន្ធផ្ដល់សេវាកម្មតាមបច្ចេកវិទ្យាកំពុងពេញនិយមដែលផ្ដល់នូវទាំងផលវិជ្ជមាន និងផលអវិជ្ជមានផងដែរ។ ហើយបញ្ហាទាំងនេះ គឺតម្រូវឱ្យក្រសួង ស្ថាប័ន អាជ្ញាធរ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន សហគមន៍ ឪពុកម្ដាយ រួមគ្នាដោះស្រាយឱ្យបានទាន់ពេលវេលា និងចំគោលដៅ ប្រកបដោយគុណភាព និងប្រសិទ្ធភាព។

លោក សុខ សីហា ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត តំណាងឱ្យរដ្ឋបាលខេត្ត មានប្រសាសន៍ថា ខេត្តសៀមរាប ជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ ដែលរាជរដ្ឋាភិបាលបានចាត់ទុកជាតំបន់ប៉ូលទី២ នៃការអភិវឌ្ឍវិស័យទេសចរណ៍របស់ជាតិ ក៏ដូចជាខឿនសេដ្ឋកិច្ចជាតិ ដែលមានភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិចូលមកទស្សនាកម្សាន្តកើនឡើងគួរឱ្យកត់សម្គាល់។ ទន្ទឹមនឹងផលវិជ្ជមានពីសេវាកម្មទេសចរណ៍យើងក៏បានទទួលរងផលជាអវិជ្ជមានផងដែរ ពីអ្នកទេសចរណ៍មួយចំនួន ដែលមានបំណងទុច្ចរិត បានឆក់ឱកាសប្រព្រឹត្តបទល្មើសរំលោភបំពាន ការកេងប្រវ័ញ្ចផ្លូវភេទទៅលើកុមារតាមរូបភាពផ្សេងៗ និងការយកខេត្តសៀមរាប ជាខេត្តសម្រាប់ឆ្លងកាត់ការនាំចេញមនុស្សដោយខុសច្បាប់ និងកន្លែងសម្រាប់ប្រព្រឹត្តបទល្មើស។

ជាមួយគ្នានោះ លោកប្រធានមន្ទីរ ក៏បានស្នើដល់គ្រប់អ្នកពាក់ព័ន្ធទាំងអស់ ធ្វើការតាមដានត្រួតពិនិត្យ វាយតម្លៃ និងធ្វើបច្ចុប្បន្នកម្មជាប្រចាំ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់ស្ដែងរបស់កុមារ ពិសេសអាជ្ញាធរនៅតាមមូលដ្ឋាន ដើម្បីឲ្យកុមារដែលលទទួលរងនូវការរំលោភបំពានទទួលបាននូវការផ្ដល់សេវា និងការយកចិត្តទុកដាក់ជាពហុវិស័យបន្ថែមទៀត មានន័យថាធ្វើសកម្មភាពផ្សេងៗគ្នា ដើម្បីឈានទៅសម្រេចគោលបំណងរួមតែមួយជូនសង្គមជាតិ និងធ្វើឱ្យមានសុខមាលភាពសង្គមជាតិ៕ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយៈ ធូ កុសល

# ថ្ងៃទី០៤ ខែ មេសា ឆ្នាំ២០២៣

## សម្តេចក្រឡាហោម ស ខេង ណែនាំឱ្យអាជ្ញាធរខេត្តព្រះសីហនុ ត្រូវដោះស្រាយបញ្ហាដែលនៅសេសសល់កន្លងមក ព្រោះកម្ពុជាត្រូវបានគេយកធ្វើជាកន្លែងជួញដូរមនុស្ស

https://www.information.gov.kh/articles/101020 ចេញផ្សាយ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០២៣

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានណែនាំដល់អាជ្ញាធរខេត្តព្រះសីហនុ ត្រូវដោះស្រាយបញ្ហាដែលនៅសេសសល់កន្លងមក ព្រោះកម្ពុជាត្រូវបានគេយកធ្វើជាកន្លែងជួញដូរមនុស្ស ជួញដូរពលកម្ម។ ការណែនាំរបស់សម្តេចក្រឡាហោមបែបនេះ ក្នុងឱកាសអញ្ជើញពិធីបិទសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់រដ្ឋបាលខេត្តព្រះសីហនុ នៅសណ្ឋាគារសុខា ក្រុងព្រះសីហនុ កាលពីរសៀលថ្ងៃសុក្រ ១០កើត ខែចែត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ ។

សម្តេចក្រឡាហោម ស ខេង បានថ្លែងថា អាជ្ញាធរខេត្តត្រូវបន្តធានាសុខសន្តិភាព ការការពារសុវត្ថិភាពជូនប្រជាពលរដ្ឋ ពិសេសអនុវត្តន៍គោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព ហើយប៉ុស្តិ៍នគរបាល ត្រូវពង្រឹងគុណភាព ទទួលខុសត្រូវ និងមានវត្តមានធ្វើការជាប់ជាប្រចាំ ដើម្បីបំពេញចន្លោះប្រហោងដែលមានការយឺតយ៉ាវ។ សម្តេចក្រឡាហោម បានលើកឡើងថា ឆ្នាំ២០២២ ត្រូវបានចាត់ទុកជាឆ្នាំ អនុវត្តន៍ច្បាប់ជំហានដំបូង ហើយឆ្នាំ ២០២៣ អនុវត្តន៍ច្បាប់ ដើម្បីដោះស្រាយបញ្ហាប្រឈមដែលនៅសេសសល់ ដើម្បីទាក់ទាញការចាប់អារម្មណ៍ពីប្រជាពលរដ្ឋ មតិជាតិ អន្តរជាតិ និងវិនិយោគចិន។

សម្តេចក្រឡាហោមបានថ្លែងបញ្ជាក់ថា៖ «យើងខិតខំដោះស្រាយ គាំទ្រគោលការណ៍ វិធានការរបស់រាជរដ្ឋាភិបាលដោយឯកភាពគ្នាប្រកបដោយតម្លាភាព ដើម្បីលើកស្ទួយកិត្យានុភាពខេត្តព្រះសីហនុ។ ដូច្នេះយើងត្រូវការគាំទ្រពីប្រទេសជាសមាជិក អង្គការដៃគូក្នុងការទប់ស្កាត់បទល្មើសឱ្យខានតែបាន ហើយនេះជាកិច្ចការអាទិភាពរបស់ខេត្តព្រះសីហនុ។ ខ្ញុំស្នើសុំឱ្យមន្ត្រីរបស់យើងខិតខំការពារសន្តិសុខ សុវត្ថិភាពការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំមូលដ្ឋាន និងថ្នាក់ដឹកនាំប្រទេសជាតិ អនុវត្តន៍កិច្ចការនេះឱ្យបានល្អ រក្សាសន្តិភាព ស្ថិរភាព ការអភិវឌ្ឍប្រទេសរយៈពេល៥បន្តឆ្នាំ២០២៣-២០២៨ ដោយសេរី ប្រើប្រាស់សិទ្ធិក្នុងការបញ្ចេញមតិប្រកួតប្រជែងបោះឆ្នោតដោយសេរី គ្មានអំពើហិង្សា សន្តិសុខល្អ ដើម្បីទាញការគាំទ្រការបោះឆ្នោតជាផ្លូវការឱ្យទទួលបានជោគជ័យ»។ សម្តេចក្រឡាហោម ស ខេង ក៏បានជំរុញស្នងការនគរបាលខេត្ត បន្តបណ្តុះបណ្តាលគ្រូបង្គោល សុំឱ្យគណៈបញ្ជាការឯកភាពខេត្ត ក្រុង ស្រុក រៀបចំប្រជាការពារឱ្យបានគ្រប់ភូមិ ក្នុងការការពារសុវត្ថិភាពភូមិរបស់យើង ពង្រឹងប៉ុស្តិ៍នគរបាល និងប្រជាការពារប្រកបដោយស្មារតីម្ចាស់ការ។

ក្នុងឱកាសនោះដែរ សម្តេចក្រឡាហោម ស ខេង បានកោតសើរសើររដ្ឋបាលខេត្ត មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធបានរួមសាមគ្គីគ្នាទទួលខុសត្រូវ ហើយសមិទ្ធផលដែលទទួលបានពីសន្និបាតជាផែនទីបង្ហាញផ្លូវសម្រាប់អនុវត្តន៍ឆ្នាំ២០២៣។ ទន្ទឹមនេះ សម្តេចក្រឡាហោមបានណែនាំឱ្យអាជ្ញាធរខេត្ត គប្បីយកចិត្តទុក ដាក់បន្ថែមទៀត ទោះបី សម្រេចបានលទ្ធផលការងារដោះស្រាយកង្វល់របស់រាជរដ្ឋាភិបាល ប្រជាពលរដ្ឋ ទាក់ទងនឹងតួនាទី និងកិត្យានុភាពរបស់រដ្ឋបាលខេត្ត ក្នុងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន បទល្មើស ជួញដូរមនុស្ស ជួញដូរពលកម្ម ដែលធ្វើឱ្យប៉ះពាល់កិត្យានុភាពខេត្ត ប៉ះពាល់មុខមាត់ព្រះរាជាណាចក្រកម្ពុជា និងហាក់បីរារាំងនូវការវិនិយោគ ក៏ដូចជាវិស័យទេសចរណ៍។

សម្តេចក្រឡាហោម ស ខេង បានបន្តថា ខេត្តព្រះសីហនុ ជាប៉ូលសេដ្ឋកិច្ច បើយើងមិនបានដោះស្រាយទាន់ពេលវេលា និងធ្លាក់ក្នុងបញ្ហាធ្ងន់ធ្ងរ យើងត្រូវធ្វើកិច្ចការជាច្រើនសម្រាប់ភ្ញៀវទេសចរ និងអ្នកវិនិយោគចិន ពួកគាត់មិនទាន់វិលមកកាន់កម្ពុជា ពិសេសខេត្តព្រះសីហនុ ដោយសារវិបត្តិកូវីដ-១៩ ហើយវាមិនមែនប៉ះពាល់ខេត្តព្រះសីហនុប៉ុណ្ណោះទេ ក៏ប៉ះពាល់ដល់ខេត្តសៀមរាប និងខេត្តផ្សេងទៀត។ សម្តេចក្រឡាហោមបានបន្តទៀតថា រាជរដ្ឋាភិបាលបានធ្វើការកែទម្រង់ដោយធ្វើការចែករំលែកទស្សនទានដោយបានរៀបចំសិក្ខាសាលានៅខេត្តព្រះសីហនុ ស្តីពីគោលនយោបាយក្របខណ្ឌ រៀបចំតាក់តែងច្បាប់ ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ហើយបានដាក់ឱ្យដំណើរការរយពេល ២០ឆ្នាំមកហើយ ដែលមានការកោតសរសើរគាំទ្រចែករំលែកសិទ្ធិអំណាច ធនធានដល់ថ្នាក់ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ ទទួលខុសត្រូវរៀងៗខ្លួន ដែលនឹងបន្តធ្វើការងារនេះ និងត្រួតពិនិត្យវាយតម្លៃ និងឯកភាពគ្នាក្នុងរដ្ឋបាលនីមួយៗទាមទារនូវធនធានមនុស្សផងដែរ។

សម្តេចក្រឡាហោម ស ខេង បានបន្ថែមទៀតថា រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរកប្រភពចំណូល និងប្រើប្រាស់ប្រភពចំណូលរបស់ខ្លួនដូចជា ទី១.ចំណូលថវិការដ្ឋ ២.ចំណូលរកដោយខ្លួនឯង ស្របច្បាប់ និងទី៣. ចំណូលពីសប្បុរសជន ដើម្បីឱ្យរដ្ឋបាលរបស់យើងរឹងមាំខ្លាំង ទន្ទឹមនោះបង្កើនរបបប្រជុំរវាងក្រុមប្រឹក្សា និងគណៈអភិបាលឱ្យបានទៀងទាត់តាមតួនាទី ភារកិច្ច ។

ឯកឧត្តម គួច ចំរើន អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុបានថ្លែងថា អង្គសន្និបាត នឹងប្រមូលយកបញ្ហាប្រឈម វិធានការដោះស្រាយ និងសំណូមពរចងក្រងជាផែនការសកម្មភាព និងលើកទិសដៅការងារ ដើម្បីអនុវត្តន៍ជាក់ស្តែងឆ្នាំ២០២៣ ជាមួយការប្តេជ្ញាចិត្តរួមគ្នាថែរក្សា ការពារនូវសុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពក្នុងសង្គម រួមគ្នារៀបចំពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរឱ្យប្រព្រឹត្តទៅដោយរលូនសប្បាយរីករាយ។ ទន្ទឹមនេះ ចូលរួមរក្សាសុវត្ថិភាពក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំការងារទេសចរណ៍លើកទី៥១ និងវេទិកាទេសចរណ៍មេគង្គឆ្នាំ២០២៣ ការរៀបចំព្រឹត្តិការណ៍កីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ដែលខេត្តព្រះសីហនុធ្វើជាម្ចាស់ផ្ទះរៀបចំកីឡា ៣ ប្រភេទ រួមមាន កីឡាទូកក្តោង កីឡាម៉ូតូទឹក និងកីឡាបាល់ទះលើឆ្នេរខ្សាច់ ពិសេសជានាឱ្យការបោះឆ្នោតជាតិលើកទី៧ នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ប្រព្រឹត្តទៅដោយលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌។

យោងតាមលទ្ធផល នៃសន្និបាតរបស់រដ្ឋបាលខេត្ត និងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ អង្គសន្និបាតបានឯកភាពសហការជំរុញកៀគររកចំណូលស្របច្បាប់ និងធ្វើការវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលដែលរដ្ឋបាលខេត្តសម្រេចបានក្នុងឆ្នាំ២០២២កន្លងមក អាស្រ័យដោយមានការចូលរួមដឹកនាំពីក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ព្រមទាំងដោយមានការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងមហាផ្ទៃ និងទទួលយកទិសដៅរបស់សន្និបាតក្រសួងមហាផ្ទៃ ជាទិសដៅគោលសម្រាប់អនុវត្តន៍៕
ដោយៈ ងូ សុមុនី

# អភិបាលរងខេត្តកំពង់ធំ ជំរុញសហគ្រាស-គ្រឹះស្ថានទាំងអស់ប្រើប្រាស់ហត្ថពលកម្មបរទេស ត្រឹមត្រូវតាមច្បាប់

https://freshnewsasia.com/index.php/en/localnews/284642-2023-03-31-07-57-02.html 2023-03-31 02:57pm

**(កំពង់ធំ)៖** លោក លី វេត អភិបាលរងខេត្តកំពង់ធំ បានជំរុញឲ្យសហគ្រាសនិងគ្រឹះស្ថានទាំងអស់ចូលរួមសហការជាមួយអាជ្ញាធរដែនដី ក្នុងការប្រើប្រាស់ហត្ថពលកម្មបរទេសឲ្យបានច្បាស់លាស់។ លោកអភិបាលរងខេត្តកំពង់ធំថ្លែងបែបនេះក្នុងពិធីផ្សព្វផ្សាយការងារគ្រប់គ្រងហត្ថពលកម្មបរទេសនៅកម្ពុជាដល់រោងចក្រ សហគ្រាស គ្រឹះស្ថានទូទាំងខេត្តកំពង់ធំ នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ ដែលរៀបចំដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត។ លោកបន្តថា រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី បង្កលក្ខណៈអំណោយផលដល់ការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ការទាក់ទាញការវិយោគទាំងនៅក្នុងប្រទេសទាំងពីបរទេស ព្រមទាំងវំហូរទេសចរបរទេសមកទស្សនានៅកម្ពុជាប់លាននាក់ក្នុងមួយឆ្នាំៗ ដែលបានជំរុញកម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេលជាងមួយទសវត្សរ៍ចុងក្រោយ។

**លោកបានបន្តទៀតថា ជនបរទេសត្រូវបំពេញបណ្តាលក្ខខណ្ឌផ្សេងៗទៀត ដូចតទៅ៖**

* និយោជក ត្រូវមានជាមុននូវប័ណ្ណការងារត្រឹមត្រូវដើម្បីប្រកបមុខរបររបស់ខ្លួននៅកម្ពុជា

* ជនបរទេសនោះ ត្រូវបានចូលមកកម្ពុជា ដោយត្រឹមត្រូវតាមផ្លូវច្បាប់

* ជនបរទេសនោះ ត្រូវមានលិខិតឆ្លងដែនត្រឹមត្រូវ

* ជនបរទេសនោះ ត្រូវមានប័ណ្ណស្នាក់នៅត្រឹមត្រូវ

* ជនបរទេសនោះ ត្រូវមានកាយសម្បទាសមស្របនឹងមុខរបរនោះ ហើយគ្មានកើតជំងឺឆ្លងណាមួយ ហើយលក្ខខណ្ឌនេះត្រូវបានកំណត់ដោយប្រកាសក្រសួងសុខាភិបាល ដោយមានការឯកភាពពីក្រសួងទទួលបន្ទុកវិស័យការងារ។

**លោក អៀង សុភាព ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានលើកឡើងថា កិច្ចប្រជុំផ្សព្វផ្សាយនាពេលនេះមានគោលបំណងសំខាន់ៗដូចខាងក្រោម៖**

១. លើកកម្ពស់ការងារគ្រប់គ្រងជនបរទេសស្នាក់នៅប្រកបមុខរបរនិងធ្វើការនៅកម្ពុជា។

២. ពង្រឹងការអនុវត្តតាមច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីអន្តោប្រវេសន៍ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធឱ្យបានម៉ឺងម៉ាត់។

៣. ផ្សព្វផ្សាយគោលការណ៍វិធានការពាក់ព័ន្ធការងារអធិការកិច្ចហត្ថពលកម្មបរទេសដល់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាននានា ដើម្បីគាំទ្រដល់ផែនការប្រតិបត្តិការបង្កើនការងារ ប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម ជួញដូរផ្លូវភេទ បទល្មើសពាក់ព័ន្ធល្បែងស៊ីសងខុសច្បាប់ ឬការឆបោកតាមប្រព័ន្ធអនឡាញ ឬបទល្មើសសម្អាតប្រាក់ ឬបទល្មើសផ្សេងៗទៀត ដើម្បីចាត់វិធានការតាមច្បាប់។

គួរបញ្ជាក់ថា ខេត្តកំពង់ធំមានសហគ្រាស គ្រឹះស្ថានសរុប ៤០៧សហគ្រាស មានកម្មករនិយោជិតចំនួន ១៤,៣២០នាក់ ស្រី៥,៤២៨ នាក់ក្នុងនោះសហគ្រាស គ្រឹះស្ថានដែលមានប្រើប្រាស់ហត្ថពលកម្មបរទេសចំនួន ៣៥សហគ្រាស មានកម្មករនិយោជិតបរទេសសរុប៦៨៤នាក់ ស្រី១៣៣នាក់ ដែលមាន១៩សញ្ជាតិ៕

# សម្តេចក្រឡាហោមជំរុញឱ្យរដ្ឋបាលខេត្តបន្តខិតខំប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន និង គ្រឿងញៀន

https://www.btv.com.kh/article/21811 2023/04/01 12:51:49 pm

ព្រះសីហនុ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ "ជំរុញឱ្យរដ្ឋបាលខេត្តបន្តខិតខំប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ការជួញដូរមនុស្ស និងគ្រឿងញៀន ដែលធ្វើឱ្យប៉ះពាល់កិត្យានុភាពរាំងនូវការវិនិយោគ និងវិស័យទេសចរណ៍" ថ្លែងក្នុងពិធីបិទសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់រដ្ឋបាលខេត្តព្រះសីហនុនៅសណ្ឋាគារ សុខា ប៊ិច ក្រុងព្រះសីហនុកាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។

សម្តេចក្រឡាហោមមានប្រសាសន៍ថា សមិទ្ធផលដែលទទួលបានពីសន្និបាតជាផែនទីបង្ហាញផ្លូវសម្រាប់អនុវត្តឆ្នាំ២០២៣ ហើយគប្បីយកចិត្តទុកដាក់បន្ថែមទៀត។ ទោះបីយើងសម្រេចបានលទ្ធផលការងារដោះស្រាយកង្វល់របស់រាជរដ្ឋាភិបាល ប្រជាពលរដ្ឋ ទាក់ទងនឹងតួនាទី និងកិត្យានុភាពរបស់រដ្ឋបាលខេត្តក្នុងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន បទល្មើស ជួញដូរមនុស្ស ជួញដូរពលកម្ម ដែលធ្វើឱ្យប៉ះពាល់កិត្យានុភាពខេត្ត ប៉ះពាល់មុខមាត់ព្រះរាជាណាចក្រកម្ពុជា វាហាក់បីរាំងនូវការវិនិយោគក៏ដូចជាវិស័យទេសចរណ៍។ ខេត្តព្រះសីហនុជាប៉ូលសេដ្ឋកិច្ចបើយើងមិនបានដោះស្រាយទាន់ពេលវេលា និងធ្លាក់ក្នុងបញ្ហាធ្ងន់ធ្ងរ យើងត្រូវធ្វើកិច្ចការជាច្រើនសម្រាប់ភ្ញៀវទេសចរ និងអ្នកវិនិយោគចិន ពួកគាត់មិនទាន់វិលមកកាន់កម្ពុជា ពិសេសខេត្តព្រះសីហនុ។ ឆ្នាំ២០២២ យើងចាត់ទុកជាឆ្នាំអនុវត្តច្បាប់ជំហានដំបូង ហើយឆ្នាំ២០២៣ អនុវត្តច្បាប់ដើម្បីដោះស្រាយបញ្ហាប្រឈមដែលនៅសេសសល់ ដើម្បីទាក់ទាញការចាប់អារម្មណ៍ពីប្រជាពលរដ្ឋ មតិជាតិ អន្តរជាតិ វិនិយោគចិន។ យើងខិតខំដោះស្រាយ គាំទ្រគោលការណ៍ វិធានការណ៍របស់រាជរដ្ឋាភិបាលដោយឯកភាពគ្នាប្រកបដោយតម្លាភាព ដើម្បីលើកស្ទួយកិត្យានុភាពខេត្តព្រះសីហនុ។

សម្តេចបន្តថា ត្រូវដោះស្រាយបញ្ហាដែលនៅសេសសល់កន្លងមក ព្រោះកម្ពុជាត្រូវបានគេយកធ្វើជាកន្លែងជួញដូរមនុស្ស ជួញដូរពលកម្ម ដូច្នេះយើងត្រូវការគាំទ្រពីប្រទេសជាសមាជិក អង្គការដៃគូក្នុងការទប់ស្កាត់បទល្មើសឲ្យខានតែបាន ហើយនេះជាកិច្ចការអាទិភាពរបស់ខេត្តព្រះសីហនុ ស្នើសុំឲ្យមន្ត្រីរបស់យើងខិតខំការពារសន្តិសុខ សុវត្ថិភាពការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំមូលដ្ឋាន និងថ្នាក់ដឹកនាំប្រទេសជាតិ អនុវត្តកិច្ចការនេះឲ្យបានល្អ រក្សាសន្តិភាព ស្ថិរភាព ការអភិវឌ្ឍប្រទេសរយៈពេល ៥ ចាប់ពីឆ្នាំ២០២៣-២០២៨ ដោយសេរី ប្រើប្រាស់សិទ្ធិក្នុងការបញ្ចេញមតិ ប្រកួតប្រជែងបោះឆ្នោតដោយសេរី គ្មានអំពើហិង្សា សន្តិសុខល្អ ដើម្បីទាញការគាំទ្រការបោះឆ្នោតជាផ្លូវការឲ្យទទួលបានជោគជ័យ ធានាសុខសន្តិភាព ការការពារសុវត្ថិភាពជូនប្រជាពលរដ្ឋ ពិសេសអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ម្យ៉ាងទៀតប៉ុស្តិ៍នគរបាលត្រូវពង្រឹងគុណភាពទទួលខុសត្រូវ និងមានវត្តមានធ្វើការជាប់ជាប្រចាំ ដើម្បីបំពេញចន្លោះប្រហោងដែលមានការយឺតយ៉ាវ។រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរកប្រភពចំណូល និងប្រើប្រាស់ប្រភពចំណូលរបស់ខ្លួនដូចជា ទី១.ចំណូលថវិការដ្ឋ ២.ចំណូលរកដោយខ្លួនឯងស្របច្បាប់ និងទី៣.ចំណូលពីសប្បុរសជន ដើម្បីឲ្យរដ្ឋបាលរបស់យើងរឹងមាំខ្លាំង ទន្ទឹមនោះបង្កើនរបបប្រជុំរវាងក្រុមប្រឹក្សា និងគណៈអភិបាលឱ្យបានទៀងទាត់តាមតួនាទីភារកិច្ច៕ អត្ថបទ៖ គង់ ប៊ុនថា

## ជិតចូលឆ្នាំខ្មែរ ពលករត្រឡប់ជាបណ្ដើរៗហើយតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត

https://kohsantepheapdaily.com.kh/article/1713653.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram បន្ទាយមានជ័យ០១ ខែ មេសា ឆ្នាំ ២០២៣ ម៉ោង ១៥:០៧

ខេត្តបន្ទាយមានជ័យ ៖ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរជិតមកដល់ បានឃើញពលករត្រឡប់ជាបណ្ដើរៗហើយតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត រៀបចំសណ្ដាប់ធ្នាប់សន្តិសុខបានល្អ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០២៣ ក្រុងប៉ោយប៉ែត ។

លោកឧត្តមសេនីយ៍ត្រី អ៊ី ចំរើន នាយប៉ុស្តិ៍នគរបាលអន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែតបានប្រាប់ថា នៅចុងខែមីនា ឆ្នាំ២០២៣នេះ ឃើញពលករខ្មែរត្រូវបានត្រឡប់មកវិញច្រើនខុសពីធម្មតា១ថ្ងៃ មានរាប់រយនាក់ នៅឱកាសមុនថ្ងៃបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរជិតមកដល់ ដើម្បីត្រឡប់មកជួបជុំក្រុមគ្រួសារបើប្រៀបធៀបកាលពីមុនពលករខ្មែរឃើញឆ្លងកាត់ទៅរកការងារធ្វើប្រទេសថៃភាគច្រើន ។ លោកបានប្រាប់ថា ច្រកទ្វារអន្តរជាតិប៉ោយប៉ែតក្រោយពីបើកអោយចេញចូលពីរង្វង់មូលមកច្រកទ្វារ គឺកម្លាំងនគរបាលអន្តោប្រវេសន៍ប្រចាំច្រកទ្វារបានធ្វើការរៀបចំសណ្ដាប់ធ្នាប់មិនអោយម៉ូតូកង់បី ឬផាស្លាប់ និងម៉ូតូឌុបត្រូវបានដាក់តាមលេខរៀងមិនអោយចតនៅក្នុងបរិវេណច្រកទ្វារធ្វើប៉ះពាល់សណ្ដាប់ធ្នាប់ និងអសន្តិសុខទើបរៀបចំអោយនៅរង្វង់មូលប៉ោយប៉ែតផ្លូវច្រកទ្វារ ហើយអោយភ្ញៀវទៅជិះចេញតាមលេខរៀងការពារដណ្ដើមម៉ូយឈ្លោះគ្នាកើតឡើង ។

លោកឧត្តមសេនីយ៍ត្រី អ៊ី ចំរើន បានបញ្ជាក់ថា ក្រោយរៀបចំសណ្ដាប់ធ្នាប់ក្នុងបរិវេណច្រកទ្វារឃើញមានសោភ័ណភាពល្អ និងសុវត្ថិភាពដល់ភ្ញៀវជាតិ និងអន្តរជាតិដែលចូលមកកម្ពុជា ដើម្បីមកកំសាន្តនិងទៅលេងនៅប្រាសាទអង្គរវត្តសៀមរាប និងតាមរមណីយដ្ឋាននៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីយ៍ខ្មែរ ។

## ពលករខ្មែរដែលមកលេងបុណ្យចូលឆ្នាំត្រូវចូលតាមច្រកទ្វារអន្តរជាតិ មិនអនុញ្ញាតឱ្យចូលតាមច្រករបៀង ឬដើរកាត់ព្រៃឡើយ

https://freshnewsasia.com/index.php/en/localnews/284759-2023-04-01-06-50-46.html 2023-04-01 01:50pm

**(បន្ទាយមានជ័យ)៖** មន្ត្រីជាន់ខ្ពស់នាយកដ្ឋានកណ្ដាលនគរបាលព្រំដែន បានប្រកាសទៅកាន់ពលករខ្មែរដែលមានបំណងចេញពីប្រទេសថៃ ដើម្បីមកលេងបុណ្យចូលឆ្នាំថ្មីនៅស្រុកកំណើតវិញ ត្រូវធ្វើដំណើរចូលតាមច្រកទ្វារព្រំដែនអន្តរជាតិ ដាច់ខាតមិនអនុញ្ញាតឱ្យចូលតាមច្រករបៀង ឬដើរកាត់ព្រៃឡើយ ព្រោះអាចប្រឈមនឹងគ្រោះថ្នាក់។ មន្ត្រីជាន់ខ្ពស់ដដែលនោះក៏បានបញ្ជាទៅកាន់កម្លាំងឈរជើងតាមបន្ទាត់ព្រំដែន ត្រូវត្រៀមការពារពលករដែលឆ្លងពីប្រទេសថៃចូលមកកម្ពុជា និងអនុវត្តបទបញ្ជានេះឱ្យបានត្រឹមត្រូវ។ ការលើកឡើងនេះធ្វើឡើងក្នុងឱកាសជួបសំណេះសំណាលជាមួយកម្លាំងឈរជើងតាមបន្ទាត់ព្រំដែននៅទិសភូមិភាគ៥ ក្រុងប៉ោយប៉ែត នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។

លោកឧត្តមសេនីយ៍ឯក លៀង ភារម្យ ប្រធាននាយកដ្ឋានកណ្ដាលនគរបាលព្រំដែន បានណែនាំនិងដាក់វិធានការចំពោះកងកម្លាំងដែលកំពុងឈរជើងតាមបន្ទាត់ព្រំដែន ត្រូវទប់ស្កាត់ពលករខ្មែរមិនឱ្យលួចចូលតាមច្រករបៀងខុសច្បាប់ និងឆ្លងដែនកាត់ព្រៃឡើយ ព្រោះអាចប្រឈមគ្រោះថ្នាក់គ្រប់ពេល។ លោកឧត្តមសេនីយ៍ឯក លៀង ភារម្យ បានបន្តណែនាំទៀតថា «**កងកម្លាំងដែលកំពុងឈរជើងតាមបន្ទាត់ព្រំដែន ត្រូវណែនាំឱ្យពលករចូលតាមច្រកទ្វារព្រំដែនអន្តរជាតិ ក្នុងឱកាសដែលពួកគាត់មកលេងបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ**»។

ចំណែកលោកឧត្តមាសេនីយ៍ទោ ស៊ឹម សំអាត ប្រធាននាយកដ្ឋាននគរបាលការពារព្រំដែនគោកទិសភូមិភាគ៥ ក៏បានរំលឹកពីការខិតខំ និងស្នាដៃរបស់កងកម្លាំងឈរជើងតាមបន្ទាត់ព្រំដែនផងដែរ។

ជាមួយគ្នានោះ លោកឧត្តមសេនីយ៍ទោ ខេង សុហ្វីណេ អនុប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែនបានណែនាំដល់កងកម្លាំងនគតរបាលការពារព្រំដែនគោកទិសភូមិភាគ៥ ត្រូវខិតខំការពារបូរណភាពទឹកដី មិនឱ្យប្រទេសជិតខាងឈ្លានពាន និងទប់ស្កាត់បទល្មើសឆ្លងដែនរថយន្តចង្កូតស្តាំ ម៉ូតូ និងទំនិញខូចគុណភាព ដែលឈ្មួញលួចលាក់នាំចូលឆ្លងដោយខុសច្បាប់នាំចូលពីប្រទេសជិតខាង ត្រូវទប់ស្កាត់ឱ្យបាន៕

## អាជ្ញាធរកម្ពុជានៅឡាវបញ្ជូនពលករខ្មែរចំនួន ៧ នាក់មកកម្ពុជាវិញ ក្រោយរំដោះចេញពីក្រុមហ៊ុនចិនដែលឃុំឃាំងឱ្យធ្វើការ

https://www.postkhmer.com/national/2023-04-01-0916-248676.html រី សុចាន់ | Publication date 01 April 2023 | 16:16 ICT

**ភ្នំពេញៈ** ស្ថានទូតកម្ពុជាប្រចាំប្រទេសឡាវបានបញ្ជូនពលករខ្មែរចំនួន ៧ នាក់ត្រឡប់មកកម្ពុជាវិញ នៅថ្ងៃទី១ ខែមេសា នេះបន្ទាប់ពីត្រូវបានរំដោះចេញពីក្រុមហ៊ុនចិន ដែលឃុំឃាំងពួកគេឱ្យធ្វើការមិនឱ្យចេញពីក្រុមហ៊ុន។ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំឡាវបញ្ជាក់ក្នុងហ្វេសប៊ុកនាថ្ងៃទី១ ខែមេសា ថាស្ថានទូតកម្ពុជា បានសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងការបរទេស និងអាជ្ញាធរមូលដ្ឋានខេត្តបកែវប្រទេសឡាវ ដែលជាខេត្តស្ថិតនៅតំបន់ត្រីកោណមាស ជាប់ព្រំដែនជាមួយប្រទេសមីយ៉ាន់ម៉ា និងថៃ «ដើម្បីរំដោះពលករខ្មែរ ៧ នាក់ ដែលត្រូវថៅកែក្រុមហ៊ុនចិនរំលោភលើសិទ្ធិការងារឃុំឃាំង ឱ្យធ្វើការមិនឱ្យចេញពីក្រុមហ៊ុនចិន»។

ហ្វេសប៊ុកដដែលបន្តថា៖ «នៅថ្ងៃសៅរ៍ ទី១ ខែមេសា នេះ ស្ថានទូតបានសហការជាមួយស្ថានអគ្គកុងស៊ុលកម្ពុជានៅទីក្រុងប៉ាក់សេ បញ្ជូនពលករទាំង ៧ នាក់នោះត្រឡប់ទៅកម្ពុជាវិញ»។។ ស្ថានអគ្គកុងស៊ុលបានផ្តល់អាហារហូបចុក ព្រមទាំងជួលឡានដឹកជញ្ជូនពលករទាំង ៧ នាក់តាមច្រកព្រំដែនអន្តរជាតិណងណុកខៀន-ត្រពាំងគ្រៀលមកភ្នំពេញវិញ។ ហ្វេសប៊ុកដដែលបន្ថែមថា ស្ថានទូត និងស្ថានអគ្គកុងស៊ុលកម្ពុជា ក៏បានណែនាំដល់ពលករខ្មែរទាំងនោះ ត្រូវពិចារណាឱ្យបានច្បាស់មុននឹងសម្រេចចិត្តចំណាកស្រុកទៅធ្វើការងារនៅក្រៅប្រទេស ពិសេសការទៅធ្វើការខុសច្បាប់ ដោយមិនត្រូវជឿតាមការអូសទាញពីមេខ្យល់ ដែលអាចបង្កជាបញ្ហាជាច្រើនដល់ខ្លួនឯង៕

# ថ្ងៃទី០៥ ខែ មេសា ឆ្នាំ២០២៣

## សេចក្តីប្រកាសព័ត៌មាន! ក្រុមប្រតិបត្តិការស៊ើបអង្កេត ស្រាវជ្រាវបណ្តាញនាំមនុស្សឆ្លងដែនខុសច្បាប់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ

http://nokorwatnews.com/archives/984848 04/04/2023

ភ្នំពេញ៖ សេចក្តីប្រកាសព័ត៌មាន! ក្រុមប្រតិបត្តិការស៊ើបអង្កេត ស្រាវជ្រាវ បណ្តាញនាំមនុស្សឆ្លងដែនខុសច្បាប់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ សូមជម្រាបជូនដល់សាធារណជន អំពីលទ្ធផលកិច្ចប្រតិបត្តិការស្វែងរកជនបរទេស ដែលបានស្នើសុំអន្តរាគមន៍ តាមរយៈទំព័រហ្វេសប៊ុកសម្តេចក្រឡាហោម (ករណីលេខ ៧៦៣)។ នេះបេ្ើយោងសេចក្តីប្រកាសព័ត៌មានរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាលពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០២៣។

នៅក្នុងសេចក្តីប្រកាសព័ត៌មានរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបញ្ជាក់ថា៖ នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ ស្ថានទូតឥណ្ឌូនេស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា ស្នើសុំ អន្តរាគមន៍ស្វែងរកពលរដ្ឋរបស់ខ្លួនឈ្មោះ ADITYA FERDIANSYAT ភេទប្រុស កើតថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០១ កាន់លិខិតឆ្លងដែនលេខ E1772988 ដែលសង្ស័យត្រូវបានបង្ខាំងក្នុងទីតាំងមួយកន្លែងស្ថិតនៅ ខេត្តស្វាយរៀង។ នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង បានចុះស្រាវជ្រាវ រកឃើញជនជាតិឥណ្ឌូនេស៊ីខាងលើ កំពុងស្នាក់នៅផ្ទះសំណាក់មួយកន្លែង និងបានស្តាប់ការបំភ្លឺរបស់ សាមីខ្លួនបានឱ្យដឹងថា រូបគេចូលមកប្រទេសកម្ពុជា កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ ក្នុងគោលបំណង ដើម្បីស្វែងរកការងារ ហើយបានចូលធ្វើការរយៈពេល ០១ខែ នៅក្នុងក្រុមហ៊ុនមួយកន្លែង ស្ថិតនៅ រាជធានីភ្នំពេញ រួចបានសុំឈប់ និងរកបានការងារថ្មីនៅខេត្តស្វាយរៀង នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៣ តាមរយៈភ្នាក់ងារស្វែងរកការងារ ដោយមានចុះកិច្ចសន្យាការងាររយៈពេល ០៦ខែ។ អំឡុងពេលធ្វើការ មិនមានការបង្ខាំងបិទសិទ្ធិសេរីភាព ឬធ្វើទារុណកម្មអ្វីឡើយ។ ដោយសារខ្លួនមិនពេញចិត្តនឹងស្ថានភាព ការងារ ទើបមានបំណងចង់លាឈប់ត្រឡប់ទៅប្រទេសកំណើតវិញ ប៉ុន្តែខ្លាចក្រុមហ៊ុនមិនអនុញ្ញាត ព្រោះ ខុសកិច្ចសន្យាការងារ។

នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ រូបគេបានទំនាក់ទំនងទៅក្រុមគ្រួសារឱ្យរាយការណ៍ទៅស្ថានទូត ឥណ្ឌូនេស៊ី ដើម្បីជួយអន្តរាគមន៍។ លុះដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ ក្រុមហ៊ុនបានអនុញ្ញាតឱ្យរូបគ ឈប់ពីការងារ និងចាកចេញពីក្រុមហ៊ុន ហើយខ្លួនក៏បានទៅស្នាក់នៅផ្ទះសំណាក់មួយកន្លែង ស្រាប់តែ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ ក៏មានសមត្ថកិច្ចចុះមកដល់ផ្ទះសំណាក់ស្វែងរកខ្លួន និងអញ្ជើញទៅកន្លែង សមត្ថកិច្ច ដើម្បីសាកសួរ ។ ករណីនេះក្រុមប្រតិបត្តិការមិនបានពិនិត្យឃើញមានសញ្ញាណនៃការបង្ខាំង មនុស្សដោយខុសច្បាប់នោះទេ ផ្ទុយទៅវិញ គឺឈ្មោះ ADITY – FERDIANSY AT មានចេតនាឈប់ពី ការងារ ដោយគេចវេះពីការទទួលខុសត្រូវតាមកិច្ចសន្យាការងាររវាងក្រុមហ៊ុន និងបុគ្គលខ្លួន។

បច្ចុប្បន្នសមត្ថកិច្ចជំនាញបានបញ្ជូនឈ្មោះ ADITYA FERDIANSYAT ទៅកាន់មណ្ឌលត្រៀម បណ្តេញចេញរបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីអនុវត្តនីតិវិធីធ្វើមាតុភូមិនិវត្តន៍៕

## ក្រសួងមហាផ្ទៃ បើកកិច្ចប្រជុំអន្តរក្រសួង ពិភាក្សាដោះស្រាយបញ្ហាពលករចំណាកស្រុក

https://cen.com.kh/archives/642908.html Posted ByPen Srey NeatApril 3, 2023

ភ្នំពេញ : ក្រសួងមហាផ្ទៃ នៅរសៀលថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ បានបើកកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាដោះស្រាយសម្រាប់ពលករដែលបានស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ដោយពុំមានឯកសារ និងហួសសុពលភាព នៃឯកសារច្បាប់អនុញ្ញាត ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អគ្គលេខាធិការ អគ្គលេខាធិការរង អគ្គនាយករង អគ្គស្នងការរង ប្រធាននាយកដ្ឋាននៃក្រសួង-ស្ថាប័នពាក់ព័ន្ធ ព្រមទាំងមន្ត្រីជំនាញ ច្រើនរូបផងដែរ។

លោកជំទាវ ជូ ប៊ុនអេង មានប្រសាសន៍ឱ្យដឹងថា កាលពីពេលថ្មីៗនេះ រាជរដ្ឋាភិបាលថៃ បានដាក់ចេញការអនុញ្ញាតឱ្យពលករណាដែលបានដាក់ពាក្យស្នើសុំស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃ ក្នុងអំឡុងខែកុម្ភៈ ឆ្នាំ២០២៣ នឹងអាចពន្យាសុពលភាព ត្រឹមថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ ករណីហួសពីរយៈពេលនៃការកំណត់នេះ ពលករនិយោជក ទាំងអស់នឹងត្រូវផាកពិន័យ ឬអនុវត្តន៍តាមច្បាប់អន្តោប្រវេសន៍ និងច្បាប់ការងារនៃប្រទេសថៃ។ ក្នុងដំណាក់កាលនេះ អាជ្ញាធរថៃ បានស្នើសុំឱ្យរាជរដ្ឋាភិបាលកម្ពុជាបញ្ជូនក្រុមការងារ ទៅប្រមូលទិន្នន័យ និងផ្តល់អត្តសញ្ញាណជូនពលករកម្ពុជា។

ក្រោយកិច្ចប្រជុំ លោកជំទាវ បានថ្លែងអំណរគុណដល់សមាជិកនៃអង្គប្រជុំដែលមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលបានផ្តល់ធាតុចូលសំខាន់ៗ ដើម្បីដោះស្រាយបញ្ហាពលករដែលកំពុងស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃ ដោយពុំមានឯកសារ និងហួសសុពលភាពនៃឯកសារច្បាប់អនុញ្ញាត ដើម្បីរកដំណោះស្រាយសមស្របមួយដែលមានភាពច្បាស់លាស់ និងអនុវត្តប្រកបដោយប្រសិទ្ធភាព៕ រក្សាសិទ្ធដោយ ៖ សុវណ្ណារិទ្ធ

## សមត្ថកិច្ចកម្ពុជា បន្តទទួលបានបណ្តឹង ៦ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ១១នាក់

https://freshnewsasia.com/index.php/en/localnews/285089-2023-04-04-08-40-05.html 2023-04-04 03:40pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី០២ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៦ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ១១នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៨២៣ករណី មានមនុស្ស ២,០៧៧នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៧៧៨សំណើ និងបិទសំណុំរឿង ២៦៥សំណើ (រកឃើញមនុស្ស ១,២១២នាក់, ឃាត់ខ្លួនជនសង្ស័យ ១២៨នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣៥ករណី៕

# ថ្ងៃទី០៦ ខែ មេសា ឆ្នាំ២០២៣

## ពលករខ្មែរនៅថៃ វិលត្រឡប់ចូលមកកម្ពុជាវិញជាបណ្តើរៗ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី

https://kohsantepheapdaily.com.kh/article/1715461.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ០៤ ខែ មេសា ឆ្នាំ ២០២៣ ម៉ោង ២០:៤៤

ខេត្តបាត់ដំបង ៖ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ជិតចូលមកដល់ គេសង្កេតឃើញថា បងប្អូនពលករខ្មែរ ដែលបានទៅបម្រើការងារនៅក្នុងប្រទេសថៃ ចាប់ផ្តើមវិលត្រឡប់ចូលមកប្រទេសវិញ ជាបណ្តើរៗហើយ តាមច្រកទ្វារអន្តរជាតិនានា ។

របាយការណ៍នៅចំណុចព្រំដែន ក្នុងភូមិសាស្ត្រស្រុកសំពៅលូន នៃខេត្តបាត់ដំបង នាព្រឹកថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣នេះបងប្អូនពលករខ្មែរចំនួន ២២២នាក់ ក្នុងនោះមានស្ត្រីចំនួន ៨៨នាក់ បានចាកចេញពីប្រទេសថៃចូលមកប្រទេសកម្ពុជាវិញដែលចំនួននេះនឹងកើនឡើងជាបន្តបន្ទាប់នៅច្រកទ្វារ តាមបណ្តោយព្រំដែនកម្ពុជា-ថៃ ។

លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង បានធ្វើការណែនាំដល់មន្ត្រីនគរបាលការពារព្រំដែនគោក ត្រូវសហការជាមួយសមត្ថកិច្ចអាជ្ញាធរពាក់ព័ន្ធក្នុងភូមិសាស្ត្រទទួលខុសត្រូវ រៀបចំការទទួលពួកគាត់ឱ្យបានត្រឹមត្រូវ ស្របតាមជំនាញ និងការណែនាំ ដែលបានអនុវត្តនាពេលកន្លងមក ។ ជាមួយគ្នានេះ ត្រូវយកចិត្តទុកដាក់ក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពជូនពួកគាត់ ក្នុងការមកដល់ និងវិលត្រឡប់ទៅកាន់ លំនៅដ្ឋាន ស្រុកកំណើតរបស់គាត់ ប្រកបដោយសុខសុវត្ថិភាព ៕

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិចិន ១នាក់

https://freshnewsasia.com/index.php/en/localnews/285234-2023-04-05-07-47-56.html 2023-04-05 02:47pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី០៣ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិចិន ១នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៨២៧ករណី មានមនុស្ស ២,០៨៤នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៧៨៩សំណើ និងបិទសំណុំរឿង ២៦៥សំណើ (រកឃើញមនុស្ស ១,២១៣នាក់, ឃាត់ខ្លួនជនសង្ស័យ ១២៨នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣៨ករណី៕

# ក្រសួងមហាផ្ទៃបើកកិច្ចប្រជុំអន្តរក្រសួង ពិភាក្សាដោះស្រាយបញ្ហាពលករចំណាកស្រុក

https://www.postkhmer.com/national/2023-04-04-1736-248769.html គឹម យុត្តារ៉ូ | Publication date 04 April 2023 | 17:36 ICT

**ភ្នំពេញៈ** ក្រសួងមហាផ្ទៃ បានបើកកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាដោះស្រាយសម្រាប់ពលករដែលបានស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ដោយពុំមានឯកសារ និងហួសសុពលភាពនៃឯកសារច្បាប់អនុញ្ញាត ក្រោយពីអាជ្ញាធរថៃបានស្នើសុំឱ្យរាជរដ្ឋាភិបាលកម្ពុជាបញ្ជូនក្រុមការងារ ទៅប្រមូលទិន្នន័យ និងផ្តល់អត្តសញ្ញាណជូនពលករកម្ពុជា។

ក្នុងកិច្ចប្រជុំនៅថ្ងៃទី៣ ខែមេសា លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ថ្លែងថា កាលពីពេលថ្មីៗនេះ រាជរដ្ឋាភិបាលថៃ បានដាក់ចេញការអនុញ្ញាតឱ្យពលករណាដែលបានដាក់ពាក្យស្នើសុំស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃ ក្នុងអំឡុងខែកុម្ភៈ ឆ្នាំ២០២៣ នឹងអាចពន្យារសុពលភាព ត្រឹមថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ ។ លោកស្រីបានប្រាប់នៅថ្ងៃទី៤ ខែមេសា ថា ករណីហួសពីរយៈពេលនៃការកំណត់នេះ ពលករ និយោជិត ទាំងអស់នឹងត្រូវផាកពិន័យ ឬអនុវត្តតាមច្បាប់អន្តោប្រវេសន៍ និងច្បាប់ការងារនៃប្រទេសថៃ។ ក្នុងដំណាក់កាលនេះ អាជ្ញាធរថៃ បានស្នើសុំឱ្យរាជរដ្ឋាភិបាលកម្ពុជាបញ្ជូនក្រុមការងារ ទៅប្រមូលទិន្នន័យ និងផ្តល់អត្តសញ្ញាណជូនពលករកម្ពុជា។

លោកស្រី ថ្លែងថា៖ «ចំពោះទិន្នន័យពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃដោយពុំមានឯកសារ និងហួសសុពលភាពនៃឯកសារច្បាប់អនុញ្ញាត មានចំនួនប៉ុន្មាននោះទេ ព្រោះភាគីថៃផ្តល់មកឱ្យកម្ពុជាមិនទាន់ច្បាស់លាស់ដែរ។ ដូច្នេះអ្វីដែលកិច្ចប្រជុំនេះ ធ្វើឡើង ដើម្បីពិភាក្សាស្វែងរកទិន្នន័យ ឱ្យបានច្បាស់លាស់ ដើម្បីរកដំណោះស្រាយសមស្របមួយដែលមានភាពច្បាស់លាស់ និងអនុវត្តប្រកបដោយប្រសិទ្ធភាព»។ លោកស្រីបានបញ្ជាក់ទៀតថា ចំពោះការបញ្ជូនក្រុមការងាររបស់រាជរដ្ឋាភិបាលទៅប្រមូលទិន្នន័យពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃដោយពុំមានឯកសារ និងហួសសុពលភាពនៃឯកសារច្បាប់អនុញ្ញាតនៅក្នុងប្រទេសថៃ ក៏មិនទាន់បានកំណត់ពេលវេលាជាក់លាក់ដែរ ខណៈដែលកន្លងមកក្រុមការងាររបស់រាជរដ្ឋាភិបាលបានទៅធ្វើកិច្ចការងារនេះនៅក្នុងប្រទេសថៃរយៈពេល១ខែដែរ។

លោក អំ សំអាត នាយកទទួលបន្ទុកកិច្ចការទូទៅ នៃអង្គការការពារសិទ្ធិមនុស្សលីកាដូ ថ្លែងថា ការដោះស្រាយបញ្ហាពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃដោយពុំមានឯកសារ និងហួសសុពលភាពនៃឯកសារច្បាប់អនុញ្ញាត គឺជារឿងចាំបាច់ដែលត្រូវធ្វើ ដើម្បីកុំឱ្យមានការរំលោភបំពានការងារលើពួកគេក្នុងប្រការណាមួយ។ លោកបានប្រាប់ថា៖ «ការដោះស្រាយនៅពេលនេះ គឺជារឿងល្អ។ ភាគីកម្ពុជា និងភាគីថៃគួរតែមានកិច្ចសហការសមស្របណាមួយ ដើម្បីធ្វើកិច្ចការងារនេះ ដើម្បីឱ្យពួកគេរស់នៅ និងបម្រើការងារក្នុងប្រទេសថៃស្របច្បាប់ និងបញ្ចៀសបាននូវការរំលោភបំពានពលកម្ម និងមានការការពារស្របទៅតាមច្បាប់ជូនពួកគេ នៅក្នុងប្រទេសថៃ»។

យោងតាមរបាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីឆ្នាំ ២០២២ បង្ហាញថាពលករកម្ពុជាដែលកំពុងស្នាក់នៅ និងបម្រើការងារនៅក្នុងប្រទេសថៃមានចំនួន ១,២លាននាក់ លើផ្នែកសំណង់ កសិកម្ម បេះផ្លែឈើ និងឧស្សាហកម្មជាដើម៕

# ឯកអគ្គរាជទូតអង់គ្លេសសរសើរកម្ពុជា
# ខិតខំប្រយុទ្ធប្រឆាំងការសម្អាតប្រាក់ រហូតដកចេញពីបញ្ជីប្រផេះ

https://btv.com.kh/article/21945 2023/04/05 03:12:06 pm

ភ្នំពេញ៖ ឯកឧត្តម Dominic William ឯកអគ្គរាជទូតចក្រភពអង់គ្លេសប្រចាំនៅកម្ពុជា បានកោតសរសើរ និង វាយតម្លៃខ្ពស់ចំពោះប្រទេសកម្ពុជា ដែលបានខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំង នឹងការសម្អាតប្រាក់ រហូត ត្រូវបាន ដកចេញពីបញ្ជីប្រផេះ នៃប្រទេសមានហានិភ័យក្នុងការសម្អាតប្រាក់ ។ ការថ្លែងបែបនេះ ធ្វើឡើងក្នុងជំនួប និង ពិភាក្សាការងារជាមួយសម្តេចក្រឡាហោម ស ខេង ឧបនាយកនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៣នេះ នាវិមានសន្តិភាព ។

ឯកឧត្តមអគ្គរដ្ឋទូត លើកឡើងថា ប្រទេសកម្ពុជាចូលរួមជាមួយ ប្រទេសជាសមាជិកអាស៊ាន ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន តាមរយៈការអនុវត្តនូវយន្តការផ្សេងៗ ជាពិសេសពាក់ព័ន្ធទៅនឹងការជួញដូរមនុស្ស ហើយសមិទ្ធផលទាំងនេះ ក៏ជាការបង្ហាញអំពីការប្តេជ្ញាចិត្ត និងឆន្ទៈរបស់អង់គ្លេស ក្នុងការរួមចំណែករក្សានូវសន្តិសុខល្អនៅក្នុងតំបន់ ។

ក្នុងឱកាសនោះ សម្តេចក្រឡាហោម មានប្រសាសន៍ថា ទោះកម្ពុជាត្រូវបានដកចេញពីបញ្ជីប្រផេះ នៃប្រទេសមានហានិភ័យក្នុងការសម្អាតប្រាក់ ប៉ុន្តែកម្ពុជានៅបន្តខិតខំលើការងារនេះបន្ថែមទៀត និងបន្តដោះស្រាយបញ្ហានានា ដែលនៅសេសសល់ ពាក់ព័ន្ធទៅនឹងការងាររៀបចំការសម្អាតប្រាក់ ។ សម្តេចបន្ថែមថា ចំពោះការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនក៏ដូចគ្នា គឺរាជរដ្ឋាភិបាលកម្ពុជា មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការប្រយុទ្ធប្រឆាំង ទៅនឹងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ជាពិសេស គឺបទល្មើសពាក់ព័ន្ធទៅនឹងការជួញដូរមនុស្ស និងគ្រឿងញៀនខុសច្បាប់ ដែលបញ្ហានេះ គឺជាបញ្ហាមួយមានភាពស្មុគស្មាញ ហើយកម្ពុជាត្រូវតែបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីដោះស្រាយបញ្ហាធំៗទាំងនេះ ។

សម្តេចក្រឡាហោម បានសង្កត់ធ្ងន់ថា ការងារប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ជាពិសេស បទល្មើសប្រឆាំងការជួញដូរមនុស្ស កម្ពុជាតែឯងមិនអាចធ្វើបាននោះទេ គឺទាមទារចាំបាច់ នៃកិច្ចសហប្រតិបត្តិការទាំងក្នុងកម្រិតតំបន់ និងសកលលោក ដើម្បីរួមសហការគ្នាធ្វើការស្រាវជ្រាវផ្តន្ទាទោស ដល់អ្នកពាក់ព័ន្ធក៏ដូចជាមេក្លោងក្នុងបទល្មើសទាំងនេះ ដែលមានវត្តមានក្នុងប្រទេសរបស់ខ្លួន ។ ជាមួយនេះរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានបំណងឲ្យមានកិច្ចសហប្រតិបត្តិការ ឱ្យកាន់តែខ្លាំងក្លាថែមទៀត ក៏ដូចជាស្នើឲ្យមានការចែករំលែកបទពិសោធ នៃការអនុវត្តល្អៗរបស់ចក្រភពអង់គ្លេស ក្នុងការពង្រឹង និងលើកកម្ពស់សមត្ថភាពកងកម្លាំងអនុវត្តច្បាប់ របស់កម្ពុជាឱ្យកាន់តែខ្លាំងក្លាថែមទៀត នៅក្នុងការងារប្រយុទ្ធប្រឆាំងទៅឧក្រិដ្ឋកម្មឆ្លងដែន ។

គួរបញ្ជាក់ថា កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣ កម្ពុជា ត្រូវបានអង្គការឃ្លាំមើលអំពើលាងលុយកខ្វក់លើពិភពលោក (FATF) មានមូលដ្ឋាននៅទីក្រុងប៉ារីស ប្រទេសបារាំង បានដកកម្ពុជាចេញពីបញ្ជីប្រផេះ នៃប្រទេសលាងលុយកខ្វក់ ៕ អត្ថបទ បាន សុខរិទ្ធិ

## តុលាការកំពូល បដិសេធពាក្យសុំនៅស្ថិតក្រៅឃុំ របស់បុរសចិនជាប់ចោទម្នាក់ ជាប់ពាក់ព័ន្ធនឹង បទល្មើស លក់ដូរមនុស្ស និង កាន់កាប់អាវុធគ្រាប់រំសេវដោយគ្មានការអនុញ្ញាត

https://cen.com.kh/archives/644001.html Posted ByPen Srey NeatApril 5, 2023

ភ្នំពេញ: តុលាការកំពូលកាលពីព្រឹក ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០២៣ នេះ បានប្រកាសសាលដីកាបដិសេធ លើកបណ្តឹងសាទុក្ខ ស្នើសុំស្ថិតនៅក្រៅឃុំបណ្តោះអាសន្ន របស់ជនជាប់ចោទ ជនជាតិចិនម្នាក់ ដែលត្រូវបានតុលាការថ្នាក់ក្រោម ចាប់ខ្លួនដាក់គុក បណ្តោះអាសន្ន ជាប់ពាក់ព័ន្ធនឹងការ អំពើលក់ដូរមនុស្ស និង កាន់កាប់អាវុធគ្រាប់រំសេវដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅក្រុម២៧ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលកាលពី អំឡុង ខែមិថុនា ឆ្នាំ ២០២២ ។

លោក សឹង បញ្ញាវុឌ្ឍ ជាប្រធានចៅក្រមជំនុំជម្រះនៃ តុលាការកំពូល បានឲ្យដឹងថា ជនជាប់ចោទមានឈ្មោះ ZHANG RUN BIN ភេទប្រុស អាយុ ៤៦ ឆ្នាំ North Carolina ជនជាតិចិន ។ នៅក្នុងសំណុំរឿងក្តីនេះ សាលាដំបូងខេត្តព្រះសីហនុ កាលពីថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០២២ បានបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន ពីបទ: អំពើលក់ដូរមនុស្ស និង កាន់កាប់នូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវដោយគ្មានការអនុញ្ញាត តាមមាត្រា ១៥ នៃច្បាប់ស្តីពីការ បង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ និង មាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេ។

ជនជាប់ចោទបាន ប្តឹងឧទ្ធរណ៍ តែសាលាឧទ្ធរណ៍ព្រះសីហនុ បានតម្កល់ទណ្ឌកម្មរបស់គាត់រក្សាទុកជាបានការដដែល មិនឲ្យនៅក្រៅឃុំ ។ ជនជាប់ចោទ ក៏បានបន្តប្តឹងសាទុក្ខ មកកាន់តុលាការកំពូលទៀត។ ជនជាប់ចោទ ត្រូវបានចាប់ឃាត់ខ្លួន កាលពីថ្ងៃទី១៣ ខែ កញ្ញា ឆ្នាំ ២០២២ នៅ ក្រុម២៧ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ៕ រក្សាសិទ្ធដោយ ៖ ចន្ទា ភា

# ថ្ងៃទី០៧ ខែ មេសា ឆ្នាំ២០២៣

## រាជរដ្ឋាភិបាលកម្ពុជា
## មានការប្តេជ្ញាចិត្តខ្ពស់ ក្នុងការប្រយុទ្ធប្រឆាំងទៅនឹងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ជាពិសេសគឺបទល្មើសពាក់ព័ន្ធទៅនឹងការជួញដូរមនុស្ស និងគ្រឿងញៀនខុសច្បាប់

https://cen.com.kh/archives/644146.html Posted ByPen Srey NeatApril 5, 2023

ភ្នំពេញ : សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នាថ្ងៃទី០៥ ខែមេសា ឆ្នាំ ២០២៣ បានអនុញ្ញាតឱ្យឯកឧត្តម Dominic Williams ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃចក្រភពអង់គ្លេស ទើបតែងតាំងថ្មី ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម។

ក្នុងឱកាសនោះ សម្តេចក្រឡាហោម ស ខេង បានសម្តែងនូវការស្វាគមន៍ចំពោះឯកឧត្តម ដែលត្រូវបានតែងតាំងជា ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព ប្រចាំព្រះរាជាណាចក្រកម្ពុជា។ សម្តេចក្រឡាហោម ក៏បានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការរវាងចក្រភពអង់គ្លេស ជាមួយក្រសួងមហាផ្ទៃ នៅលើវិស័យនានាដែលក្រសួងមហាផ្ទៃ ទទួលខុសត្រូវផងដែរ។ ជាមួយគ្នានេះ សម្តេចក្រឡាហោម សង្ឃឹមជឿជាក់ថា តាមរយៈអាណត្តិបេសកម្មការទូតរបស់ឯកឧត្តម នៅកម្ពុជានឹងបន្តពង្រឹងពង្រីកនូវកិច្ចសហប្រតិបត្តិការទំនាក់ទំនងរវាងប្រទេសទាំងពីរក៏ដូចជា ក្រសួងមហាផ្ទៃកាន់តែរីកចម្រើនលូតលាស់ថែមទៀត។

ជាការឆ្លើយតប ឯកឧត្តម ឯកអគ្គរាជទូត បានវាយតម្លៃខ្ពស់ចំពោះកិច្ចទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រទេសទាំងពីរ ក្នុងនោះដែរ ក៏មានទំនាក់ទំនងដ៏ល្អជាមួយក្រសួងមហាផ្ទៃ ទៅលើវិស័យការងារពាក់ព័ន្ធ រួមទាំងការងារសហប្រតិបត្តិការល្អពាក់ព័ន្ធទៅនឹងការងារអគ្គកុងស៊ុលផងដែរ។ ឯកឧត្តម ឯកអគ្គរាជទូត សូមយកឱកាសនេះ សម្តែងនូវការអបអរសាទរចំពោះ រាជរដ្ឋាភិបាលកម្ពុជា ដែលទទួលធ្វើជាប្រធានអាស៊ានប្រកបដោយជោគជ័យ កាលពីឆ្នាំ២០២២ កន្លងទៅ ហើយ ឯកឧត្តម បានចាត់ទុកថា ភាពជោគជ័យរបស់កិច្ចប្រជុំកំពូលអាស៊ាននេះដែរ គឺជាការរួមចំណែកមួយយ៉ាងសំខាន់របស់ សម្តេចក្រឡាហោម ស ខេង ក៏ដូចជា ក្រសួងមហាផ្ទៃ ដែលទទួលបន្ទុកកិច្ចការងារស្នូលក្នុងការធានាថែរក្សាសុខសុវត្ថិភាពបានល្អប្រសើរ សម្រាប់ព្រឹត្តិការណ៍អន្តរជាតិដ៏មានសារៈសំខាន់នេះ។

ជាមួយគ្នាដែរ ឯកឧត្តម ឯកអគ្គរាជទូត ក៏បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការងារប្រយុទ្ធប្រឆាំងការសម្អាតប្រាក់ ដែលធ្វើឱ្យកម្ពុជា ត្រូវបានដកចេញពីបញ្ជីប្រផេះ នៃប្រទេសមានហានិភ័យ ក្នុងការសម្អាតប្រាក់ ដែលការងារនេះគឺមានសម្តេចក្រឡាហោម ស ខេង ជាអ្នកដឹកនាំផ្ទាល់ផងដែរ។ ទន្ទឹមនេះ ឯកឧត្តម ក៏បានសម្តែងនូវសេចក្តីរីករាយដែលបានចូលរួមចំណែក ជាមួយនឹងបណ្តាប្រទេសជាសមាជិកអាស៊ានក្នុងការអនុវត្តនូវយន្តការនានា ក្នុងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ជាពិសេសពាក់ព័ន្ធទៅនឹងការជួញដូរមនុស្ស។ ឯកឧត្តម បានចាត់ទុកថា សមិទ្ធផលការងារដូចបានបញ្ជាក់មកនេះ គឺជាការបង្ហាញអំពីការប្តេជ្ញាចិត្ត និងឆន្ទៈរបស់ចក្រភពអង់គ្លេស ក្នុងការរួមចំណែករក្សានូវសន្តិសុខល្អនៅក្នុងតំបន់។

ជាថ្មីម្តងទៀត សម្តេចក្រឡាហោម ស ខេង បានថ្លែងអំណរគុណ ឯកឧត្តម ឯកអគ្គរាជទូត និងការវាយតម្លៃមកលើតួនាទីរបស់កម្ពុជា ក្នុងការធ្វើជាប្រធានអាស៊ានឆ្នាំ២០២២ កន្លងទៅ។ តាមរយៈ ឯកឧត្តម ឯកអគ្គរាជទូត នាឱកាសនេះ សម្តេច ក៏សូមថ្លែងអំណរគុណចំពោះចក្រភពអង់គ្លេស ដែលបានចាត់ថ្នាក់ដឹកនាំជាន់ខ្ពស់ចូលរួមក្នុងព្រឹត្តិការណ៍នៃកិច្ចប្រជុំកំពូលអាស៊ាននៅកម្ពុជានេះ។ សម្តេចក្រឡាហោម បានចាត់ទុកថា ជោគជ័យនៃកិច្ចប្រជុំកំពូលអាស៊ាន គឺមិនត្រឹមតែជាជោគជ័យរបស់កម្ពុជានោះទេ ក៏ប៉ុន្តែជាជោគជ័យរបស់បណ្តាប្រទេសក្នុងតំបន់ ក៏ដូចជាសកលលោកទាំងមូលផងដែរ។

ទន្ទឹមនេះ សម្តេចក្រឡាហោម ក៏បានមានប្រសាសន៍បន្ថែមថា ទោះបីជាទទួលបានលទ្ធផលល្អប្រសើរយ៉ាងនេះក្តី ក៏ប៉ុន្តែកម្ពុជានៅតែបន្តខិតខំលើការងារនេះបន្ថែមទៀត និងបន្តដោះស្រាយបញ្ហានានា ដែលនៅសេសសល់ពាក់ព័ន្ធទៅនឹងការងាររៀបចំការសម្អាតប្រាក់នេះ។ ចំពោះការងារប្រយុទ្ធប្រឆាំងទៅនឹងឧក្រិដ្ឋកម្មឆ្លងដែនក៏ដូចគ្នាដែរ សម្តេចក្រឡាហោម បានជម្រាបជូនថា រាជរដ្ឋាភិបាលកម្ពុជា មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការប្រយុទ្ធប្រឆាំងទៅនឹងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ជាពិសេសគឺបទល្មើសពាក់ព័ន្ធទៅនឹងការជួញដូរមនុស្ស និងគ្រឿងញៀនខុសច្បាប់ ដែលបញ្ហានេះ គឺជាបញ្ហាមួយមានភាពស្មុគស្មាញ ហើយដែលកម្ពុជាត្រូវតែបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយបញ្ហាធំៗទាំងនេះ។

សម្តេចក្រឡាហោម ក៏បានសង្កត់ធ្ងន់ថា ការងារប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ជាពិសេសគឺបទល្មើសប្រឆាំងការជួញដូរមនុស្ស កម្ពុជាតែឯងមិនអាចធ្វើបាននោះទេ គឺទាមទារជាចាំបាច់នូវកិច្ចសហប្រតិបត្តិការទាំងក្នុងកម្រិតតំបន់ និងសកលលោក ដើម្បីរួមសហការគ្នាធ្វើការស្រាវជ្រាវផ្តន្ទាទោសដល់អ្នកពាក់ព័ន្ធ ក៏ដូចជាមេក្លោង ក្នុងបទល្មើសទាំងនេះដែលមានវត្តមានក្នុងប្រទេសរបស់ខ្លួន។ សម្តេចក្រឡាហោម ក៏សូមយកឱកាសនេះសម្តែងនូវគោលបំណងឱ្យមានកិច្ចសហប្រតិបត្តិការឱ្យកាន់តែខ្លាំងក្លាថែមទៀត និងបានស្នើឱ្យមានការចែករំលែកផ្លាស់ប្តូរបទពិសោធក៏ ដូចជាការអនុវត្តល្អៗរបស់ចក្រភពអង់គ្លេស ក្នុងការពង្រឹង និងលើកកម្ពស់សមត្ថភាពកងកម្លាំងអនុវត្តច្បាប់របស់កម្ពុជាឱ្យកាន់តែខ្លាំងក្លាថែមទៀតនៅក្នុងការងារប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន។

នាឱកាសនោះ សម្តេចក្រឡាហោម ស ខេង និងឯកឧត្តមអគ្គរាជទូតចក្រភពអង់គ្លេស ក៏បានពិភាក្សាផ្លាស់ប្តូរយោបល់លើការងារមួយចំនួនបន្ថែមទៀត ដែលរួមមានដូចជា៖ ដំណើរការត្រៀមលក្ខណៈសម្រាប់ដំណើរការរៀបចំការបោះឆ្នោតដែលនឹងប្រព្រឹត្តទៅនៅក្នុងខែកក្កដា ឆ្នាំ២០២៣ខាងមុខនេះ, ការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុងដំណើរការអភិវឌ្ឍសង្គមជាតិ, ការពង្រឹងពង្រីកនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការគាំទ្រគ្នាទៅវិញទៅមកលើការងារកុងស៊ុល ជាពិសេសពាក់ព័ន្ធទៅនឹងពលរដ្ឋនៃចក្រភពអង់គ្លេស ដែលរស់នៅព្រះរាជាណាចក្រកម្ពុជា៕រក្សាសិទ្ធិដោយៈសុវណ្ណារិទ្ធ

## ប្រជាពលរដ្ឋដែលទៅបម្រើការងារនៅប្រទេសថៃ ចាប់ផ្តើមវិលត្រឡប់មកចូលរួមសប្បាយរីករាយក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរនៅថ្ងៃខាង មុខ

https://www.gdlf-kh.com/2023/04/05/-2/ Vicheka ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅសល់តែប៉ុន្មានថ្ងៃទៀតតែប៉ុណ្ណោះ បុណ្យចូល ឆ្នាំថ្មីប្រពៃណីជាតិខ្មែរឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ និងចូលមកដល់ ជាមួយនេះបានកត់សម្គាល់ឃើញ ថា បងប្អូនប្រជាពលរដ្ឋ ដែលបានទៅបំពេញការងារនៅព្រះរាជាណាចក្រថៃ បានអញ្ជើញ វិលត្រឡប់មកចូលរួមសប្បាយរីករាយក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ។ តាមរបាយការណ៍ពីចំណុចព្រំដែននៃភូមិសាស្ត្រស្រុកសំពៅលូន ខេត្តបាត់ដំបង នាព្រឹកថ្ងៃទី ៥ ខែមេសា ឆ្នាំ ២០២៣ នេះបងប្អូនប្រជាពលរដ្ឋ ចំនួន ៣៣៣នាក់ ស្រី១៣៤នាក់ ក្មេង៥នាក់ បានអញ្ជើញចាកចេញ ពីប្រទេសថៃ ចូលមកប្រទេសកម្ពុជា ហើយដែលចំនួននេះនឹងកើនឡើងជាបន្ត បន្ទាប់ នៅតាមចំណុចព្រំដែនជាប់នឹងប្រទេសថៃ។

ពិនិត្យលើទិដ្ឋភាពនេះ លោកឧត្តមសេនីយ៍ទោ សាត គីមសាន ស្នងការនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង បានធ្វើការណែនាំដល់មន្ត្រីនគរបាលនៅមូលដ្ឋានទាំងនគរបាលវរសេនាតូចការពារព្រំដែនគោក និងនគរបាលនៃអធិការដ្ឋាននគរបាលស្រុកពាក់ព័ន្ធ ត្រូវសហការជាមួយសមត្ថកិច្ចអាជ្ញាធរពាក់ព័ន្ធ នៅភូមិសាស្ត្រទទួលខុសត្រូវ រៀបចំការទទួលពួកគាត់ឱ្យបានត្រឹមត្រូវស្របតាមជំនាញនិងការណែនាំដែលបានអនុវត្តនាពេលកន្លងមកហើយជាមួយនេះត្រូវយកចិត្តទុកដាក់ក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពជូនពួកគាត់ ក្នុងការមកដល់និងវិលត្រឡប់ទៅកាន់ លំនៅដ្ឋាន ស្រុកកំណើតរបស់គាត់បានប្រកបដោយសុខសុវត្ថិភាព ៕

## ក្រសួងយុត្តិធម៌បណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ ដើម្បីពង្រឹងកិច្ចការពារជនរងគ្រោះក្នុងសំណុំរឿងជួញដូរមនុស្ស

https://www.postkhmer.com/national/2023-04-06-0905-248829.html ជា សុខនី | Publication date 06 April 2023 | 09:05 ICT

ព្រះសីហនុៈ ក្រសួងយុត្តិធម៌បើកកម្មវិធីបណ្តុះបណ្តាលរយៈពេល ៣ ថ្ងៃ ស្តីពីសំណុំរឿងជួញដូរមនុស្ស ទៅដល់ព្រះរាជអាជ្ញាចៅក្រមស៊ើបសួរ និងមន្ត្រីអនុវត្តច្បាប់ដទៃទៀត ក្នុងគោលបំណងផ្តល់ចំណេះដឹង ដើម្បីការពារជនរងគ្រោះ និងជំនាញទំនាក់ទំនងរវាងជនរងគ្រោះ និងព្រះរាជអាជ្ញាមុនសវនាការ។ នេះបើយោងតាមការចុះផ្សាយរបស់ក្រសួងយុត្តិធម៌ កាលពីថ្ងៃទី ៤ ខែមេសា។

កម្មវិធីបណ្តុះបណ្តាលនេះ ធ្វើឡើងរយៈពេល ៣ ថ្ងៃ ចាប់ពីថ្ងៃទី ៤ រហូតដល់ថ្ងៃទី ៦ ខែមេសា នៅសណ្ឋាគារឯករាជ្យ ខេត្តព្រះសីហនុ ក្រោមកិច្ចសហការពីបណ្ឌិតសភាភូមិន្ទយុត្តិធម៌កម្ពុជា និងកម្មវិធីអាស៊ាន អូស្ត្រាលីប្រឆាំងការជួញដូរមនុស្សប្រចាំកម្ពុជា (ASEAN-ACT)។ កម្មវិធីនេះធ្វើឡើងក្នុងគោលបំណងដើម្បីផ្តល់

ចំណេះដឹង និងជំនាញសំខាន់ៗ ពាក់ព័ន្ធនឹងការចូលរួមរបស់ជនរងគ្រោះ ធ្វើជាសាក្សីក្នុងកិច្ចការពារជនរងគ្រោះជាសាក្សី និងទំនាក់ទំនងរវាងជនរងគ្រោះ និងព្រះរាជអាជ្ញាមុនសវនាការ។

អ្នកនាំពាក្យក្រសួងយុត្តិធម៌ លោក ជិន ម៉ាលីន បានថ្លែងថា ជាគោលដៅរបស់ក្រសួងគឺយកការអភិវឌ្ឍធនធានមនុស្សនេះជារឿងអាទិភាព ដើម្បីជំរុញទៅដល់ មន្ត្រីអនុវត្តច្បាប់ឱ្យធ្វើការប្រកបដោយប្រសិទ្ធភាព។ ក្រៅពីការជួញដូរមនុស្ស ក្រសួងយុត្តិធម៌ក៏បើកបណ្ដុះបណ្ដាលកម្មវិធីផ្សេងទៀតជាច្រើនដោយរៀបចំជាប្រចាំ សម្រាប់មន្ត្រីអនុវត្តច្បាប់ ដោយសារសង្គមមានការវិវឌ្ឍ និងមានការរីកចម្រើនជាប់ជាប្រចាំ។ លោក ជិន ម៉ាលីន ថា៖« អ៊ីចឹងការដុសខាត់ ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ក៏ត្រូវធ្វើជាប់ជាប្រចាំផងដែរ ដើម្បីឆ្លើយតបទៅនឹងការវិវឌ្ឍនៃសង្គម»។

អ្នកនាំពាក្យសមាគមការពារសិទ្ធិមនុស្សអាដហុក លោក ស៊ឹង សែនករុណា បានកត់សម្គាល់ថា ករណីការជួញដូរមនុស្ស មានបញ្ហាចម្បង ២ ចំណុចដែលកាលពីមុន ករណីជួញដូរមនុស្សបានកើតឡើងតែទៅលើប្រជាពលរដ្ឋកម្ពុជាទេ ដែលត្រូវបានជនល្មើសធ្វើការជួញដូរកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ទៅក្រៅប្រទេសជាដើម តាមរយៈរូបភាពផ្សេងៗដូចជា៖ តាមរយៈមេខ្យល់ឆបោក តាមរយៈការរៀបអាពាហ៍ពិពាហ៍ជាដើម។ ប៉ុន្តែឥឡូវនេះលោកមើលឃើញរូបភាពថ្មីមួយទៀត គឺការជួញដូរកម្លាំងពលកម្មបរទេសដែលចូលមកធ្វើកិច្ចការងារនៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅតាមក្រុមហ៊ុនល្បែងអនឡាញមួយចំនួន ដែលមានការបង្ក្រាបពីក្រសួងមហាផ្ទៃបានជាច្រើនករណី។ លោក ស៊ឹង សែនករុណា ថា៖ «អ៊ីចឹងអាហ្នឹង គឺជាអ្វីដែលខ្ញុំមានការកត់សម្គាល់ ក៏ប៉ុន្តែកិច្ចការងារដែលសំខាន់បំផុតនោះគឺយើងចង់ឃើញសមត្ថកិច្ចដែលអនុវត្តច្បាប់ តួនាទីរបស់ក្រុមអ្នកអនុវត្តច្បាប់ ដែលគួរតែប្រកាន់នូវជំហរ និងការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ ហើយនិងមានប្រសិទ្ធភាព អានោះគឺជាអ្វីដែលអាចទប់ស្កាត់ករណីជួញដូរមនុស្សឱ្យបានប្រសើរជាងមុន»។

ក្រសួងយុត្តិធម៌លើកឡើងថា កម្មវិធីបណ្ដុះបណ្ដាលលើកនេះ មានការចូលរួមពីសំណាក់លោក សម ប៊ុនថុន ប្រធានសាលាឧទ្ធរណ៍បាត់ដំបង លោក វង្ស ប៊ុនវិសុទ្ធ ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តកំពង់ចាម លោក រស់ សារាំ ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តកោះកុង និងរួមទាំងក្រុមគ្រូបង្គោលនៃកម្មវិធីជំនាញអាស៊ានស្ដីពីការជួញដូរមនុស្ស ព្រមទាំងចៅក្រម ព្រះរាជអាជ្ញារងតំណាងសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកំពត កែប ព្រះសីហនុ និងខេត្តកោះកុង៕

## កម្ពុជាស្នើអង់គ្លេស
## ចែករំលែកបទពិសោធន៍ក្នុងការពង្រឹងសមត្ថភាពប្រយុទ្ធឧក្រិដ្ឋកម្មឆ្លងដែន

https://www.postkhmer.com/national/2023-04-05-1726-248811.html សុខ វេស្សា | Publication date 05 April 2023 | 17:26 ICT

**ភ្នំពេញ:** កម្ពុជាបានស្នើចក្រភពអង់គ្លេសចែករំលែកបទពិសោធន៍ក៏ដូចជាការអនុវត្តល្អៗដល់កម្ពុជាក្នុងការពង្រឹង និងលើកកម្ពស់សមត្ថភាពកងកម្លាំងអនុវត្តច្បាប់ឱ្យកាន់តែខ្លាំងថែមដើម្បីត្រៀមខ្លួនប្រយុទ្ធប្រឆាំងទៅនឹងឧក្រិដ្ឋកម្មឆ្លងដែន ជាពិសេសបទល្មើសប្រឆាំងការជួញដូរមនុស្ស ។

សំណើនេះត្រូវបានលើកឡើងក្នុងជំនួបរវាងលោកឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលបានអនុញ្ញាតជូនលោកDominic William ឯកអគ្គរាជទូតចក្រភពអង់គ្លេសប្រចាំកម្ពុជាដែលទើបតែងតាំងថ្មី ចូលជួបសម្ដែងការគួរសមនៅវិមានសន្តិភាព នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៣។ លោកស ខេង បានបង្ហោះនៅលើហ្វេសប៊ុករបស់លោកស្ដីពីជំនួបនោះ ដោយបានអបអរសាទរចំពោះកិច្ចសហប្រតិបត្តិការរវាងភាគីទាំង២ព្រមទាំងវាយ

តម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការរវាងចក្រភពអង់គ្លេសជាមួយក្រសួងមហាផ្ទៃកម្ពុជាលើវិស័យនានាដែលក្រសួងមហាផ្ទៃទទួលខុសត្រូវ។

ជាមួយគ្នានេះដែរ តាមរយៈអាណត្តិបេសកកម្មការទូតរបស់លោក Dominic William នៅកម្ពុជា លោកស ខេង សង្ឃឹមថា នឹងបន្តពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងរវាងប្រទេសទាំង២ក៏ដូចជាជាមួយនឹងក្រសួងមហាផ្ទៃកាន់តែរីកចម្រើនលូតលាស់ថែមទៀត។ ប្រភពដដែលបញ្ជាក់ថា៖«សម្តេចក៏សុំយកឱកាសនេះសម្តែងនូវបំណងឱ្យមានកិច្ចសហប្រតិបត្តិការឱ្យកាន់តែខ្លាំងក្លាថែមទៀត ក៏ដូចជាស្នើឱ្យមានការចែករំលែកបទពិសោធន៍ក៏ដូចជាការអនុវត្តល្អៗរបស់ចក្រភពអង់គ្លេស ក្នុងការពង្រឹង និងលើកកម្ពស់សមត្ថភាពកងកម្លាំងអនុវត្តច្បាប់របស់កម្ពុជាឱ្យកាន់តែខ្លាំងក្លាថែមទៀតនៅក្នុងការងារប្រយុទ្ធប្រឆាំងទៅឧក្រិដ្ឋកម្មឆ្លងដែន»។

ប្រភពបានបន្តទៀតថា ជាការឆ្លើយតបលោកDominic William បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រទេសទាំង២កម្ពុជា និងចក្រភពអង់គ្លេស ដែលក្នុងនោះក៏មានទំនាក់ទំនងដ៏ល្អជាមួយក្រសួងមហាផ្ទៃលើវិស័យការងារពាក់ព័ន្ធ រួមទាំងកិច្ចសហប្រតិបត្តិការល្អពាក់ព័ន្ធនឹងកិច្ចការកុងស៊ុលផងដែរ។ ជាមួយគ្នានេះ លោកDominic ក៏វាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ជាពិសេសកោតសរសើរលោក ស ខេង ដែលបានដឹកនាំផ្ទាល់ខិតខំប្រឹងប្រែងក្នុងការងារប្រយុទ្ធប្រឆាំងការសម្អាតប្រាក់ធ្វើឱ្យកម្ពុជា ត្រូវបានដកចេញពីបញ្ជីប្រផេះនៃប្រទេសមានហានិភ័យក្នុងការសម្អាតប្រាក់។ ប្រភពខាងលើបញ្ជាក់ថា៖«ការងារពាក់ព័ន្ធទៅនឹងការងារប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ឯកឧត្តម Dominic ក៏សម្តែងនូវសេចក្តីរីករាយដែលបានចូលរួមចំណែក ជាមួយនឹងបណ្តាប្រទេសសមាជិកអាស៊ានក្នុងការអនុវត្តនូវយន្តការនានាក្នុងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ជាពិសេសពាក់ព័ន្ធទៅនឹងការជួញដូរមនុស្ស។ ឯកឧត្តមចាត់ទុកថា សមិទ្ធផលការងារដូចបានបញ្ជាក់មកនេះ គឺជាការបង្ហាញអំពីការប្តេជ្ញាចិត្ត និងឆន្ទៈរបស់ចក្រភពអង់គ្លេសក្នុងការរួមចំណែករក្សានូវសន្តិសុខល្អនៅក្នុងតំបន់»។

លោក ស ខេង បានយកឱកាសនេះថ្លែងអំណរគុណចំពោះលោកDominicដែលបានវាយតម្លៃទៅលើកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងបទល្មើសសម្អាតប្រាក់ ដែលធ្វើឱ្យកម្ពុជាត្រូវបានដកចេញពីបញ្ជីប្រផេះ។ លោកស ខេង ថ្លែងថា៖«រាជរដ្ឋាភិបាលកម្ពុជាមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការប្រយុទ្ធប្រឆាំងទៅនឹងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ជាពិសេសគឺបទល្មើសពាក់ព័ន្ធទៅនឹងការជួញដូរមនុស្ស និងគ្រឿងញៀនខុសច្បាប់ដែលបញ្ហានេះ គឺជាបញ្ហាមួយមានភាពស្មុគស្មាញ ហើយដែលកម្ពុជាត្រូវតែបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយបញ្ហាធំៗទាំងនេះ»។ លោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានសង្កត់ធ្ងន់ថា ការងារប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ជាពិសេសគឺបទល្មើសប្រឆាំងការជួញដូរមនុស្សកម្ពុជាតែឯងមិនអាចធ្វើបាននោះទេ គឺទាមទារជាចាំបាច់នៃកិច្ចសហប្រតិបត្តិការទាំងក្នុងកម្រិតតំបន់ និងសកលលោកដើម្បីរួមសហការគ្នាស្រាវជ្រាវផ្តន្ទាទោសដល់អ្នកពាក់ព័ន្ធក៏ដូចជាមេខ្លោងក្នុងបទល្មើសទាំងនេះ ៕

## មន្ត្រីជាន់ខ្ពស់ក្រសួងសង្គមកិច្ច៖ អំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មលើមនុស្ស បានកើតឡើង និងកំពុងរីកសាយភាយគ្រប់ទីកន្លែង គ្រប់រូបភាព ភាគច្រើនជាឧក្រិដ្ឋកម្មឆ្លងដែន

https://freshnewsasia.com/index.php/en/localnews/285416-2023-04-06-13-38-20.html 2023-04-06 08:38pm

**(ភ្នំពេញ)៖** លោក ញឹក វណ្ណារ៉ា រដ្ឋលេខាធិការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានថ្លែងបញ្ជាក់ថា អំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មលើមនុស្សបានកើតឡើង និងកំពុងរីកសាយភាយគ្រប់ទីកន្លែងគ្រប់រូបភាព ហើយភាគច្រើនជាឧក្រិដ្ឋកម្មឆ្លងដែន ដែលមានអង្គការចាត់តាំង ហើយឧក្រិដ្ឋកម្មនេះបានធ្វើឲ្យ

ប៉ះពាល់ទាំងថ្នាក់ជាតិ តំបន់ និងលើពិភពលោក ។ លោកបានបន្ថែមថា បញ្ហានេះប្រទេសកម្ពុជាបាននឹងកំពុងបង្កើតរៀបចំចង់ក្រងផ្សព្វផ្សាយ អនុវត្តគោលនយោបាយផែនការយុទ្ធសាស្រ្ត កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងយន្តការនានាសំដៅប្រយុទ្ធប្រឆាំង និងចូលរួមកាត់បន្ថយឲ្យបានជាអតិបរិមានូវអំពើជួញដូរមនុស្សទាំងក្នុងក្របខ័ណ្ឌជាតិ តំបន់ និងលើពិភពលោក ពិសេសជាងនោះទៅទៀត សព្វថ្ងៃនេះជនរងគ្រោះក៏បាន និងកំពុងតែកើតមាននៅក្នុងប្រទេសគោលដៅផងដែរ ដូចជាប្រទេសចិន ឥណ្ឌូនេស៊ី ថៃ ។

លោក ញ៉ឹក វណ្ណារ៉ា បានថ្លែងដូចនេះ នាថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២៣នេះ ក្នុងឱកាសអញ្ជើញជាអធិបតីក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី នីតិវិធីនៃដំណើរការមាតុភូមិនិវត្តន៍ជនរងគ្រោះ និងជនសង្ស័យថារងគ្រោះ ដោយអំពើជួញដូរមនុស្សតាមផ្លូវអាកាស។ ពិធីនេះក៏មានការចូលរួមពីលោក គង់ សូភណារ៉ា ទីប្រឹក្សាក្រសួងសង្គមកិច្ច លោក តូនី ផូសណិត នាយកប្រចាំប្រទេសអង្គការ វតនៈអន្តរជាតិ លោក ជ័យ រដ្ឋា ប្រធាននាយកដ្ឋានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងលោក លោកស្រី ប្រធាននាយកដ្ឋាន ប្រធានអង្គការ ឬតំណាងអង្គការ ស្ថាប័នដៃគូអភិវឌ្ឍន៍ និងអង្គការពាក់ពន្ធ័ជាច្រើនរូប។

លោក បានបន្ថែមទៀតថា ជនរងគ្រោះទាំងអស់នោះភាគច្រើន មានការសម្របសម្រួលតាមរយៈស្ថានទូត និងក្រសួងការបរទេស ដែលផ្តល់ឲ្យមកក្រសួងសង្គមកិច្ច អតីយយុទ្ធជន និងយុវនីតិសម្បទា ក្នុងការទទួល និងបញ្ជូនពួកគាត់ទៅរកសេវាស្នាក់នៅរយៈពេលវែង និងសេវាចាំបាច់នានា ពេលខ្លះការសម្របសម្រួលនោះមានភាពអសកម្មខ្លះដោយសារតែយើង មិនទាន់មានឯកសារជាក់លាក់ណាមួយ បង្ហាញឲ្យស៊ីជម្រៅ និងពេញលេញសម្រាប់មន្រ្តីអ្នកអនុវត្តទាំងនោះនៅឡើយ ហើយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បាននឹងកំពុងចងក្រងលិខិតបទដ្ឋានមួយចំនួនដើម្បីជាយន្តការក្នុងការសម្រួលដល់ការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ និងសង្ស័យថារងគ្រោះតាមផ្លូវអាកាសដើម្បីបង្កើនប្រសិទ្ធភាពក្នុងការផ្តល់ការសម្របសម្រួលទទួល ជនរងគ្រោះដោយមានទំនួលខុសត្រូវតាមជំនាញរបស់ខ្លួន និងផ្តល់សេវាឲ្យមានប្រសិទ្ធភាពដល់ជនរងគ្រោះ ។

លោក ញ៉ឹក វណ្ណារ៉ា ក៏បានបង្ហាញក្តីសង្ឃឹមយ៉ាងមុតមាំថា ការចូលរួមក្រុមការងារបច្ចេកទេស (អ្នកអនុវត្តជាក់ស្តែង) របស់លោក លោកស្រី ស្តីពីនីតិវិធីនៃដំណើរការមាតុភូមិ និវត្តន៍ជនរងគ្រោះ និងជនសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្សតាមផ្លូវអាកាសដើម្បីជាប្រយោជន៍ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ ពិសេសកុមាររងគ្រោះដោយ អំពើជួញដូរ មនុស្ស និងកេងប្រវ័ញ្ចផ្លូវភេទនៅព្រះរាជាណាចក្រកម្ពុជាផងដែរ៕

# ថ្ងៃទី១០ ខែ មេសា ឆ្នាំ២០២៣

## លោក ស ខេង៖ ភ្ញៀវទេសចរ និងវិនិយោគគេមិនមកទេ បើដោះស្រាយបញ្ហាជួញដូរមនុស្សមិនបានល្អ

https://www.rfi.fr/km//20230407-?ref=tgi ចុះផ្សាយនៅថ្ងៃ៖ 07/04/2023 - 08:08

លោក ស ខេង រដ្ឋមន្រ្តីក្រសួងមហាផ្ទៃ បានជំរុញឲ្យខេត្តដែលជាប់ព័ន្ធករណីជួញដូរមនុស្សត្រូវចូលរួមដោះស្រាយឲ្យមានប្រសិទ្ធភាព ដើម្បីឈានទៅបិទបញ្ចប់បញ្ហានេះ។ បើតាមលោក ស ខេង ករណីនេះ មិនមែនជារឿងធម្មតាឡើយ ជារឿងធ្វើឲ្យខូចមុខមាត់និងកិត្តិយសកម្ពុជា ដែលធ្វើឲ្យភ្ញៀវទេសចរ និងអ្នកវិនិយោគខ្លាចរអា មិនហ៊ានមកកម្ពុជា។ ការលើកឡើងនេះ ធ្វើឡើងក្នុងកិច្ចប្រជុំផ្សព្វផ្សាយខ្លឹមសារនៃសេចក្តីណែនាំរួម ស្តីពីសកម្មភាព

និងការរៀបចំភ្នាក់ងារសន្តិសុខការពារដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៅថ្ងៃទី៦ ខែមេសា។

គិតមកទល់នឹងពេលនេះមានប្រមាណ ៨៥០ពាក្យបណ្តឹងហើយ ដែលបានប្តឹងឲ្យជួយសង្គ្រោះពីករណីសង្ស័យពីការជួញដូរមនុស្សនៅកម្ពុជា។ បើតាមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង ករណីជួញដូរមនុស្សនេះ ខេត្តដែលជាប់ពាក់ព័ន្ធមានប្រមាណជាង ១០ខេត្ត គឺខេត្តព្រះសីហនុ រាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ កំពត កោះកុង ពោធិ៍សាត់ ប៉ៃលិន ស្វាយរៀង ឧត្តរមានជ័យ បន្ទាយមានជ័យជាដើម ដោយករណីនេះផ្តើមចេញពីខេត្តព្រះសីហនុមុនគេ បន្ទាប់មកទើបរាលដាលដល់ខេត្តផ្សេងៗទៀត។ បណ្តឹងប្រមាណ ៨៥០ពាក្យបណ្តឹងនេះ លោក ស ខេង ចង់ឃើញខេត្តដែលជាប់ពាក់ព័ន្ធ ដោះស្រាយឲ្យមានប្រសិទ្ធភាព ដើម្បីឈានទៅបិទបញ្ចប់បញ្ហានេះ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃរូបនេះ សង្កត់ធ្ងន់ថា បើពាក្យបណ្តឹងទាំងនេះនៅមិនទាន់ដោះស្រាយចប់សព្វគ្រប់ទេ មិនអាចឈានទៅបិទបញ្ចប់បញ្ហាជួញដូរមនុស្សនៅកម្ពុជាឡើយ។ លោក ស ខេង សង្កត់ធ្ងន់ទៀតថា រឿងនេះមិនមែនជារឿងធម្មតាឡើយ ជារឿងជាប់ព័ន្ធកិត្តិយសមុខមាត់កម្ពុជា បើមិនដូច្នោះទេភ្ញៀវទេសចរ និងអ្នកវិនិយោគទន់បរទេសមិនហ៊ានមកកម្ពុជាឡើយ ប្រសិនបើការដោះស្រាយមិនបានល្អទេនោះ ព្រោះគេមិនទុកចិត្តកម្ពុជា។ លោកថា ការដោះស្រាយបញ្ហានេះ ក៏ជាចំណែកមួយជួយដល់ទំនាក់ទំនងអន្តរជាតិរបស់កម្ពុជាដែរ ជាពិសេសជាមួយបណ្តាជាមិត្តទាំងអស់។

យ៉ាងណាមិញបើតាមលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបញ្ជាក់ថា ពាក្យបណ្តឹងប្រមាណ៨៥០នេះ មានខ្លះប្តឹងឲ្យជួយសង្គ្រោះ ដោយសង្ស័យថា ជួញដូរមនុស្ស ប៉ុន្តែពេលចុះទៅស្រាវជ្រាវផ្ទាល់ករណីខ្លះ មិនមែនជាករណីជួញដូរមនុស្សឡើយ។ លោកស្រីបន្តថា ការស្រាវជ្រាវតាមបណ្តឹង ឃើញថាមានករណីខ្លះឆ្លងដែនមកដោយខុសច្បាប់ និងខ្លះទៀតរកឃើញថាជាករណីជួញដូរមនុស្ស។ ត្រង់បញ្ហានេះ លោកស្រីបានគូសបញ្ជាក់ថា គ្រប់បណ្តឹងទាំងអស់ មិនមែនសុទ្ធសឹងជាករណីជួញដូរមនុស្សនោះទេ។

សូមបញ្ជាក់ថា ពាក់ព័ន្ធបញ្ហាជួញដូរមនុស្សនេះ របាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងការបរទេសអាមេរិក បង្ហាញថា កម្ពុជាបានធ្លាក់ទៅកម្រិតទី៣ ឬបញ្ជីខ្មៅ នៃសកម្មជួញដូរមនុស្សប្រចាំឆ្នាំ២០២២។ ក្រោយពីអាមេរិកចេញរបាយការណ៍ទម្លាក់កម្ពុជាទៅកម្រិតទី៣ ឬបញ្ជីខ្មៅ នៃសកម្មជួញដូរមនុស្ស រដ្ឋាភិបាលតាមរយៈក្រសួងមហាផ្ទៃ និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស បានចេញប្រតិបត្តិការបង្ក្រាប ដោយបានចាប់ខ្លួនមេខ្លោង និងអ្នកពាក់ព័ន្ធមួយចំនួន ហើយជួយសង្គ្រោះមនុស្សបានជាច្រើននាក់ពីការជួញដូរនេះ ខណៈប្រតិបត្តិនេះបានចាប់ផ្តើមធ្វើនៅខេត្តព្រះសីហនុ និងខេត្តដទៃទៀតជាបន្តបន្ទាប់។

ពាក់ព័ន្ធបទល្មើសជួញដូរមនុស្ស និងបទល្មើសផ្សេងៗទៀតនេះ លោក ស ខេង ក្នុងពិធីប្រកាសចូលកាន់មុខតំណែងអភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ កាលពីថ្ងៃទី២១ វិច្ឆិកាកន្លងទៅ ធ្លាប់បានលើកឡើងថា បើគ្មានមន្ត្រីជាប់ពាក់ព័ន្ធទេ បញ្ហាទាំងនេះ គឺងាយស្រួលដោះស្រាយបំផុត។ លោកធ្លាប់ត្អូញត្អែរថា ពិបាកស្រាវជ្រាវណាស់ បើមានមន្ត្រីជាប់ពាក់ព័ន្ធ ព្រោះបើមន្ត្រីជាប់ពាក់ព័ន្ធ ការដោះស្រាយ គឺផ្អែកតាមអារម្មណ៍ មិនបានផ្អែកតាមគោលការណ៍ច្បាប់ឡើយ៕

## រដ្ឋមន្ត្រីម៉ាឡេស៊ីនិយាយថា អនុស្សរណៈយោគយល់គ្នាចំនួនពីរដែលចុះហត្ថលេខាដោយម៉ាឡេស៊ីនិងកម្ពុជានឹងជួយជំរុញកម្លាំងពលកម្ម

https://www.khmertimeskh.com/501269824// Khmer Times April 7, 2023

អនុស្សរណៈនៃការយោគយល់គ្នាចំនួនពីរ ដែលបានចុះហត្ថលេខាក្នុងអំឡុងពេលដំណើរទស្សនកិច្ចរបស់នាយករដ្ឋមន្ត្រី Anwar Ibrahim នៅកម្ពុជានាពេលថ្មីៗនេះ នឹងជួយក្នុងការជ្រើសរើសពលករបន្ថែមនៅក្នុងប្រទេសម៉ាឡេស៊ី។ រដ្ឋមន្ត្រីក្រសួងធនធានមនុស្ស លោក V. Sivakumar បាននិយាយថា អនុស្សរណៈ នៃការយោគយល់គ្នាចំនួនពីរ ពាក់ព័ន្ធនឹងការបណ្តុះបណ្តាលបុគ្គលិកកម្ពុជា ក៏ដូចជាគំនិតផ្តួចផ្តើម ដើម្បីជួយក្នុងការធ្វើសមាហរណកម្មរបស់ពួកគេនៅកន្លែងធ្វើការ។

"នៅក្នុងដំណើរទស្សនកិច្ចការងាររបស់ខ្ញុំជាមួយនាយករដ្ឋមន្ត្រីនៅកម្ពុជា យើងបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាចំនួនពីរ ដែលនឹងជួយពង្រឹងកិច្ចសហប្រតិបត្តិការខាងផ្នែកពលកម្មការងារ" ។ លោកបាននិយាយក្នុងអំឡុងសន្និសីទសារព័ត៌មាននៅ Wisma Perkeso ថា "អនុស្សរណៈនៃការយោគយល់គ្នាទាំងពីរមានគោលបំណងនាំយកកម្លាំងការងារមកពីបរទេសបម្រើក្នុងវិស័យផ្លូវការ និងការងារតាមផ្ទះ" ។ លោកបន្តថា បច្ចុប្បន្នមានពលករខ្មែរចំនួន ៤.៤២២នាក់ ក្នុងនោះ ៩២៦នាក់បម្រើការងារតាមផ្ទះ។ «ខណៈដែលចំនួនពលករកម្ពុជាក្នុងប្រទេសមានកម្រិត យើងគិតថាការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នានឹងជំរុញចំនួនពលករកាន់តែច្រើនមកពីប្រទេសកម្ពុជា»។

លោក Sivakumar បានពន្យល់ថា "ពលករទាំងនេះនឹងត្រូវបានបណ្តុះបណ្តាល មុនពេលមកប្រទេសម៉ាឡេស៊ី ដូច្នេះពួកគេអាចធ្វើសមាហរណកម្ម និងធ្វើការងារបានយ៉ាងល្អនៅទីនេះ ជៀសវាងស្ថានភាពមិនអំណោយផលណាមួយ" ។ លោកធ្លាប់បានចូលរួមក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងភាពជាដៃគូរវាងអង្គការសន្តិសុខសង្គម(Perkeso)និងនាយកដ្ឋានពន្ធនាគារដើម្បីផ្តល់ជូនឱកាសទីពីរដល់អ្នកទោសចូលបម្រើការងារម្តងទៀត៕

*New Straits Times*

## ជិតដល់ថ្ងៃចូលឆ្នាំខ្មែរ ពលរដ្ឋខ្មែរធ្វើដំណើរចាកចេញពីប្រទេសថៃតាមច្រកអន្តរជាតិអូរស្មាច់ក្នុងមួយថ្ងៃៗរាប់រយនាក់

https://freshnewsasia.com/index.php/en/localnews/285509-2023-04-07-08-59-40.html 2023-04-07 03:59pm

**(ឧត្តរមានជ័យ)៖** ស្របពេលដែលពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរជិតចូលមកដល់ គេសង្កេតឃើញប្រជាពលរដ្ឋខ្មែរ ដែលធ្វើការនៅប្រទេសថៃ បានសម្រុកចូលមកស្រុកកំណើតវិញយ៉ាងច្រើនក្នុងមួយថ្ងៃៗរាប់រយនាក់ តាមច្រកអន្តរជាតិអូរស្មាច់ ក្នុងសង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ។

មន្ត្រីនគរបាលអន្តោប្រវេសន៍ច្រកព្រំដែនអន្តរជាតិអូរស្មាច់ បានថ្លែងឱ្យដឹងនៅព្រឹកថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៣ថា ចាប់តាំងពីដើមខែមេសា ឆ្នាំ២០២៣មក ពលករបានធ្វើការចំណាកស្រុកពីប្រទេសថៃ ឆ្លងដែនមកស្រុកវិញ ក្នុងមួយថ្ងៃៗមានចំនួនរាប់រយនាក់។ លោកថា កត្តាដែលពលករឆ្លងដែនត្រឡប់ចូលប្រទេសវិញយ៉ាងច្រើនបែបនេះ គឺដើម្បីមកលេងស្រុកកំណើត ជួបជុំក្រុមគ្រួសារ សាច់ញាតិ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ដែលខិតជិតមកដល់នាពេលដ៏ខ្លីខាងមុខនេះ។ លោកបានថ្លែងបន្តថា កន្លងមកជារៀងរាល់ឆ្នាំឲ្យតែជិតដល់ពិធីបុណ្យចូលឆ្នាំថ្មី ភាគច្រើនប្រជាពលរដ្ឋដែលធ្វើការចំណាកស្រុកមកពីប្រទេសថៃ នោះតែងតែសរុកធ្វើដំណើរឆ្លងដែនមកស្រុកកំណើតរបស់ខ្លួន មានចំនួនច្រើនលើសពីថ្ងៃធម្មតា។

ជាមួយគ្នានេះ ក្រុមការងារដែលឈរជើងប្រចាំការនៅច្រកទ្វារព្រំដែន តែងតែជួយសម្របសម្រួលរាល់បញ្ហានានារបស់ពួកគាត់ ធ្វើយ៉ាងណាដើម្បីឲ្យប្រជាពលរដ្ឋទាំងអស់ធ្វើដំណើរវិលត្រលប់ទៅស្រុកកំណើត របស់ខ្លួនវិញប្រកបដោយសុខសុវត្ថិភាព៕

## សមត្ថកិច្ចអន្តរាគមន៍ជួយសង្គ្រោះជនជាតិចិន៤នាក់ដែលត្រូវជនជាតិចិនដូចគ្នាបញ្ឆោតឱ្យមកធ្វើការខុសពីការសន្យា

https://www.kampucheathmey.com/security/492100 ថ្ងៃសៅរ៍ ៨ មេសា ២០២៣ដោយ Sokhom Khon

សមត្ថកិច្ចបានអន្តរាគមន៍ជួយសង្គ្រោះជនជាតិចិនចំនួន៤នាក់ ដែលត្រូវជនជាតិចិនដូចគ្នាបោកបញ្ឆោតឱ្យមកធ្វើការខុសពីការសន្យា បន្ទាប់ពីជនរងគ្រោះបានសរសេរពាក្យបណ្ដឹងចូលហ្វេសប៊ុកផេក (បណ្ដឹងលេខ ៨១៩) របស់ សម្ដេចក្រឡាហោម ស ខេង កាលពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣។

ជនជាតិចិនទាំង៤នាក់នោះ រួមមាន ១. ឈ្មោះ ZHANG XIANBIN ភេទប្រុស កើតឆ្នាំ១៩៩៤ (អ្នកប្ដឹង), ២. ឈ្មោះ CHENG RUI ភេទប្រុស កើតឆ្នាំ១៩៩៥, ៣. ឈ្មោះ LUO YANGCHAO ភេទប្រុស កើតឆ្នាំ១៩៩៩ និងទី៤. ឈ្មោះ LIU LUNJIANG ភេទប្រុស កើតឆ្នាំ១៩៩៤។ ជនជាតិចិនទាំង០៤នាក់ខាងលើមានលិខិតឆ្លងដែន និងទិដ្ឋាការស្នាក់នៅមានសុពលភាពទាំងអស់។

យោងតាមលទ្ធផលនៃការសាកសួររបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ពួកគេទាំង៤នាក់ បានចូលមកកម្ពុជានៅថ្ងៃទី២៨ ខែកម្ភៈ ឆ្នាំ២០២៣ តាមច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ក្នុងគោលបំណងមកធ្វើការងារជាចុងភៅនៅខេត្តព្រះសីហនុ តាមការទំនាក់ទំនងលើបណ្ដាញអ៊ីនធើណិត (APP) ដោយសន្យាផ្ដល់ប្រាក់១៤.០០០ទៅ១៥,០០០យ័ន និងមានឈ្មោះ សៃ ផាន ជាអ្នករៀបចំសំបុត្រយន្តហោះ។ ប៉ុន្តែក្រុមហ៊ុនបែរជាតម្រូវឲ្យពួកគេធ្វើការផ្នែក Online ខុសពីគោលបំណងដើមជាចុងភៅ ទើបពួកគេក៏បានប្ដឹងឲ្យសមត្ថកិច្ចជួយអន្តរាគមន៍។ លុះដល់ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ ក៏មានសមត្ថកិច្ចចុះទៅនាំខ្លួនពួកគេចេញពីក្រុមហ៊ុនមកស្នងការខេត្តព្រះសីហនុ។ មកដល់ថ្ងៃទី៣ ខែមេសា សមត្ថកិច្ចក៏បាននាំពួកគេទៅមន្ទីរសង្គមកិច្ចនិងបញ្ជូនមកអគ្គនាយកដ្ឋានអន្តោប្រវេសន៍។

ចំពោះមុខ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានអនុញ្ញាតឲ្យជនជាតិចិនទាំង៤នាក់ខាងលើស្នាក់នៅសណ្ឋាគារ និងបានប្រគល់លិខិតឆ្លងដែនដល់ពួកគេទាំង៤នាក់វិញ ក្នុងនោះតាមព័ត៌មានដែលទទួលបានមានម្នាក់ក្នុងចំណោម៤នាក់បានសម្រេចចិត្តធ្វើដំណើរទៅប្រទេសចិនវិញដើម្បីជួបជុំក្រុមគ្រួសារ។ អគ្គនាយកដ្ឋានក៏បានជូនដំណឹងនេះទៅស្ថានទូតសាធារណៈរដ្ឋប្រជាមានិតចិនប្រចាំកម្ពុជាផងដែរ។

សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សធ្លាប់បានអំពាវនាវសាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្ដាប្រទេសពាក់ព័ន្ធសហការផ្ដល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀតដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

គួរបញ្ជាក់ថា គិតចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដល់ថ្ងៃទី៦ ខែមេសាឆ្នាំ២០២៣ មានពាក្យបណ្ដឹងសុំកិច្ចអន្តរាគមន៍ចំនួន៨៣០ករណីសរុបមនុស្សចំនួន២ ០៩៤នាក់ ស្មើនឹង១៦សញ្ជាតិ ភាគច្រើនជនជាតិចិន វៀតណាម និងឥណ្ឌូនេស៊ី។ បណ្ដឹងទាំងនោះបានប្ដឹងចូលទំព័រហ្វេសប៊ុកសម្ដេចក្រឡាហោម អគ្គស្នងការដ្ឋាននគរបាលជាតិនិងអគ្គនាយកដ្ឋានអន្តោប្រវេសន៍។ ផ្អែកតាមលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរមានសមត្ថកិច្ចកម្ពុជាភាគច្រើន នៃបណ្ដឹងទាំងនោះត្រូវបានដោះស្រាយយ៉ាងមានប្រសិទ្ធភាពពោលគឺ ទាំងការសង្គ្រោះជនរងគ្រោះ ការបិទទីតាំងអាជីវកម្មខុសច្បាប់ការចាប់ជនល្មើសបញ្ជូនទៅតុលាការ និងការអនុវត្តនីតិវិធីបណ្ដេញចេញ៕

## ស្ត្រីជនជាតិចិនម្នាក់ បានស្នើសុំអន្តរាគមន៍ តាមរយៈទំព័រហ្វេសបុកសម្តេចក្រឡាហោម

https://cen.com.kh/archives/645422.html Posted ByPen Srey NeatApril 8, 2023

ភ្នំពេញ ៖ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស គណៈបញ្ជាការដឹកនាំប្រតិបត្តិការ ក្រុមប្រតិបត្តិការស៊ើបអង្កេត ស្រាវជ្រាវ បណ្តាញនាំមនុស្សឆ្លងដែនខុសច្បាប់ បានចេញសេចក្តីប្រកាសព័ត៌មានថា ក្រុមប្រតិបត្តិការស៊ើបអង្កេត ស្រាវជ្រាវ បណ្តាញនាំមនុស្សឆ្លងដែនខុសច្បាប់ នៃអគ្គស្នងការដ្ឋាន នគរបាលជាតិ សូមជម្រាបជូនដល់សាធារណជនអំពីលទ្ធផលប្រតិបត្តិការស្វែងរកជនបរទេស ដែលបាន ស្នើសុំអន្តរាគមន៍ តាមរយៈទំព័រហ្វេសប៊ុកសម្តេចក្រឡាហោម (ករណីលេខ ៧៧៩)។ នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ក្រុមប្រតិបត្តិការទទួលបានសំណើសុំអន្តរាគមន៍ពីស្ត្រីជនជាតិចិន ឈ្មោះ SONG HUILING កើតថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៧ កាន់លិខិតឆ្លងដែនលេខ EG6006217 ដែល សង្ស័យត្រូវបានបង្ខាំងក្នុងទីតាំងមួយកន្លែងស្ថិតនៅខេត្តកោះកុង។

ក្រោយទទួលបានសំណើសុំអន្តរាគមន៍នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣ ស្នងការដ្ឋាននគរបាល ខេត្តកោះកុង បានចុះស្រាវជ្រាវរកឃើញស្ត្រីជនជាតិចិនខាងលើ កំពុងស្នាក់នៅក្នុងក្រុមហ៊ុនមួយកន្លែង ស្ថិតនៅខេត្តកោះកុង។ តាមការបំភ្លឺរបស់សាមីខ្លួនបានឱ្យដឹងថា រូបនាងបានចូលមកប្រទេសកម្ពុជានៅ ចុងខែកញ្ញា ឆ្នាំ២០២២ ក្នុងគោលបំណងមកស្នាក់នៅ និងធ្វើការក្នុងក្រុមហ៊ុនមួយកន្លែងនៅខេត្តកោះកុង តាមរយៈភ្នាក់ងារស្វែងរកការងារនៅប្រទេសចិន។ អំឡុងពេលធ្វើការអស់រយៈពេល ០៦ខែ គឺពុំមានការបង្ខាំង បិទសិទ្ធសេរីភាព ឬធ្វើទារុណកម្មនោះទេ ប៉ុន្តែដោយសាររូបនាងមានបំណងចង់ត្រឡប់ទៅប្រទេសចិនវិញ ទើបនៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២៣ បានដាក់សំណើសុំអន្តរាគមន៍តាមទំព័រហ្វេសប៊ុកសម្តេចក្រឡាហោម ដោយសារតែខ្លួនធ្លាប់បានសុំក្រុមហ៊ុនលាឈប់ចំនួន ០២លើក ប៉ុន្តែក្រុមហ៊ុនមិនអនុញ្ញាត ព្រោះក្រុមហ៊ុន កំពុងខ្វះបុគ្គលិក និងស្នើសុំរូបនាងឱ្យជួយបន្តការងាររហូតដល់មានបុគ្គលិកថ្មីមកជំនួស។

ផ្អែកតាមការ ពិនិត្យស្ថានភាពជាក់ស្តែង និងការបំភ្លឺរបស់សាមីខ្លួន ករណីនេះក្រុមប្រតិបត្តិការពិនិត្យឃើញថា មិនមាន ការបង្ខាំង ឬធ្វើទារុណកម្មនោះទេ ផ្ទុយទៅវិញ គឺឈ្មោះ SONG HUILING ស្នើសុំសមត្ថកិច្ចជួយអន្តរាគមន៍ ឱ្យខ្លួនបានឈប់ពីការងារ និងត្រឡប់ទៅប្រទេសកំណើតវិញ។ បច្ចុប្បន្នសមត្ថកិច្ចជំនាញបានបញ្ជូនឈ្មោះ SONG HUILING ទៅកាន់មណ្ឌលត្រៀមបណ្តេញ ចេញនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីអនុវត្តនីតិវិធីធ្វើមាតុភូមិនិវត្តន៍៕ រក្សាសិទ្ធដោយ ៖ សុទ្ធលី

# ថ្ងៃទី១១ ខែ មេសា ឆ្នាំ២០២៣

## មានការភ្ញាក់ផ្អើល ខណៈនគរបាលឃាត់ខ្លួននិងនិរទេសជនជាតិជប៉ុន១៩នាក់ ពីបទឆបោកតាមទូរស័ព្ទ

https://www.khmertimeskh.com/501270243//?p=1270243 Khmer Times April 8, 2023

អាជ្ញាធរនៃប្រទេសទាំងពីរបាននិយាយកាលពីថ្ងៃសុក្រថា ជនជាតិជប៉ុនចំនួន១៩នាក់ ត្រូវបានឃុំខ្លួននៅក្នុងប្រទេសកម្ពុជាពីបទជាប់ពាក់ព័ន្ធក្នុងការឆបោកតាមទូរស័ព្ទនៅក្នុងប្រទេសជប៉ុន។ ប្រភពស៊ើបអង្កេត បាននិយាយថា នគរបាលក្រុងតូក្យូទទួលបានដីកាចាប់ខ្លួនជនទាំងនោះ កាលពីថ្ងៃព្រហស្បតិ៍ ហើយគ្រោងនឹងបញ្ជូនអ្នកស៊ើបអង្កេតមកកម្ពុជា នៅដើមសប្តាហ៍ក្រោយ ដើម្បីដឹកជញ្ជូនពួកគេទៅកាន់ប្រទេសជប៉ុន។ ប្រទេសជប៉ុនបាន

នឹងកំពុងបង្ក្រាបក្រុមឧក្រិដ្ឋកម្ម ដែលមានមូលដ្ឋាននៅក្រៅប្រទេស។ ប្រភពដដែលបានបន្តថា នគរបាលនៅក្នុងប្រទេសកម្ពុជាបានស៊ើបអង្កេតសណ្ឋាគារមួយនៅខេត្តព្រះសីហនុភាគខាងត្បូងក្នុងខែមករា បន្ទាប់ពីស្ថានទូតជប៉ុនប្រចាំនៅកម្ពុជាត្រូវបានគេផ្តល់ដំណឹងអំពីក្រុមឆបោកដ៏មានសក្តានុពល ដែលប្រតិបត្តិការពីទីតាំងនេះ។ បុរសទាំងនោះ ដែលមានអាយុពី២០ ទៅ៥០ឆ្នាំ ត្រូវបានសង្ស័យថា បានបោកប្រាស់លុយពីប្រជាជនតាម រយៈការអះអាងថា ជនរងគ្រោះថាហួសកាលកំណត់បង់ប្រាក់សម្រាប់គេហទំព័រ សម្រាប់ការចុះឈ្មោះ។

យោងតាមប្រភពបានឱ្យដឹងថា ដីកាចាប់ខ្លួនត្រូវបានចេញពាក់ព័ន្ធនឹងករណីដែលស្ត្រីម្នាក់អាយុ៦០ឆ្នាំរស់នៅក្នុងទីក្រុងតូក្យូត្រូវបានបោកប្រាស់ប្រាក់អេឡិចត្រូនិក BitCash ចំនួន២៥០,០០០យ៉េន (១,៩០០ដុល្លារ) នៅក្នុងខែមករា។ នគរបាលកម្ពុជាបាននិយាយថា ពួកគេកំពុងរៀបចំបញ្ជូនបុរសទាំងនោះត្រឡប់ទៅប្រទេសជប៉ុនវិញនៅប៉ុន្មានថ្ងៃខាងមុខ។ បុរសទាំងនោះត្រូវបានគេជឿថា បានផ្ញើសារដែលអះអាងថា មកពីប្រតិបត្តិករទូរសព្ទជប៉ុន NTT Docomo Inc. ទៅកាន់លេខទូរសព្ទក្នុងប្រទេសជប៉ុន។ បន្ទាប់មក ពួកគេនឹងបង្ខិតបង្ខំអ្នកដែលបានហៅត្រឡប់មកវិញឱ្យផ្ញើប្រាក់អេឡិចត្រូនិកដោយជូនដំណឹងពួកគេអំពីអ្វីដែលពួកគេបានអះអាងថាជាការបង់ប្រាក់លើសសម្រាប់ការចុះឈ្មោះ។

ប្រភពបានឱ្យដឹងថា ទូរស័ព្ទដៃជាច្រើនគ្រឿង សៀវភៅណែនាំអំពីរបៀបបោកប្រាស់មនុស្ស និងបញ្ជីឈ្មោះរួមទាំងជនរងគ្រោះ គឺជារបស់ដែលបានរកឃើញនៅក្នុងបន្ទប់សណ្ឋាគារ ដែលត្រូវបានគេជឿថា ត្រូវបានគេប្រើប្រាស់ជាការិយាល័យជាក់ស្តែង។ មន្ត្រីមូលដ្ឋានបានឲ្យដឹងថា ជនសង្ស័យទាំង ១៩ នាក់នេះសុទ្ធតែបានសុំទិដ្ឋាការទេសចរណ៍ពេលចូលប្រទេសកម្ពុជា។ អ្នកខ្លះបានចូលប្រទេសកម្ពុជាកាលពីពីរឆ្នាំមុន ឯអ្នកខ្លះទៀតចូលកម្ពុជាបានប្រាំមួយខែ។

ស្រដៀងគ្នានេះដែរ នគរបាលជប៉ុនថ្មីៗនេះបានដឹកជញ្ជូនជនសង្ស័យពីប្រទេសហ្វីលីពីន ហើយបានចាប់ខ្លួនពួកគេដោយសង្ស័យពីបទចោរកម្ម ពាក់ព័ន្ធនឹងករណីឆបោកសំដៅទៅលើមនុស្សចាស់នៅក្នុងប្រទេសជប៉ុន។ អ្នកដែលត្រូវបានចាប់ខ្លួនក៏ត្រូវបានគេសង្ស័យថាបានសម្របសម្រួលក្រុមចោរប្លន់នៅទូទាំងប្រទេស។ សកម្មភាពបែបនេះហាក់មានការធ្លាក់ចុះក្នុងខេត្តព្រះសីហនុនាពេលថ្មីៗនេះ ប៉ុន្តែនៅតែបន្តនៅកន្លែងផ្សេងទៀត។ ការបោកប្រាស់តាមប្រព័ន្ធអ៊ីនធឺណិតបានក្លាយជាបញ្ហាចម្បងនៅក្នុងប្រទេសកម្ពុជាកាលពីឆ្នាំមុន ដោយគណនីជាច្រើនរបស់ប្រជាជនមកពីបណ្តាប្រទេសអាស៊ីផ្សេងៗ និងកន្លែងជាច្រើនទៀតត្រូវបានទាក់ទាញឱ្យមកធ្វើការនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែនេះគឺជាលើកទីមួយហើយដែលជនសង្ស័យជនជាតិជប៉ុនត្រូវបានចាប់ខ្លួន និងនិរទេស។ *The Mainichi*

## ការចេញប័ណ្ណសម្គាល់សម្រាប់ពលករចំណាកស្រុកពីប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម ត្រូវបានផ្អាករហូតដល់ថ្ងៃទី១៥ ខែឧសភា

https://www.khmertimeskh.com/501270411//?p=1270411 Khmer Times April 9, 2023

ប្រទេសថៃកំពុងផ្អាកសេវាកម្មមួយចំនួនសម្រាប់ពលករចំណាកស្រុករហូតដល់ក្រោយការបោះឆ្នោតសកលដើម្បីធានាថាការបោះឆ្នោតដំណើរការទៅមុខដោយគ្មានបញ្ហា។ ការបោះឆ្នោតគ្រោងធ្វើនៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ ២០២៣។ កាសែត The Nation របស់ប្រទេសថៃបានដកស្រង់សម្តីលោក Chatree Wattanakhajorn អនុលេខាអចិន្ត្រៃយ៍ប្រចាំទីក្រុង ដែលបាននិយាយកាលពីថ្ងៃសុក្រថា សេវាកម្មដូចជាការចុះឈ្មោះ ធ្វើបច្ចុប្បន្នភាពកំណត់ត្រា និងការធ្វើប័ណ្ណសម្គាល់សម្រាប់ពលករមកពីប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម នឹងត្រូវផ្អាករហូតដល់ថ្ងៃទី១៥ ខែឧសភា។ លោក Chatree បានបន្ថែមថា ចំណាត់ការនេះគឺដើម្បីធានាថាគ្រប់ការិយាល័យខណ្ឌ

ទាំងអស់អាចគ្រប់គ្រងបន្ទុកការងារដែលកំពុងកើនឡើងនៅក្នុងដំណើរការបោះឆ្នោត និងធានាថាមិនមានឧបសគ្គអ្វីទាំងអស់។ ប្រជាជននៅទីក្រុងបាងកក និងខេត្តចំនួន ៧៦ ផ្សេងទៀតនឹងទៅបោះឆ្នោតសម្រាប់មណ្ឌលបោះឆ្នោត និងសមាជិកសភាក្នុងបញ្ជីគណបក្សនៅថ្ងៃអាទិត្យ ទី១៤ ឧសភា ចាប់ពីម៉ោង ៨ ព្រឹក ដល់ ៥ ល្ងាច។ សេវាកម្មទាំងអស់នឹងដំណើរការដូចធម្មតាចាប់ពីថ្ងៃទី១៦ ឧសភា។

មន្ត្រីក្រសួងការងារកម្ពុជាបានប៉ាន់ប្រមាណក្នុងខែមិថុនា ឆ្នាំ២០២២ ថា មានពលករចំណាកស្រុកខ្មែរជាង ១,២ នាក់ កំពុងធ្វើការនៅប្រទេសថៃក្នុងវិស័យផ្សេងៗដូចជា សំណង់ កសិកម្ម នេសាទ និងរោងចក្រអាហារ។ ខណៈពេលដែលពលករជាច្រើនបានចូលប្រទេសថៃដោយស្របច្បាប់ដោយមានឯកសារធ្វើដំណើរត្រឹមត្រូវ និងការចុះឈ្មោះផ្សេងទៀត ក៏មានមនុស្សជាច្រើននាក់ផ្សេងទៀតបានឆ្លងព្រំដែនញឹកញាប់ជាពិសេសក្នុងខេត្តបាត់ដំបង ដើម្បីស្វែងរកការងារធ្វើនៅចម្ការផ្លែឈើ ផ្សារ និងការងារផ្សេងៗទៀត ខណៈដែលការងារទាំងនេះត្រូវបានគេរាយការណ៍ថាទទួលបានប្រាក់ឈ្នួលប្រចាំថ្ងៃខ្ពស់។ *Nation Thailand/Khmer Times*

## រដ្ឋមន្ត្រីក្រសួងការងារ កោតសសើរពលករខ្មែរ ដែលខិតខំធ្វើការងាររកកម្រៃចិញ្ចឹមគ្រួសារ និងរួមចំណែករកចំណូលជូនជាតិ

https://cen.com.kh/archives/645796.html Posted ByCENApril 10, 2023

បាងកក៖ ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធាន គណៈកម្មការផ្តល់ភាពស្របច្បាប់ ជូនពលករខ្មែរកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ នារសៀលថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៣ បានអញ្ជើញចូលរួមសង្ក្រាន្តជាមួយពលករ សិស្សនិស្សិត អាជីវករ និងពលរដ្ឋខ្មែរ ដែលកំពុងធ្វើការ រៀនសូត្រ និងប្រកបរបរអាជីវកម្មនៅក្នុងប្រទេសថៃ។ ក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង បានកោតសសើរបងប្អូនពលករខ្មែរយើង ដែលមានស្មារតីតស៊ូ អត់ធ្មត់ ខិតខំធ្វើការងាររកកម្រៃចិញ្ចឹមគ្រួសារ និងបានរួមចំណែករកចំណូលជូនជាតិ។ ឯកឧត្តមលើកឡើងថា៖ «បងប្អូនពលករយើងនៅថៃមាន១លាន ២សែននាក់ ម្នាក់ៗមួយខែផ្ញើទៅផ្ទះ១៦៧ដុល្លារអាម៉េរិក មួយឆ្នាំ បានប្រមាណ២ពាន់លានដុល្លារ» ។ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង បានពាំនាំផ្តាំផ្ញើ ការសាកសួរសុខទុក្ខ និងពរបវរ មហាប្រសើរ ពីសម្តេចតេជោ ហ៊ុន សែន និងសម្តេចគតិព្រឹទ្ធ បណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ជូនបងប្អូនខ្មែរទាំងអស់ ដែលជានិច្ចកាលសម្តេចទាំងទ្វេ តែងយកចិត្តទុកដាក់ពីសុខទុក្ខរបស់បងប្អូនពលកររបស់យើង ដែលកំពុងធ្វើការនៅក្រៅប្រទេស។

ឯកឧត្តមបណ្ឌិត អ៊ិត សំហេង គូសបញ្ជាក់ថា សង្ក្រាន្តចូលឆ្នាំខ្មែរ គឺជាបុណ្យប្រពៃណីជាតិ ដ៏ធំរបស់ខ្មែរកាន់ព្រះពុទ្ធសាសនា ដែលស្ថិតក្នុងដួងចិត្តខ្មែរគ្រប់រូបតាំងពីបុរាណកាលមក។ ឆ្នាំនេះបងប្អូនខ្មែរយើងនៅថៃមួយចំនួន បានទៅលេងស្រុកកំណើតចូលឆ្នាំ តែភាគច្រើន មិនបានទៅលេងស្រុកទេ ដោយរវល់ការងារ តែយើងបានរៀបចំចូលឆ្នាំខ្មែរ តាមប្រពៃណីនៅទីនេះបានដែរ ហើយអាចទំនាក់ទំនង សួរសុខទុក្ខ ជូនពរចូលឆ្នាំថ្មី ដល់អ្នកមានគុណនៅឯស្រុកកំណើតរបស់យើងដែរ។ ឯកឧត្តមរដ្ឋមន្ត្រី បានកោតសរសើរ ចំពោះឯកឧត្តមអគ្គរាជទូត និងសហការី ដែលបានខិតខំបំពេញភារកិច្ច ការទូតតាមគោលនយោបាយ របស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងពង្រីក កិច្ចសហប្រតិបត្តិការជិតខាងល្អ កម្ពុជា-ថៃ ទាំងផ្នែក សេដ្ឋកិច្ច អប់រំ វិស័យការងារ ព្រមទាំងបានផ្តល់ឱកាសសិក្សាដល់និស្សិត និងផ្តល់ឱកាសការងារដល់ពលករកម្ពុជារបស់យើងផងដែរ។

ឯកឧត្តមរដ្ឋមន្ត្រី បានចាត់ទុកកិច្ចសហប្រតិបត្តិការ រវាងកម្ពុជា-ថៃ ជាកិច្ចសហប្រតិបត្តិការ ឈ្នះ-ឈ្នះ ដោយក្នុងនោះ បងប្អូន ពលករខ្មែរ អាចរកការងារ មានប្រាក់ចំណូល ចេះជំនាញការងារដែលកំពុងធ្វើ ពេលត្រឡប់ទៅស្រុកកំណើតវិញ អាចយកជំនាញទាំងនេះទៅចិញ្ចឹមក្រុមគ្រួសារ និងចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ រីឯខាងភាគីប្រទេសទទួល គេបានកម្លាំងពលកម្ម ដើម្បីបំពេញការផលិតរបស់គេដែរ។ ឯកឧត្តមរដ្ឋមន្ត្រី បានណែនាំបងប្អូន

ពលករ សូមថៃរក្សាសុខភាព សាមគ្គីភាព ចូលរួមគោរពច្បាប់របស់ប្រទេសគេឱ្យបានល្អ ជៀសវាងប្រព្រឹត្តិខុសនាំទោសដល់ខ្លួន។ អំឡុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ខាងមុខនេះ ពលករយើងមានសិទ្ធិបោះឆ្នោតដូចគ្នា គឺត្រូវបោះឆ្នោតនៅតាមមូលដ្ឋានដែលបងប្អូនចុះឈ្មោះ ដោយឯកឧត្តម បានអំពាវនាវដល់ពលករយើង ក៏ដូចជាក្រុមគ្រួសារបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា ដើម្បីរក្សាសុខសន្តិភាព និងដឹកនាំប្រទេសជាតិឱ្យមានការអភិវឌ្ឍរីកចម្រើនបន្តទៅមុខទៀត៕

## ក្រសួងការងារប្រកាសដាក់បញ្ចូលកម្មវិធីបណ្តុះបណ្តាលទេសន្តរប្រវេសន៍ដោយសុវត្ថិភាពនៅក្នុងកម្មវិធីសិក្សាក្នុង TVET

https://www.btv.com.kh/article/22077 2023/04/10 09:13:43 am

ភ្នំពេញ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅព្រឹកថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣នេះ បានរៀបចំពិធីដាក់ឲ្យដំណើរការជាផ្លូវការនូវការដាក់បញ្ចូលកម្មវិធី បណ្តុះបណ្តាលទេសន្តរប្រវេសន៍ ដោយសុវត្ថិភាពទៅក្នុងកម្មវិធីសិក្សាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ហៅកាត់ អ.ប.វ. ឬហៅកាតជាភាសាអង់គ្លេស ធីវែត (TVET)។ កម្មវិធីនេះ បានប្រព្រឹត្តទៅក្រោមអធិបតី ឯកឧត្តមបណ្ឌិត ពេជ សោភ័ន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាអនុប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាលដែលរៀបចំឡើងក្រោមកិច្ចសហការរវាងក្រសួងការងារ និងអង្គការអន្តរជាតិទេសន្តរប្រវេសន៍។

កម្មវិធីនេះត្រូវបានរៀបចំឡើងក្នុងគោលបំណង ដើម្បដាក់ឲ្យដំណើរការជាផ្លូវការនូវការអនុវត្តកម្មវិធីបណ្តុះបណ្តាលទេសន្តរប្រវេសន៍ដោយសុវត្ថិភាពនៅក្នុងកម្មវិធីសិក្សារបស់ អ.ប.វ. និងបង្ហាញជូនដល់ភាគីពាក់ព័ន្ធនានាអំពីសារៈសំខាន់នៃការដាក់បញ្ចូល និងអនុវត្តកម្មវិធីបណ្តុះបណ្តាលទេសន្តរប្រវេសន៍ដោយសុវត្ថិភាពនេះ, ដើម្បីបង្ហាញសេចក្តីណែនាំសម្រាប់ការអនុវត្តកម្មវិធីបណ្តុះបណ្តាលទេសន្តរប្រវេសន៍ដោយសុវត្ថិភាព និងការប្រើប្រាស់សេចក្តីណែនាំនេះ ទៅដល់អ្នកចូលរួម ជាពិសេសគ្រូបង្គោលមកពីគ្រឹះស្ថានអ.ប.វ.ទាំង៣៨, ដើម្បីផ្តល់ជូនវគ្គបណ្តុះបណ្តាលឡើងវិញលើមេរៀនទេសន្តរប្រវេសន៍ដោយសុវត្ថិភាពដល់គ្រូបង្គោលនៃគ្រឹះស្ថានអ.ប.វ. និងដើម្បីឱ្យសាធារណជនចាប់អារម្មណ៍ពីសារៈសំខាន់ នៃការលើកកម្ពស់ការយល់ដឹងអំពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព។

## ពលករខ្មែររាប់ពាន់នាក់កំពុងកកស្ទះនៅស្រុកអារញ្ញ ឈមច្រកទ្វារអន្តរជាតិប៉ោយប៉ែត

http://nokorwatnews.com/archives/987632 10/04/2023

ខេត្តបន្ទាយមានជ័យ៖ ពលករខ្មែរសម្រុកពីប្រទេសថៃរាប់ពាន់នាក់បានមកកកស្ទះនៅផ្សាររុងក្លឿស្រុកអារញ្ញ ខេត្តស្រះកែវ(ថៃ)ឈមនឹងច្រកទ្វារអន្តរជាតិប៉ោយប៉ែតត្រៀមចូលមកស្រុកកំណើតរបស់ពួកគាត់វិញ បន្ទាប់ពីរដូវចូលឆ្នាំខ្មែរប្រពៃណីជាតិជិតឈានចូលមកដល់។

តាមសេចក្តីរាយការណ៍បញ្ជាក់ថា នៅរសៀលថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៣នេះនៅមាត់ច្រកខ្លងលឹក ស្រុកអារញ្ញ ខេត្តស្រះកែវ(ប្រទេសថៃ)ឈមនឹងច្រកទ្វារអន្តរជាតិប៉ោយប៉ែតគេឃើញមានពលករប្រុសស្រី ខ្លះមានបង្វេចខោអាវសំពីងសំពោង ខ្លះអង្គុយ ខ្លះឈរត្រៀបត្រារាប់ពាន់នាក់រង់ចាំការវាយត្រាពីសមត្ថកិច្ចថៃ ដើម្បីវិលត្រលប់មកស្រុកកំណើតវិញ។

សេចក្តីរាយការណ៍ពីសមត្ថកិច្ចបន្តថា នៅល្ងាចប្រមាណជាម៉ោង៥ថ្ងៃដដែលនេះ គេនៅតែឃើញពលករខ្មែរសម្រុកមកជាបន្តបន្ទាប់ តែទោះជាយ៉ាងណាក៏ដោយ ការវិលត្រលប់ពីសំណាក់បងប្អូនប្រជាពលរដ្ឋខ្មែរយើងជា

ច្រើននោះមិនអាចវិលចូលមកផ្ទះរបស់ខ្លួនទាន់ពេលនោះទេ ព្រោះកំណើននៃការវិលត្រលប់របស់ពួកគាត់មានច្រើនកុះករធ្វើឱ្យសមត្ថកិច្ចថៃសម្រួលមិនទាន់ បណ្តាលឱ្យពួកគាត់ស្នាក់អាស្រ័យនៅក្នុងទឹកដីថៃបន្ត។

ប្រភពបានលើកឡើងថា៖ ករណីខាងលើនេះគួរតែមន្ត្រីគ្រប់លំដាប់ថ្នាក់ប្រចាំខេត្តបន្ទាយមានជ័យសហការជាមួយអាជ្ញាធរថៃដើម្បីសម្រួលឱ្យពួកគាត់ធ្វើដំណើរចេញឱ្យបានលឿនព្រោះថាពលរដ្ឋដែលមកនៅខាងភាគីថៃនៅពេលយប់មិនដឹងជាស្នាក់អាស្រ័យនៅទីណា ព្រោះពួកគាត់អ្នកខ្លះមានកូនតូចៗ ម្យ៉ាងទៀតអាចប្រឈមទៅនឹងបញ្ហាសុវត្ថិភាពផ្សេងៗកើតឡើងទៅលើពួកគាត់ និងអាចបាត់បង់ប្រាក់កាសដែលជនឆ្លៀតឱកាសលួចបន្លំមកលើពួកគាត់ដែលស្នាក់អាស្រ័យនៅប្រទេសគេដោយពុំមានការគ្រោងទុក។

ដោយឡែកនៅមាត់ច្រកទ្វារអន្តរជាតិប៉ោយប៉ែតសេចក្តីរាយការណ៍បានបន្តថាក៏មានច្រើនកុះករផងដែរ អ្នកខ្លះក៏រួតរះបានធ្វើដំណើរទៅផ្ទះ អ្នកខ្លះទៀតក៏ខកខានមិនបានធ្វើដំណើរផងដែរ៕

## នាយប៉ុស្តិ៍អន្តរជាតិប៉ោយប៉ែត រួសរាន់ជួយសម្រួល ប្រជាពលករ មកលេងស្រុកកំណើត

https://dap-news.com/national/2023/04/10/324631/ BySS107Posted on April 10, 2023

ភ្នំពេញ៖ ដើម្បីពន្លឿនការប្រថាប់ត្រា លិខិតឆ្លងដែនជូនពលករកម្ពុជា ធ្វើដំណើរចូលមកលេងកំសាន្ត នារដូវចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឱ្យបានរហ័ស និងទាន់ពេលវេលា កាត់បន្ថយការរង់ចាំយូរ នៅច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក អនុវត្តតាមការណែនាំរបស់លោកឧត្តមសេនីយ៍ត្រី នាយប៉ុស្តិ៍ និងដោយមានការឯកភាពពីភាគីថៃ ក្រុមការងាររបស់ប៉ុស្តិ៍ សហការជាមួយអាជ្ញធរក្រុង បានយករថយន្តដឹកជញ្ជូនពលករខ្មែរដែលមកដល់ច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក ហើយរង់ចាំយូរ ដោយមូលហេតុ មកពីនគរបាលអន្តោប្រវេសន៍ថៃ នៅច្រកទ្វារផ្តល់ទិដ្ឋាការ RE-ENTRY PERMIT ជូនគាត់មិនទាន់(ម៉ាស៊ីនមានតែមួយ) ។

ដូចនេះដើម្បីផ្តល់ទិដ្ឋាការ RE-ENTRY PERMIT ជូនគាត់ឱ្យបានលឿនក្រុមការងារយើង បានដឹកពួកគាត់ត្រឡប់ទៅស្រុកអារញ្ញប្រាថេតវិញដើម្បីធ្វើទិដ្ឋាការ RE-ENTRY PERMIT ជូនគាត់នៅទីនោះមួយកន្លែងទៀត ។ អនុវត្តរបៀបនេះ ងាយស្រួលដល់ពួកគាត់នៅពេលដែលគាត់បានទិដ្ឋាការ RE-ENTRY PERMITនេះហើយ ពេលមកដល់ច្រកទ្វារគ្រាន់តែ នគរបាលអន្តោប្រវេសន៍ថៃ ប្រថាប់ត្រាលិខិតឆ្លងដែន ចេញជូនគាត់ជាការស្រេច។ សូមបញ្ជាក់ជូនលោកនាយ មេត្តាជ្រាបផងដែរ ក្រៅពីការជួយសម្របសម្រួលគ្រប់មធ្យោបាយ ប៉ុស្តិ៍នូវបានចែកបាយនឹងទឹកសុទ្ធដល់ពួកគាត់ ដែលធ្វើដំណើរមកដល់ច្រកទ្វារខ្លងលឹកជាបន្តបន្ទាប់ ដោយមិនគិតពីចំនួនឡើយ ៕

## ពលករខ្មែរ ៨នាក់ បានស្លាប់ និងរបួស ៧នាក់ ក្នុងគ្រោះថ្នាក់ចរាចរណ៍ នៅថៃ

https://dap-news.com/national/2023/04/10/324652/ ByKD102Posted on April 10, 2023

**ភ្នំពេញ៖ ប្រជាពលរដ្ឋកម្ពុជាចំនួន ៨នាក់បាត់បង់ជីវិត និងរបួស៧នាក់ ក្នុងគ្រោះថ្នាក់ចរាចរណ៍ដ៏រន្ធត់មួយរវាង រថយន្តដឹកអ្នកដំណើរ និងរថយន្តកុងតឺន័រ នៅខេត្តឈុនបុរី ប្រទេសថៃ កាលពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៣។**

យោងតាមសាររំលែកទុក្ខ របស់ស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ នាថ្ងៃទី១០ មេសា នេះ បានឲ្យដឹងថា «មានក្តីក្តុកក្តួលរន្ធត់ចិត្តឥតឧបមា ក្រោយពីបានទទួលព័ត៌មានអំពី គ្រោះថ្នាក់ចរាចរណ៍ដ៏រន្ធត់មួយរវាង រថយន្តដឹកអ្នកដំណើរ និងរថយន្តកុងតឺន័រ នៅខេត្តឈុនបុរី ប្រទេសថៃ នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៣ ដែលបានឆក់យកជីវិតពលករកម្ពុជា ចំនួន៨នាក់ និងអ្នករបួសចំនួន ៧នាក់ទៀត កំពុងសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ»។ ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ សោកស្តាយគ្មានអ្វីប្រៀបផ្ទឹមបាន ចំពោះមរណភាពនេះ និងចូលរួមរំលែកទុក្ខដ៏សោកសង្រេងបំផុតជាមួយក្រុមគ្រួសារ សាច់ញាតិនៃសព ៕

# ថ្ងៃទី១២ ខែ មេសា ឆ្នាំ២០២៣

## សមត្ថកិច្ច កម្ពុជា នឹងបញ្ជូនជនសង្ស័យឆបោកតាមទូរស័ព្ទជនជាតិ ជប៉ុន ១៩ នាក់ទៅប្រទេសវិញនៅព្រឹកស្អែក

https://www.kampucheathmey.com/global-news/493465 ថ្ងៃចន្ទ ១០ មេសា ២០២៣ Sok Chivon

ជប៉ុនបានបញ្ជូនក្រុមអ្នកស៊ើបអង្កេតមកព្រះរាជាណាចក្រកម្ពុជាដើម្បីនាំខ្លួនជនជាតិជប៉ុនចំនួន ១៩ នាក់ដែលត្រូវបានចាប់ខ្លួនពីបទឆបោកតាមទូរស័ព្ទ ក្រោយធ្វើសកម្មភាពពីប្រទេសកម្ពុជា ផ្តោតគោលដៅទៅលើជនជាតិជប៉ុន ។ អ្នកស៊ើបអង្កេតប្រហែល ៥០ នាក់បានចាកចេញពីអាកាសយានដ្ឋាន Haneda នៃទីក្រុងតូក្យូ និងមកកាន់ទឹកដី នៃព្រះរាជាណាចក្រកម្ពុជានៅព្រឹកថ្ងៃចន្ទនេះ ហើយប៉ូលិសជប៉ុនគ្រោងនឹងនាំខ្លួនជនសង្ស័យទៅប្រទេសវិញនៅព្រឹកថ្ងៃអង្គារ ដើម្បីអនុវត្តទោសតាមផ្លូវច្បាប់ ។

នាយកដ្ឋានប៉ូលិសក្រុងតូក្យូ ទទួលបានដីកាចាប់ខ្លួនមនុស្ស ១៩ នាក់ ដែលមានអាយុចន្លោះពី ២៥ ទៅ ៥៥ ឆ្នាំ បន្ទាប់ពីជនសង្ស័យទាំងនេះត្រូវបានចោទប្រកាន់ថាបោកប្រាស់ប្រាក់ប្រហែល ១,៩០០ ដុល្លារពីអ្នករស់នៅទីក្រុងតូក្យូម្នាក់ដែលមានវ័យ ៦០ ឆ្នាំ ។

សមាជិកក្រុមនេះត្រូវបានគេជឿថា បានធ្វើប្រតិបត្តិការចេញពីបន្ទប់សណ្ឋាគារមួយកន្លែងក្នុងក្រុងព្រះសីហនុកាលពីខែមករា ខណៈក្នុងប្រតិបត្តិការនោះ សមត្ថកិច្ចកម្ពុជាក៏បានរកឃើញបញ្ជីឈ្មោះពលរដ្ឋជប៉ុនដែលគេជឿថា ជាមុខសញ្ញាសម្រាប់ជនសង្ស័យទាក់ទងទៅឆបោក និងទូរសព្ទមួយចំនួនធំពីបន្ទប់សណ្ឋាគារ ខណៈវត្ថុតាងទាំងនោះសមត្ថកិច្ចកម្ពុជាក៏បានប្រគល់ឲ្យភាគីជប៉ុនហើយផងដែរ ៕ **ប្រែសម្រួលដោយ ៖ ជីវ័ន្ត**

## មន្ត្រីច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែតសហការជាមួយភាគីថៃ ពន្លឿនលិខិតឆ្លងដែនជូនពលករកម្ពុជា អាចធ្វើដំណើរមកលេងស្រុកកំណើតឱ្យឆាប់រហ័ស ក្នុងឱកាសបុណ្យចូលខ្មែរ

https://btv.com.kh/article/22137 2023/04/11 01:29:57 pm

បន្ទាយមានជ័យ៖ នគរបាលអន្តោប្រវេសន៍ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត សហការជាមួយភាគីថៃ ដើម្បីពន្លឿនការប្រថាប់ត្រាលិខិតឆ្លងដែនជូនពលករកម្ពុជា ធ្វើដំណើរចូលមកលេងស្រុកកំណើតឱ្យឆាប់រហ័ស ក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីខ្មែរ។ ដោយអនុវត្តតាមការណែនាំរបស់លោកឧត្តមសេនីយ៍ត្រី អ៊ី ចំរើន នាយប៉ុស្តិ៍នគរបាលអន្តោប្រវេសន៍ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត និងមានការឯកភាពពីភាគីថៃផងនោះ ដើម្បីសម្រួល និងពន្លឿនការប្រថាប់ត្រាលិខិតឆ្លងដែនជូនបងប្អូនពលករ កុំឲ្យមានការរងចាំយូរនៅឯច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក មន្ត្រីនគរបាលអន្តោប្រវេសន៍ក្រុមការងាររបស់ប៉ុស្តិ៍ បានសហការជាមួយអាជ្ញាធរក្រុង បានយករថយន្តដឹកជញ្ជូនពលករខ្មែរដែលមកដល់ច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក ដែលរង់ចាំយូរ ដោយមូលហេតុមកពីនគរបាលអន្តោប្រវេសន៍ថៃ នៅច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក ដែលជាកន្លែងផ្តល់ទិដ្ឋាការ RE-ENTRY PERMIT ជូនគាត់មិនទាន់មូលហេតុ (ម៉ាស៊ីនមានតែមួយ)បានជាបណ្តាលឲ្យបងប្អូនពលករដែលឆ្លងដែនមកមានការកកស្ទះរងចាំយូរយ៉ាងដូច្នេះ។

លោកឧត្តមសេនីយ៍ត្រី អ៊ី ចំរើន នាយប៉ុស្តិ៍នគរបាលអន្តោប្រវេសន៍ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានបន្តទៀតថា ដូចនេះដើម្បីសម្រួល និងពន្លឿនការផ្តល់ទិដ្ឋាការ RE-ENTRY PERMIT ជូនដល់ពួកគាត់ឱ្យបានលឿន និងឆាប់រហ័សនោះក្រុមការងារយើងបានជួយដឹកពួកគាត់ត្រឡប់ទៅស្រុកអារញ្ញប្រាថេតវិញ ដើម្បីធ្វើទិដ្ឋាការ RE-ENTRY PERMIT ជូនគាត់នៅទីនោះមួយកន្លែងទៀតដែលជាភាពងាយស្រួលសម្រាប់ពួកគាត់ក្នុងការ

ឆ្លងដែនមក ។ ការអនុវត្តរបៀបនេះ ងាយស្រួលដល់ពួកគាត់នៅពេលដែលគាត់បានទិដ្ឋាការ RE-ENTRY PERMITនេះហើយ ពេលមកដល់ច្រកទ្វារគ្រាន់តែនគរបាលអន្តោប្រវេសន៍ថៃប្រថាប់ត្រាលិខិតឆ្លងដែនចេញជូនគាត់ជាការស្រេច។

សូមបញ្ជាក់ថា ក្រៅពីការជួយសម្របសម្រួលគ្រប់មធ្យោបាយជូនបងប្អូនពលករខ្មែរទាំងអស់ ក្រុមការងារបានចែកបាយនឹងទឹកសុទ្ធជូនដល់បងប្អូនដែលធ្វើដំណើរមកដល់ច្រកទ្វារខ្លងលឹកជាបន្តបន្ទាប់ផងដោយដោយមិនគិតពីចំនួនអ្វីនោះឡើយ ដើម្បីខ្មែរជួយខ្មែរធ្វើយ៉ាងឲ្យបងប្អូនទាំងអស់បានឆាប់វិលត្រលប់មកដល់ផ្ទះសម្បែងដើម្បីជួបជុំសាច់ញាតិនិងចូលរួមក្នុង ឱកាសបុណ្យចូលឆ្នាំផងដែរ ៕

## ពលករខ្មែរវិលត្រឡប់ពីថៃចូលកម្ពុជាតាមច្រកប៉ោយប៉ែតនៅតែមមាញឹក

https://www.postkhmer.com/national/2023-04-11-1706-249019.html យុត សុភចរិយា | Publication date 11 April 2023 | 17:06 ICT

**បន្ទាយមានជ័យៈ** ស្ថានភាពពលករខ្មែរសម្រុកចេញពីប្រទេសថៃ ចូលមកកម្ពុជាតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតនៅតែបន្តមានភាពមមាញឹកគួរឱ្យកត់សម្គាល់ ប៉ុន្តែភាពកកស្ទះនៅមុខច្រកទ្វារព្រំដែនអន្តរជាតិមួយនេះត្រូវបានកាត់បន្ថយ។ នេះបើតាមសម្ដីមន្ត្រីនគរបាលទំនាក់ទំនងកិច្ចការព្រំដែន កម្ពុជា-ថៃ។

លោក អ៊ី ចម្រើន នាយប៉ុស្តិ៍នគរបាលអន្តោប្រវេសន៍ប្រចាំច្រកទ្វារអន្តរជាតិប៉ោយប៉ែត បានប្រាប់ ភ្នំពេញប៉ុស្ដិ៍ថា ក្នុងរដូវកាលបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិឆ្នាំ ២០២៣ នេះ ពលរដ្ឋខ្មែរចំណាកស្រុកទៅធ្វើការនៅក្នុងប្រទេសថៃ បាននាំគ្នាសម្រុកវិលត្រឡប់មកលេងស្រុកកំណើតនៅក្នុងប្រទេសកម្ពុជា វិញយ៉ាងច្រើនកុះករ ខុសប្លែកពីបណ្ដាឆ្នាំមុនៗ ជាពិសេស ក្នុងរយៈពេល៣ថ្ងៃកន្លងមកនេះ (ថ្ងៃទី ៨-៩-១០ ខែមសា) ពលករខ្មែរប្រមាណពី ៣-៤ ពាន់នាក់ ក្នុង ១ ថ្ងៃ បានសម្រុកវិលត្រឡប់ចូលមកកម្ពុជាវិញធ្វើឱ្យមានភាពកកស្ទះខ្លាំងនៅឯច្រកព្រំដែនក្នុងទឹកដីថៃ។ លោកថ្លែងថា៖ «គិតត្រឹមថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០២៣ លំហូរពលករខ្មែរវិលត្រឡប់ពីធ្វើការងារក្នុងប្រទេសថៃ ចូលមកកម្ពុជាតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត នៅតែមានភាពមមាញឹកគួរឱ្យកត់សម្គាល់ប៉ុន្តែមិនមានភាពកកស្ទះទៀតនោះទេ បន្ទាប់ពីអាជ្ញាធរខេត្តជាប់ព្រំដែននៃប្រទេសទាំង ២ (ខេត្តបន្ទាយមានជ័យ ប្រទេសកម្ពុជា និងខេត្តស្រះកែវប្រទេសថៃ) បានសហការគ្នាជួយសម្របសម្រួលពន្លឿននីតិវិធី ក្នុងការងារបំពេញទម្រង់បែបបទជូនដល់ពលករខ្មែរយើង»។

ជាមួយគ្នានេះ លោក ង៉ោ ម៉េងជ្រួន អភិបាលរងខេត្តបន្ទាយមានជ័យបានប្រាប់ ភ្នំពេញ ប៉ុស្ដិ៍ថា ដើម្បីដោះស្រាយភាពកកស្ទះរបស់ពលករខ្មែរនៅមុខច្រកទ្វារព្រំដែនអន្តរជាតិក្លងឡឹក-ប៉ោយប៉ែត ក្នុងទឹកដីថៃនោះ រូបលោកទទួលបានការចាត់តាំងពីលោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ ឱ្យដឹកនាំក្រុមការងារថ្នាក់ខេត្តប្រមាណជិត ១០០ នាក់ ចុះទៅសហការជាមួយអាជ្ញាធរខេត្តស្រះកែវ ដើម្បីជួយសម្របសម្រួលពន្លឿននីតិវិធីជូនដល់ពលករខ្មែរឆាប់បានត្រឡប់ចូលមកស្រុកកំណើតវិញ ។ លោក ម៉េងជ្រួន បានបន្តថា ដោយមានការឯកភាពពីអាជ្ញាធរខេត្តស្រះកែវប្រទេសថៃ ក្រុមការងាររបស់លោកបាននាំយករថយន្តដឹកអ្នកដំណើរចំនួន១០គ្រឿង ចូលទៅជួយអន្តរាគមន៍ដឹកជញ្ជូនពលករខ្មែរ ពីច្រកទ្វារព្រំដែនអន្តរជាតិក្លងឡឹកទៅកាន់មណ្ឌលសំចតនៃការិយាល័យនគរបាលអន្តោប្រវេសន៍ថៃក្នុងស្រុកអារញ្ញ ដើម្បីមកបំពេញទម្រង់បែបបទឯកសារនានាទៅតាមផ្លូវច្បាប់ និងដឹកពួកគេពីមណ្ឌលសំចតនេះ ទៅកាន់ច្រកទ្វារព្រំដែន ដើម្បីបោះត្រាចេញ និងឆ្លងចូលមកក្នុងទឹកដីកម្ពុជាតែម្តង ។

លោកបានបញ្ជាក់ថា៖«ការដឹកជញ្ជូនពលករខ្មែរយើងមកបំពេញបែបបទឯកសារនៅមណ្ឌលសំចតនៃការិយាល័យនគរបាលអន្តោប្រវេសន៍ថៃក្នុងស្រុកអារញ្ញនៃខេត្តស្រះកែវនេះ គឺដើម្បីសម្រួលដល់ការងាររបស់មន្ត្រីអន្តោ

ប្រវេសន៍ថៃនៅឯច្រកទ្វារព្រំដែនអន្តរជាតិ ក្លងឡឹក ដែលមានចំនួនតិចផង និងដើម្បីឃ្លាំមើលពីសុខទុក្ខរបស់ពលរដ្ឋយើងផង»។ លោកបានបន្ថែមថា៖ «នៅក្នុងការបំពេញទម្រង់បែបបទនោះ អាជ្ញាធរថៃបានរកឃើញមានពលករខ្មែរយើងមួយចំនួនមានការប្រើប្រាស់លិខិតឆ្លងដែនផុតសុពលភាព និងខ្លះទៀតបានរកឃើញថា មានកូននៅក្នុងបន្ទុក ខណៈពេលចូលមកធ្វើការក្នុងប្រទេសថៃ ប្រកាសថា នៅលីវ និងមិនមានកូន។ ប៉ុន្តែករណីនេះក៏ត្រូវបានភាគីថៃយល់ព្រមទទួលយកតាមការសម្របសម្រួលដំណោះស្រាយតាមនីតិវិធីពីក្រុមការងារនៃអគ្គកុងស៊ុលខ្មែរប្រចាំខេត្តស្រះកែវផងដែរ»។

បើតាមលោក ម៉េងជ្រួន មកទល់រសៀលថ្ងៃ ១១ ខែមេសា ឆ្នាំ ២០២៣ ពលករខ្មែរជាង ៣ ០០០ នាក់ ត្រូវបានក្រុមការងាររបស់លោក ជួយអន្តរាគមន៍សម្របសម្រួលបំពេញទម្រង់បែបបទតាមនីតិវិធី និងដឹកជញ្ជូនពីមណ្ឌលសំចតក្នុងស្រុកអារញ្ញប្រទេសថៃមកកាន់ច្រកព្រំដែនអន្តរជាតិក្លងឡឹក-ប៉ោយប៉ែត ដើម្បីបោះត្រាចេញ និងឆ្លងចូលមកកម្ពុជាដោយសុវត្ថិភាព៕

## ទូតកម្ពុជានៅថៃ កំពុងទាមទារសំណងពីក្រុមហ៊ុនធានារ៉ាប់រង បន្ទាប់ពីមានពលករខ្មែរស្លាប់ និងរងរបួសក្នុងគ្រោះថ្នាក់ចរាចរណ៍

https://news.btv.com.kh/article/22158 2023/04/11 05:22:59 pm

ភ្នំពេញ៖ អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឯកឧត្តម អាន សុខឿន នាល្ងាចថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣ បានឲ្យដឹងថា ស្ថានទូតកម្ពុជាប្រចាំទីក្រុងបាងកក កំពុងសហការជាមួយអាជ្ញាធរថៃដើម្បីទាមទារសំណងពីក្រុមហ៊ុនធានារ៉ាប់រងជូនជនរងគ្រោះ ក្នុងឧបទ្វេវហេតុគ្រោះថ្នាក់។ ជុំវិញព័ត៌មានអំពីគ្រោះថ្នាក់ចរាចរណ៍រវាងរថយន្តដឹកអ្នកដំណើរ និងរថយន្តកុងតឺន័រ ដែលបានកើតឡើងកាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ ២០២៣ នៅខេត្តឈុនបុរី ប្រទេសថៃ អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា បានឲ្យដឹងថា បន្ទាប់ពីទទួលបានព័ត៌មានខាងលើភ្លាម ស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ បានទាក់ទងនិងធ្វើការជាមួយអាជ្ញាធរមានសមត្ថកិច្ច មន្ទីរពេទ្យ និងអ្នកពាក់ព័ន្ធ នៅក្នុងប្រទេសថៃ។

អ្នកនាំពាក្យរូបនេះបន្តថា យោងតាមរបាយការណ៍របស់ស្ថានទូត គ្រោះថ្នាក់ខាងលើបានបណ្តាលឱ្យពលរដ្ឋខ្មែរចំនួន៣រូប (ម្នាក់ជាស្ត្រីមានផ្ទៃពោះ៩ខែ) បាត់បង់ជីវិត និង ចំនួន១១រូបផ្សេងទៀត រងរបួស (ក្នុងនោះមាន៨រូប រងរបួសធ្ងន់ធ្ងរ)។ អ្នកនាំពាក្យក្រសួងការបរទេស គូសបញ្ជាក់ថា បន្ថែមលើលិខិតចូលរួមរំលែកទុក្ខជាមួយនឹងគ្រួសារនៃសព ស្ថានទូតកម្ពុជាបានជួយសម្របសម្រួលជាមួយអាជ្ញាធរថៃលើឯកសារពាក់ព័ន្ធ ដើម្បីសុំនាំយកសពទៅធ្វើបុណ្យតាមប្រពៃណី។ ជាមួយគ្នា ស្ថានទូតកម្ពុជា ក៏បានចុះផ្ទាល់ដល់ទីតាំងតម្កល់សព ដែលស្ថិតនៅក្នុងវត្តសោធរនិមិត្ត (ខេត្តសាក់មុតប្រាកាន) ហើយបាននិងកំពុងចុះសាកសួរសុខទុក្ខជនរងគ្រោះ ដែលកំពុងទទួលការព្យាបាលនៅក្នុងប្រទេសថៃព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួនដល់គ្រួសារសពនិងជនរងគ្រោះផងដែរ។

លើសពីនេះ ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បាននិងកំពុងសហការជាមួយអាជ្ញាធរថៃ គ្រួសារជនរងគ្រោះ និងអ្នកពាក់ព័ន្ធ ដើម្បីដោះស្រាយករណីគ្រោះថ្នាក់ចរាចរណ៍ខាងលើ និងទាមទារសំណងពីក្រុមហ៊ុនធានារ៉ាប់រងជូនជនរងគ្រោះ៕

## ជនជាតិខ្មែរ ៥នាក់ត្រូវចាប់ខ្លួននៅឧទ្យានជាតិ Khao Yai ប្រទេសថៃ រួមនឹងឈើចន្ទគ្រឹះស្នា ១គីឡូក្រាម

https://www.khmertimeskh.com/501271638// Khmer Times April 11, 2023

ពលរដ្ឋខ្មែរ ៥នាក់ត្រូវបានចាប់ខ្លួនពីបទលួចឈើចន្ទគ្រឹះស្នាពីឧទ្យានជាតិ Khao Yai របស់ប្រទេសថៃ ក្នុងខេត្តនគររាជសីមាភាគឦសាន។ មន្ត្រីឧទ្យានុរក្សបានរកឃើញរបស់របរជាប់ខ្លួន មានដូចជា ចំណិតឈើចន្ទគ្រឹះស្នា ១គីឡូក្រាម កាំបិត រណា ពិល និងព្រលាក។

លោក Veera Khunchairak នាយកតំបន់ការពារទី១ ក្នុងខេត្ត Prachin Buri បាននិយាយកាលពីម្សិលមិញ (ថ្ងៃអាទិត្យ) ថា មន្ត្រីឧទ្យានុរក្សបានតាមដានក្រុមនេះ ចាប់តាំងពីពួកគេមួយចំនួនបានលួចចូលក្នុងតំបន់ឧទ្យានកាលពីថ្ងៃសុក្រមុន។ អ្នកទាំង៥នាក់ត្រូវចាប់បាននៅក្នុងព្រៃ Khao Laem ក្នុងសង្កាត់ Mu Si ។ មានជនជាតិវៀតណាមប្រហែល ៥០នាក់ ភាគច្រើនមកពីខេត្ត Quang Binh ត្រូវបានចាប់ខ្លួនដោយមន្ត្រីថៃចាប់តាំងពីឆ្នាំ ២០០៨ ហើយ ៤០នាក់ក្នុងចំណោមពួកគេត្រូវបានគេចាប់ខ្លួន ពីបទលួចឈើចន្ទគ្រឹស្នាពីដែនជម្រកសត្វព្រៃ Phu Khiao ក្នុងខេត្ត Chaiyaphum ។ ក្រុមចុងក្រោយមានគ្នា៥នាក់ត្រូវបានចាប់ខ្លួននៅស្រុក Khon Sarn ខេត្ត Chaiyaphum កាលពីថ្ងៃទី២៦ ខែមីនា ជាមួយនឹងឈើចន្ទគ្រឹះស្នា ចំនួន ១០៣,៥គីឡូក្រាម។ ឈើចន្ទគ្រឹះស្នា (Agarwood) មានក្លិនក្រអូបនៅពេលដែលវាត្រូវបានចំរ៉ាញ់ និងមានតម្លៃខ្ពស់។ ខ្លឹមចន្ទដែលមានគុណភាពខ្ពស់ត្រូវបានគេប៉ាន់ប្រមាណថាមានតម្លៃចន្លោះពី ១៥,០០០ ទៅ ២០,០០០ បាត/គីឡូក្រាម៕ *Thai PBS World*

## សម្តេចតេជោ ហ៊ុន សែន ឱ្យបញ្ចេញរថយន្តរាប់សិបគ្រឿងដឹកពលករខ្មែរពីព្រំដែនកម្ពុជា-ថៃទៅស្រុកកំណើត

https://www.kampucheathmey.com/local-news/494397 ថ្ងៃពុធ ១២ មេសា ២០២៣ដោយ deth leng

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាបានឱ្យបញ្ចេញរថយន្តរាប់សិបគ្រឿងដឹកពលករខ្មែរ ដែលធ្វើដំណើរមកពីប្រទេសថៃ ទៅកាន់រាជធានី ខេត្ត ដែលជាគោលដៅរបស់ពួកគាត់ ដើម្បីចូលរួមពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរនាពេលខាងមុខ។

លោក សេក សុខុម អ្នកនាំពាក្យសាលាខេត្តបន្ទាយមានជ័យប្រាប់កម្ពុជាថ្មីនៅព្រឹកថ្ងៃទី ១២ ខែមេសាថា ពលករខ្មែរដែលទៅបម្រើការងារនៅថៃ បានសម្រុកចូលមកលេងស្រុកកំណើតក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរនេះក្នុង ១ ថ្ងៃប្រមាណ ១ ៥០០ ទៅ ២០០០ នាក់ ខណៈអាជ្ញាធរព្រំដែនកំពុងខិតខំធ្វើការពន្លឿនឯកសារឱ្យពួកគាត់ឆាប់បានចូលមក។ លោកថា ជិត១ សប្តាហ៍ហើយ ពលករខ្មែរនៅលើទឹកដីថៃ មានការកកស្ទះ ហើយអាជ្ញាធរមិនមានការរឹតបន្តឹងនោះទេ ខណៈពួកគាត់បានចាក់វ៉ាក់សាំងគ្រប់ដូសរួចហើយ។

អ្នកនាំពាក្យរូបនេះ បញ្ជាក់ថា នៅថ្ងៃនេះ នៅតែមានពលករខ្មែរសម្រុកមកច្រើន ហើយសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានផ្តល់រថយន្តដឹកពលករខ្មែរមកពីថៃ មិនគិតប្រាក់ពីខេត្តបន្ទាយមានជ័យ បាត់ដំបង ប៉ៃលិន។ រថយន្តប្រមាណ ៥០ ទៅ ១០០ គ្រឿង ដោយដឹកមិនគិតថ្លៃ ចាប់ពីថ្ងៃទី ១៤ រហូតដល់ថ្ងៃទី ១៦ ខែមេសានេះ។ រដ្ឋបាលខេត្តបន្ទាយមានជ័យ បានបញ្ជាក់ថា បញ្ហាដែលនាំឱ្យមានមនុស្សកកស្ទះនៅតំបន់ច្រកទ្វារព្រំដែនប៉ោយប៉ែត គឺព្រោះតែប្រជាជនកំពុងអង្គុយរង់ចាំពិនិត្យបំពេញបែបបទនៅខាងទឹកដីថៃ មុននឹងឆ្លងមកទឹកដីកម្ពុជា។ ចំណែកខាងសមត្ថកិច្ចកម្ពុជា ក៏បានយកចិត្តទុកដាក់ ដើម្បីសម្របសម្រួលពន្លឿននីតិវិធី ធ្វើយ៉ាងណាសម្រួលដល់ប្រជាជនខ្មែរដែលមកពីប្រទេសថៃឆាប់បានទៅស្រុកកំណើតរបស់ខ្លួនផងដែរ៕

# ថ្ងៃទី១៨ ខែ មេសា ឆ្នាំ២០២៣

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិវៀតណាម ១នាក់

https://freshnewsasia.com/index.php/en/localnews/286478-2023-04-12-11-09-50.html 2023-04-12 06:09pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១០ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិវៀតណាម ១នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្ដេចក្រឡាហោម សរុប ៨៣៥ករណី មានមនុស្ស ២,០៩៨នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៨០២សំណើ និងបិទសំណុំរឿង ២៧៤សំណើ (រកឃើញមនុស្ស ១,២១៦នាក់, ឃាត់ខ្លួនជនសង្ស័យ ១២៩នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣៣ករណី៕

## តុលាការកំពូល ជម្រះបណ្តឹងសាទុក្ខ
## អតីតអ្នកតំណាងរាស្ត្រ អះម៉ាត់យ៉ះយ៉ា និងក្មួយប្រុស ពាក់ព័ន្ធការលក់ដូរស្ត្រីខ្មែរ២នាក់ ទៅធ្វើជាទាសករគេ អស់រយៈពេលជិត ១៣ ឆ្នាំ នៅទីក្រុងអារ៉ាប់

https://cen.com.kh/archives/647868.html Posted ByPen Srey NeatApril 13, 2023

ភ្នំពេញ: តុលាការកំពូល កាលពីព្រឹកថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០២៣ បានធ្វើការជំនុំជម្រះ លើបណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ ឈ្មោះ អះម៉ាត់ យ៉ះយ៉ា និង ក្មួយប្រុសម្នាក់ ដែលត្រូវបានតុលាការជាន់ទាប កាលពីអំឡុងឆ្នាំ ២០១៩ កាត់ទោស ពួកគេទាំង២នាក់ដាក់គុក ក្នុងម្នាក់ៗ កំណត់ ១៥ ឆ្នាំ ជាប់ពាក់ព័ន្ធនឹងការសង្ស័យការនាំចេញដោយមិនស្របច្បាប់ នូវពលករខ្មែរចំនួនជាង៣០០នាក់ ទៅធ្វើការ នៅប្រទេសអារ៉ាប៊ីសាអូឌីត និងបានបណ្ដាលឲ្យស្ត្រីខ្មែរចំនួន២នាក់(ជនរងគ្រោះ) ត្រូវបានគេលក់ដូរដូចសត្វធាតុ ពីគ្រួសារអារ៉ាប់មួយ ទៅគ្រួសារផ្សេងទៀត និងត្រូវបានគេបង្ខំឲ្យធ្វើការដូចទាសករ ដោយគ្មានប្រាក់ខែអស់រយៈពេលជិត ១៣ ឆ្នាំ នៅក្នុងអារ៉ាវសាអូឌីត ពីឆ្នាំ ២០០៤ រហូតដល់ឆ្នាំ ២០១៧។

លោក គង់ ស្រ៊ីម ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ នៃតុលាការកំពូល បានថ្លែងថា៖ នៅក្នុងរឿងក្តីឧក្រិដ្ឋនេះ ជនជាប់ចោទឈ្មោះ អះម៉ាត់ យ៉ះយ៉ា ភេទ ប្រុស អាយុ ៧០ ឆ្នាំ ជាខ្មែរអ៊ីស្លាម , ជាអតីតអ្នកតំណាងរាស្ត្រ និងជារដ្ឋលេខាធិការ ក្រសួងសាធារណៈការនិងដឹកជញ្ជូន និង ជាប្រធានក្រុមហ៊ុនAccent Group និងឈ្មោះ អ៊ីស្មាអែល ពិនឧស្មាន ភេទ ប្រុស អាយុ ៥០ ឆ្នាំ ជនខ្មែរអ៊ីស្លាម និង ជាអតីតមន្ត្រីរាជការ ធ្វើការនៅក្រសួងសាធារណៈការនិងដឹកជញ្ជូន ត្រូវបានសាលាដំបូងខេត្តរាជធានីភ្នំពេញ កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៩ កាត់ទោស ដាក់ពន្ធនាគារ ក្នុង ម្នាក់ៗ កំណត់ ១៥ ឆ្នាំ និងបង្គាប់ឱ្យសងជំងឺចិត្តពួកគេទាំង២នាក់ ពូនិងក្មួយ ត្រូវរួមគ្នាសងជនរង

គ្រោះចំនួន២នាក់ សរុប ២០០លានរៀល ពីបទ: នាំចេញដោយមិនស្របច្បាប់ សម្រាប់ឆ្លងដែន តាមមាត្រា ១១ នៃ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិង ការធ្វើអាជីវកម្មផ្លូវភេទ។

ជនជាប់ចោទទាំង២នាក់ បានប្តឹងឧទ្ធរណ៍ ។ តែសាលាឧទ្ធរណ៍រាជធានីភ្នំពេញ បានតម្កល់ទណ្ឌកម្មរបស់ពួកគេរក្សាទុកជាបានការដដែល ។ ពួកគេក៏បានបន្តប្តឹងសាទុក្ខ មកកាន់តុលាការកំពូលទៀត។ នៅក្នុងចំណោមពួកគេទាំង២នាក់ ជនជាប់ចោទឈ្មោះ អ៊ីស្មាអែល ពិនឧស្មាន ត្រូវបានឃាត់ខ្លួនកាលពីថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៨ នៅរាជធានីភ្នំពេញ រីឯជនជាប់ចោទឈ្មោះ អះម៉ាត់យ៉ះយ៉ា ត្រូវបានចាប់ឃាត់ និងឃុំខ្លួន កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០២១ បន្ទាប់ពី តុលាការរាជធានីភ្នំពេញ បានប្រកាសសាលក្រម និងសម្រេចផ្តន្ទាទោសគាត់ដាក់ពន្ធនាគារ កំណត់ ១៥ ឆ្នាំ។

គួរបញ្ជាក់ថា: នាពេលសវនាការ ជនជាប់ចោទទាំង២នាក់ ពូ និង ក្មួយ បានឆ្លើយបដិសេធ ចំពោះការចោទប្រកាន់ និង ការផ្តន្ទាទោស ពួកគេ អំពើ សំណាក់ តុលាការរាជធានីភ្នំពេញ និង តុលាការឧទ្ធរណ៍ រាជធានីភ្នំពេញ។ ពួកគាត់ បានសំណូមពរ ដល់ ចៅក្រមប្រឹក្សាជំនុំជម្រះតុលាការកំពូល មេត្តាជួយរកយុត្តិធម៌ និងសម្រេចដោះលែងពួកគាត់ ឱ្យមានសេរីភាពវិញ។ នៅក្នុងសំណុំរឿងនេះ តុលាការកំពូលនឹងប្រកាសដីកា នៅព្រឹកថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០២៣ នេះ ៕ រក្សាសិទ្ធដោយ : ចន្ទា ភា

## តុលាការតៃវ៉ាន់ កាត់ទោសមនុស្ស៩នាក់ពីបទជួញដូរមនុស្សនៅកម្ពុជា

https://www.rfi.fr/km//20230413-?ref=tgi ចុះផ្សាយនៅថ្ងៃ៖ 13/04/2023 - 17:31

តុលាការមួយរបស់តៃវ៉ាន់ បានបើកសវនាការ កាលពីថ្ងៃព្រហស្បតិ៍ទី១៤ មេសា កាត់ទោសមនុស្សចំនួន៩នាក់ ដែលជាប់ចោទពីបទជួញដូរមនុស្ស នៅកម្ពុជា។ យោងតាមអាជ្ញាធរតៃវ៉ាន់ មានជនរងគ្រោះ ជាជនជាតិតៃវ៉ាន់ជាច្រើននាក់ ដែលត្រូវបានក្រុមទុច្ចរិត បោកបញ្ឆោតមកប្រទេសកម្ពុជា ដើម្បីធ្វើការជាជនឆបោកមនុស្ស តាមប្រព័ន្ធអ៊ីនធឺណិត។

ជនតៃវ៉ាន់៩នាក់ ជាប់ចោទពីបទជួញដូរមនុស្សនៅកម្ពុជា។ ជនទីមួយដែលជាក្បាលម៉ាស៊ីន នៃក្រុមទុច្ចរិតនេះ មានឈ្មោះ Lee Cheng-Hao ដែលយោងតាមអាជ្ញាធរតៃវ៉ាន់ គឺបានបង្ហោះផ្សាយសារតាមបណ្តាញសង្គម ដើម្បីអូសទាញមនុស្សជាច្រើននាក់ ឲ្យទៅធ្វើការនៅកម្ពុជា។ បណ្តាញទុច្ចរិតនេះ សន្យាឧ្យល់ជាច្រើនចំណុច ដូចជាថា នឹងផ្តល់ប្រាក់ខែច្រើនៗ ឬផ្តល់ប្រាក់កំចីយ៉ាងងាយស្រួលជាដើម។ តែជាតុពិត ជនរងគ្រោះត្រូវគេលក់បន្តទៅឲ្យបណ្តាញទុច្ចរិតផ្សេងទៀត នៅពេលទៅដល់កម្ពុជា។ នេះបើផ្អែកតាមការអះអាងរបស់តុលាការតៃវ៉ាន់។ លិខិតឆ្លងដែនរបស់ជនរងគ្រោះដែលចាញ់បោកគេ ត្រូវក្រុមទុច្ចរិតដកហូតទុក ហើយពួកគេត្រូវបង្ខំឲ្យធ្វើការ ដើម្បីឆបោកមនុស្សតាមបណ្តាញអ៊ីនធឺណិត។ តុលាការតៃវ៉ាន់អះអាងថាទៀតថា ជនរងគ្រោះ ត្រូវគេធ្វើទារុណកម្ម ហើយបើចង់ត្រលប់មកតៃវ៉ាន់វិញ គឺត្រូវសងប្រាក់ដ៏សន្ធឹកសន្ធាប់ ឬអាចត្រូវបានគេលក់បន្តទៅក្រុមបណ្តាញទុច្ចរិតផ្សេងទៀត។

Lee Cheng-Hao ត្រូវតុលាការកាត់ទោស ឲ្យជាប់ពន្ធនាគារ១៨ឆ្នាំ ខណៈជនសមគំនិតក្នុងបណ្តាញចំនួន៨នាក់ទៀត ត្រូវជាប់ទោសពន្ធនាគារ ពី ១១ និង ១៦ឆ្នាំ។ ជនជាប់ចោទទាំងអស់ បានអះអាងថា នឹងប្តឹងឧទ្ធរណ៍។

គួរបញ្ជាក់ថា យោងតាមអាជ្ញាធរតៃវ៉ាន់ គឺមានជនរងគ្រោះ ជាជនជាតិតៃវ៉ាន់ កាន់តែច្រើននាក់ បានចេញមករៀបរាប់ ពីដំណើរផ្សងព្រេងដ៏ឈឺចាប់របស់ខ្លួន ដែលបានធ្លាក់ខ្លួនចាញ់ការឆបោករបស់បណ្តាញទុច្ចរិត មកធ្វើ

ការនៅកម្ពុជា។ ជនរងគ្រោះអះអាងថា បានរងនូវការវាយដំ ទារុណកម្ម បង្ខាំងទុក និងធ្វើការមួយថ្ងៃ១៦ម៉ោងយ៉ាងតិច ដើម្បីឆបោកមនុស្សឲ្យបានច្រើននៅតាមអ៊ីនធឺណិត។

អ្នកនាំពាក្យពិសេសនៃអង្គការសហប្រជាជាតិ ស្តីពីសិទ្ធមនុស្សនៅកម្ពុជា បានលើកឡើងកាលពីឆ្នាំ២០២២ ថាជនរងគ្រោះដោយការជួញដូរមនុស្សនៅកម្ពុជា រស់នៅក្នុងស្ថាននរក រងអំពើទារុណកម្ម និងអាចមានករណីស្លាប់ថែមទៀត។ រដ្ឋាភិបាលតៃវ៉ាន់អះអាងថា ក្នុងឆ្នាំ២០២១ មានជនជាតិតៃវ៉ាន់ជាច្រើនពាន់នាក់ឮ ដែលបានមកដល់កម្ពុជា ហើយបានបាត់ដំណឹងសូន្យ មិនត្រលប់ទៅតៃវ៉ាន់វិញ៕

## ថវិកាហូរចូលកម្ពុជាតាមរយៈពលករខ្មែរនៅកូរ៉េម្នាក់ខ្ទង់១ពាន់ដុល្លាររាល់ខែជួយជីវភាពគ្រួសារ និងចរន្តសេដ្ឋកិច្ចជាតិ

https://www.kampucheathmey.com/business-economic/495984 ថ្ងៃចន្ទ ១៧ មេសា ២០២៣ ដោយ Sophal Tuon

គិតជាមធ្យមពលករខ្មែរនៅប្រទេសកូរ៉េខាងត្បូង បានផ្ញើថវិកាប្រមាណ ១ពាន់ដុល្លារជារៀងរាល់ខែ ជូនដល់គ្រួសារដែលកំពុងនៅក្នុងប្រទេសកម្ពុជា។ ដោយក្នុងមួយឆ្នាំ ថវិកាប្រមាណ ៦០០លានដុល្លារ បានហូរចូលមកកម្ពុជា តាមរយៈពលករខ្មែរនៅប្រទេសកូរ៉េខាងត្បូង។ នេះជាការបញ្ជាក់របស់លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ថ្លែងនៅក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ មហាសង្ក្រាន្តកូរ៉េ រៀបចំធ្វើឡើងនៅទីក្រុងអ៊ីយចុងប៊ូ នៃសាធារណរដ្ឋកូរ៉េ កាលពីថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៣ លោក អ៊ិត សំហេង បានសម្តែងក្តីរំភើប ដែលបានឃើញវត្តមានចូលរួមយ៉ាងច្រើនកុះកររបស់បងប្អូនខ្មែរ ទាំងអស់មកពីគ្រប់តំបន់ មានចម្ងាយឆ្ងាយរាប់រយគីឡូ និងចំណាយពេលច្រើនម៉ោងដើម្បីចូលរួមកម្មវិធីមហាសង្ក្រាន្តនេះ ជាពិសេសក៏មានវត្តមានរបស់លោក គីម ដុងគិន អភិបាលក្រុងអ៊ីយចុងប៊ូ។

ចាប់តាំងពីឆ្នាំ២០០០ លោកបណ្ឌិត អ៊ិត សំហេង បានមកទស្សនកិច្ចនៅសាធារណរដ្ឋកូរ៉េ ដើម្បីចចារជាមួយក្រសួងមុខរបរ និងការងារ និងស្ថាប័នពាក់ព័ន្ធកូរ៉េ ដើម្បីបង្កើតកិច្ចសហប្រតិបត្តិការលើវិស័យការងារ ជាពិសេសការទទួលយកពលករកម្ពុជា ដោយចាប់ផ្តើមពីការអនុវត្តប្រព័ន្ធបណ្តុះបណ្តាលជំនាញ និងបន្ទាប់មកប្រព័ន្ធអនុញ្ញាតមុខរបរ (EPS) នៅឆ្នាំ២០០៧ ដែលបានផ្តល់បរិយាកាសការងារកាន់តែល្អប្រសើរ និងការជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនប្រកបដោយសុក្រឹតភាព តម្លាភាព និងសុវត្ថិភាព។

សូមបញ្ជាក់ថា កម្ពុជា បានកសាងទំនាក់ទំនងការទូតជាមួយសាធារណរដ្ឋកូរ៉េ តាំងពីឆ្នាំ១៩៩៧ មកម្ល៉េះ។ ចាប់តាំងពីពេលនោះមក កិច្ចសហប្រតិបត្តិការលើគ្រប់វិស័យមានភាពរីកចម្រើន ជាពិសេសក្នុងឱកាសនៃកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធកាលពីចុងឆ្នាំ២០២២ថ្មីៗនេះ សម្តេចតេជោ ក៏បានជួបប្រធានាធិបតីសាធារណរដ្ឋកូរ៉េ ដើម្បីពិភាក្សាការងារ និងពង្រឹងចំណងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ឱ្យកាន់តែរីកចម្រើនមួយកម្រិតទៀត។ របាយការណ៍ឆ្នាំ ២០២១ បង្ហាញថា ពលករខ្មែរ ដែលកំពុងបម្រើការងារនៅប្រទេសកូរ៉េខាងត្បូងមានប្រហែល៥ម៉ឺននាក់៕

# ថ្ងៃទី២៤ ខែ មេសា ឆ្នាំ២០២៣

## សមត្ថកិច្ចកម្ពុជា បន្តទទួលបានបណ្តឹង ១៣ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៣២នាក់

https://freshnewsasia.com/index.php/en/localnews/287223-2023-04-18-02-04-44.html 2023-04-18 09:04am

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១៦ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ១៣ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស និងជនជាតិខ្មែរ ៣២នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៨៥០ករណី មានមនុស្ស ២,១៣២នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៨០៦សំណើ និងបិទសំណុំរឿង ២៧៥សំណើ (រកឃើញមនុស្ស ១,២១៩នាក់, ឃាត់ខ្លួនជនសង្ស័យ ១២៩នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ១៧៧ករណី៕

## ពលករខ្មែរចាប់ផ្តើមត្រឡប់ទៅប្រទេសថៃវិញ

https://kohsantepheapdaily.com.kh/article/1722554.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram បន្ទាយមានជ័យ១៩ ខែ មេសា ឆ្នាំ ២០២៣ ម៉ោង ១៤:៤៣

ខេត្តបន្ទាយមានជ័យ ៖ ក្រោយពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរហើយ ពលករបានចាប់ផ្តើមត្រឡប់ចូលទៅប្រទេសថៃវិញ ដើម្បីធ្វើការដោយស្របច្បាប់តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតជាហូរហែ ក្រោយពួកគេបានទៅជួបជុំក្រុមគ្រួសានៅស្រុកកំណើតរៀងខ្លួនៗ ខណៈពលករខុសច្បាប់បញ្ជូនពីថៃតាមរថយន្តទ្រុងមានជាង ២០០០នាក់ រយៈពេល៣ខែ ដើម ឆ្នាំ២០២៣ ។ នៅចំណុចបំពេញបែបបទចេញក្រៅប្រទេសច្រកទ្វារអន្តរជាតិប៉ោយប៉ែត គេឃើញមានពលករតម្រង់ជួរត្រៀបត្រា ដើម្បីបំពេញឯកសារឆ្លងចូលទៅទឹកដីថៃ ខណៈឥវ៉ាន់ ឬកាបូបរបស់ពួកគេជួលរទេះកម្មករអូសចូលព្រោងព្រៀត ។

អ្នកបើកបររថយន្តសាំយ៉ុងប៉ោយប៉ែត-កំពង់ធំម្នាក់និយាយថា រថយន្តខ្លួនវិលជុំរហូតមិនបានសម្រាកទេ ព្រឹកដឹកអ្នកដំណើរពីកំពង់ធំ, សៀមរាបមកក្រុងប៉ោយប៉ែត ។ លុះវេលារសៀលត្រូវត្រឡប់ទៅវិញ ដើម្បីប្រមូលដឹកពលករជាម៉ូយតាមផ្ទះ ។ ព្រឹកស្អែកបន្តបើទោះជាកាវិលត្រឡប់ពីប៉ោយប៉ែតទៅកំពង់ធំ មានអ្នកជិះតិចតួច ឬអត់ក៏ដោយ ។ ប៉ុន្តែថា ត្រឹមរយៈពេលយ៉ាងយូរ៤ទៅ៥ថ្ងៃ ក្រោយពិធីបុណ្យជាតិតែប៉ុណ្ណោះ។ អ្នកបើកបររថយន្តរូបនេះបន្តថា អ្នកដំណើរដែលខ្លួនដឹកជញ្ជូនមួយរយៈខ្លីនេះ ៩០%ជាពលករខ្មែរទៅមកប្រទេសថៃ ។សមត្ថកិច្ចឈរជើងនៅមាត់ច្រកទ្វារអន្តរជាតិប៉ោយប៉ែតម្នាក់ប្រាប់កោះសន្តិភាពថា ចាប់ពីព្រឹកថ្ងៃទី១៧ ដល់ថ្ងៃទី១៩ មេសា នេះ

ឃើញមានពលករត្រឡប់ទៅប្រទេសថៃជាបន្តបន្ទាប់ ប៉ុន្តែមិនច្រើនកកកុញដូចរយៈពេល២ទៅ៣ថ្ងៃមុនពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិដែលពួកគេត្រឡប់ពីប្រទេសថៃឡើយ។

## អភិបាលខេត្តបាត់ដំបង ចុះពិនិត្យស្ថានភាពនៅច្រកទ្វារអន្តរជាតិដូង ស្ថិតក្នុងស្រុកកំរៀង ក្រោយមានការផ្សព្វផ្សាយថាមន្ត្រីយកប្រាក់ពីពលករ និងប្រជាពលរដ្ឋ

https://freshnewsasia.com/index.php/en/localnews/287392-2023-04-19-07-56-14.html 2023-04-19 02:56pm

**(បាត់ដំបង)៖** នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣នេះ លោក សុខ លូ អភិបាលខេត្តបាត់ដំបង បានអញ្ជើញចុះពិនិត្យមើលស្ថានភាពជាក់ស្តែង នៅឯច្រកទ្វារអន្តរជាតិដូង ក្នុងស្រុកកំរៀង ដែលពលករកំពុងត្រឡប់ទៅប្រទេសថៃវិញ បន្ទាប់ពីបានមកលេងស្រុកកំណើត ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ។ ឆ្លៀតក្នុងឱកាសនោះ លោក សុខ លូ បានណែនាំបន្ថែមដល់មន្ត្រី និងសមត្ថកិច្ចដែលនៅប្រចាំការនៅច្រកទ្វារអន្តរជាតិដូងនេះ សូមខិតខំប្រឹងប្រែងធ្វើយ៉ាងណាដើម្បីបង្កលក្ខណៈងាយស្រួលដល់ដំណើរចេញចូល របស់ពលករត្រឡប់ទៅធ្វើការវិញដោយស្របច្បាប់ និងពន្លឿនក្នុងការបំពេញបែបបទឆ្លងដែនជូនប្រជាពលរដ្ឋ និងពលករឱ្យបានឆាប់រហ័ស ដោយក្នុងនោះត្រូវចៀសវាងការយកកំរៃសេវាក្រៅផ្លូវការពីប្រជាពលរដ្ឋ និងពលករដែលធ្វើដំណើរចេញ-ចូលច្រកទ្វារអន្តរជាតិដូងនេះ។

ការចុះពិនិត្យដោយផ្ទាល់របស់លោកអភិបាលខេត្តបាត់ដំបង នៅច្រកទ្វារអន្តរជាតិដូងនេះ បានធ្វើឡើងពីទទួលបានព័ត៌មានតាមបណ្តាញសង្គមថា មានការយកប្រាក់ពីបងប្អូនពលករ និងប្រជាពលរដ្ឋ ដែលចេញចូលនៅតាមច្រកទ្វារ អន្តរជាតិមួយនេះ។ តាមសេចក្តីរាយការណ៍ពីមន្ត្រីនគរបាលអន្តោប្រវេសន៍ប្រចាំច្រកអន្តរជាតិដូង បានបញ្ជាក់ថា ការរិះគន់នៅតាមបណ្តាញសង្គម Facebook គឺជាការយល់ច្រឡំ។ តាមពិតបងប្អូនខ្មែរ គឺពួកគាត់បានចំណាយថវិកាក្នុងម្នាក់ជាង ១,០០០បាត ដោយសារតែភាគីថៃ ជាអ្នកជួលរថយន្តសម្រាប់ដឹកពួកគាត់ទៅតាមគោលដៅផ្សេងៗក្នុងប្រទេសថៃ មិនមែនជាការយកលុយពីសំណាក់មន្ត្រីប្រចាំច្រកនោះឡើយ៕

## សមត្ថកិច្ចជួយជនរងគ្រោះពីការជួញដូរបានជាង ២ ០០០ នាក់

https://www.postkhmer.com/national/2023-04-19-1100-249147.html អោម ប៊ុនធឿន | Publication date 19 April 2023 | 11:00 ICT

**ភ្នំពេញៈ** គិតចាប់តាំងពីថ្ងៃទី ១៨ ខែសីហាឆ្នាំ ២០២២ រហូតមកដល់ថ្ងៃទី ១៧ ខែមេសា ឆ្នាំ ២០២៣ សមត្ថកិច្ចបានបើកប្រតិបត្តិការសង្គ្រោះជនបរទេស និងជនជាតិខ្មែរ ដែលត្រូវបានគេជួញដូរបានជាង ២០០០ នាក់ ក្នុងចំណោមសំណើដែលទទួលបានចំនួន ៨៥០ សំណើ។ នេះបើតាមលោក ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ។ លោក ខៀវ សុភ័គ បានឱ្យដឹងនៅថ្ងៃទី ១៨ ខែមេសាថា កិច្ចប្រតិបត្តិការរបស់ស មត្ថកិច្ចពាក់ព័ន្ធនឹងការប្រឆាំងការជួញដូរកម្លាំងពលកម្មបរទេស និងការបង្ខាំងមនុស្សក្នុងប្រទេសកម្ពុជាចាប់ពីខែសីហា ឆ្នាំ ២០២២ រហូតមក ដល់ថ្ងៃទី ១៨ ខែមេសា ឆ្នាំ ២០២៣ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទទួលបានសំណើឱ្យជួយសង្គ្រោះមនុស្សចំនួន ២ ១៣២ នាក់ លើសំណើចំនួន ៨៥០ សំណើ។ លោកបញ្ជាក់ថា មនុស្សជាង ២ ០០០ នាក់នាក់នោះត្រូវបានបញ្ជូនទៅលំនៅឋាន និងមាតុភូមិរបស់ពួកគេវិញ។ សំណើឱ្យជួយសង្គ្រោះដែលសមត្ថកិច្ចទទួលបានភាគច្រើនតាមរយៈក្រុមគ្រួសារ ញាតិមិត្តរបស់ជនរងគ្រោះ និង

មួយចំនួនទទួលបានពីជនរងគ្រោះផ្ទាល់។ យ៉ាងណាក៏ដោយតាមរយៈការផ្ទៀងផ្ទាត់ សំណើទាំងនោះឃើញថា មានពាក្យបណ្ដឹងប្រមាណជាង ១០០ ករណីរកមិនឃើញ។

លោកខៀវ សុភ័គ បានឱ្យដឹងទៀតថា សមត្ថកិច្ចបានឃាត់ខ្លួនជនសង្ស័យចំនួន ១២៩ នាក់ បិទក្រុមហ៊ុន ៥ ជាស្ថាពរ ផ្អាកអាជីវកម្មនិងបន្តស្រាវជ្រាវក្រុមហ៊ុនចំនួន ៤ ក្រុមហ៊ុន និងកំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៤៤ សំណើដែលស្នើឱ្យជួយរកមនុស្ស ១៧៧ នាក់។ លោកបញ្ជាក់ថា៖ «កន្លងមកមានថ្ងៃខ្លះ ក៏គ្មានករណីប្ដឹង ហើយមានថ្ងៃខ្លះ ក៏ ២-៣ ករណី ប៉ុន្តែកាលមុនដំបូងគេយើងទទួលបាន១ ថ្ងៃ ៥ ករណី ១ ថ្ងៃ ១០ ករណីឡើងទៅឯណោះម៉្លេះប៉ុន្តែឥឡូវរាងរយាលហើយ។ វិធានការបន្តគឺយើងមិនមែនស៊ើបតែត្រឹមហ្នឹងទេ គឺយើងពន្លាតការស៊ើបអង្កេតទៅរកការលាងលុយអីផ្សេងៗទៀត»។

លោកអំ សំអាត នាយកទទួលបន្ទុកកិច្ចការទូទៅ នៃអង្គការការពារសិទ្ធិមនុស្សលីកាដូ បានថ្លែងនៅថ្ងៃទី ១៨ ខែមេសាថា បច្ចុប្បន្នបញ្ហានៃការបង្ក្រាបការទប់ស្កាត់ការជួញដូរមនុស្សគ្រប់រូបភាព ទាំងការជួញដូរកម្លាំងពលកម្ម ក៏ដូចជាការជួញដូរមនុស្សតាមរូបភាពផ្សេងៗហាក់មិនសូវមានព័ត៌មានច្រើនដូចពីមុនទេ ប៉ុន្តែទោះយ៉ាងនេះក្ដី បញ្ហានេះនៅតែកើតមានឡើងជាបន្តបន្ទាប់ ដែលទាមទារឱ្យកម្ពុជានៅតែប្រកាន់នូវការតាំងចិត្តខ្ពស់ក្នុងការទប់ស្កាត់ការបង្ក្រាបទៅលើការជួញដូរមនុស្សគ្រប់ទម្រង់និងគ្រប់រូបភាព។ លោកបន្តថា ការខិតខំបង្ក្រាបទប់ស្កាត់ការជួញដូរមនុស្សគ្រប់ទម្រង់នេះគឺជាការធ្វើឱ្យកម្ពុជាទទួលបាននូវចំណាត់ថ្នាក់ល្អឡើងវិញ ក្រោយពីសហរដ្ឋអាមេរិកបានទម្លាក់ចំណាត់ថ្នាក់ នៃបញ្ហាការជួញដូរមនុស្សនៅកម្ពុជាទៅលំដាប់លេខ ៣។ លោកបន្ថែមថា បញ្ហានៃការជួញដូរមនុស្សនេះ ជាមូលដ្ឋានមួយក្នុងការបង្កើតបានជាទម្រង់រូបភាពជាច្រើនផ្សេងទៀត ក្រៅពីការជួញដូរមនុស្ស បង្ខាំងមនុស្ស កេងប្រវ័ញ្ចកម្លាំងពលកម្មមនុស្ស ក៏អាចក្លាយទៅជាបទឧក្រិដ្ឋផ្សេងៗ ដូចជា ការចាប់ជំរិតតាមប្រព័ន្ធអនឡាញជាដើម។

បើតាមលោកអំ សំអាត ការរង់ចាំទទួលបណ្ដឹងតែពីសាច់ញាតិ ឬពីជនរងគ្រោះមិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការដោះស្រាយបញ្ហានេះនោះទេ។ គួរតែមានការចូលរួមបន្ថែមពីអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងការទប់ស្កាត់បញ្ហាជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្មមនុស្ស និងបង្ខាំងមនុស្សនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព។ លោកថ្លែងថា៖ «មធ្យោបាយនៅមានច្រើនទៀតដូចជាត្រូវមានការត្រួតពិនិត្យជាប្រចាំ ឬក៏ទទួលព័ត៌មានផ្សេងៗ ពីប្រភពផ្សេងៗទៀត ដើម្បីធ្វើការជួយសង្គ្រោះសម្រាប់ជនរងគ្រោះ ហើយ ១ ទៀត គឺលើកទឹកចិត្ត សម្រាប់ភាគីដែលពាក់ព័ន្ធទាំងអស់ចូលរួមជាមួយគ្នាក្នុងការទប់ស្កាត់ ការបង្ក្រាបការជួញដូរមនុស្សជាពិសេសប្រជាពលរដ្ឋតែម្ដង»។ លោកអំ សំអាត បានលើកឡើងថា ការចូលរួមរបស់ប្រជាពលរដ្ឋបាន លុះត្រាតែអាជ្ញាធរបង្កលក្ខណៈងាយស្រួលសម្រាប់ពួកគាត់ក្នុងការផ្ដល់ព័ត៌មាន ជាជាងការធ្វើឱ្យពួកគាត់មានការភ័យខ្លាច ក្នុងការប្រាស្រ័យទាក់ទងផ្ដល់ព័ត៌មាន។

ប៉ុន្តែលោក ខៀវ សុភ័គ បានគូសបញ្ជាក់ថា ជុំវិញបញ្ហានេះកម្លាំងមានសមត្ថកិច្ចលើកទឹកចិត្តឱ្យប្រជាពលរដ្ឋចូលរួមផ្ដល់ព័ត៌មាន ដើម្បីរួមគ្នាទប់ស្កាត់ និងបង្ក្រាបការជួញដូរមនុស្ស ដើម្បីឱ្យការងារនេះកាន់តែមានប្រសិទ្ធភាព រហ័សទាន់ពេលវេលា។ ពលរដ្ឋអាចផ្ដល់ព័ត៌មានបានទាំងតាមរយៈលេខទូរស័ព្ទ ឬរាយការណ៍ទៅអាជ្ញាធរដែលនៅមូលដ្ឋាននោះឬមួយក៏អាចរាយការណ៍មកតាមរយៈហ្វេសប៊ុកក្រសួងមហាផ្ទៃតែម្ដង៕

## អភិបាលខេត្ត
## ចុះទៅពិនិត្យផ្ទាល់ ក្រោយបែកធ្លាយមន្ត្រីច្រកដូងជម្រិតទារលុយពីពលករទៅថៃ

https://www.kampucheathmey.com/local-news/497953 ថ្ងៃពុធ ១៩ មេសា ២០២៣ដោយ Dy Bunnara

ក្រោយពីចូលឆ្នាំថ្មីប្រពៃណីជាតិបានបញ្ចប់ ប្រជាពលរដ្ឋដែលជាពលករបំរើការងារនៅប្រទេសថៃបានវិលត្រឡប់ទៅបំរើការងារវិញរៀងៗខ្លួនតាមច្រកទ្វារអន្តរជាតិដូង ក្នុងស្រុកកំរៀង ខេត្តបាត់ដំបង។ ប៉ុន្តែអ្វីប្រឈមគឺមន្ត្រីនៅទីនោះយកលុយច្រើនក្នុងម្នាក់ៗ ដែលធ្វើឲ្យការធ្វើដំណើររបស់ពួកគាត់មានការយឺតយ៉ាវ។

តាមរយៈអាខោនហ្វេសប៊ុកឈ្មោះ (ស្ងួន ភក្តី) បានថតរូបប្រជាពលរដ្ឋដែលជាពលករបង្ហោះជាសាធារណៈអមដោយសំណេរដែលមានខ្លឹមសារថា "សូមលោកអភិបាលខេត្តឯកឧត្តម សុខ លូ ជួយពិនិត្យមើលផងទាននៅស្រុកកំរៀង ច្រកឡែម មានការរអ៊ូរទាំពីបងប្អូនពលករដែលវិលចូលទៅប្រទេសថៃវិញ ត្រូវអស់លុយម្នាក់ 1600 បាត និងថ្លៃជិះកអីវ៉ាន់ម្នាក់ 100 បាតទៀត ពួកគាត់បានដាក់សំណួរថា តើលុយទាំងនោះគេយកទៅណា ចូលរដ្ឋឬចូលបុគ្គល ហើយពួកគាត់សង្ឃឹមថា នឹងមានការបន្ធូរ បន្ថយរឿងយកលុយយកកាក់ពីពួកគាត់"។

ពាក់ព័ន្ធរឿងរ៉ាវខាងលើ លោក សុខ លូ អភិបាលខេត្តបានសរសេរលើបណ្ដាញហ្វេសប៊ុកផ្ទាល់ខ្លួនរបស់លោកថា "ព្រឹកនេះចេញដំណើរតាំងពីព្រលឹមទៅពិនិត្យស្ថានភាពនៅច្រកទ្វារអន្តរជាតិដូងស្រុកកំរៀង និងបានណែនាំបន្ថែមដល់បងប្អូនមន្ត្រីនិងសមត្ថកិច្ចប្រចាំការនៅច្រកទ្វារឲ្យខិតខំបង្កលក្ខណៈងាយស្រួល និងពន្លឿនការបំពេញបែបបទឆ្លងដែនជូនបងប្អូនប្រជាពលរដ្ឋ និងពលករឲ្យបានឆាប់រហ័ស ចៀសវាងការយកកំរៃសេវាក្រៅផ្លូវការពីបងប្អូន"។ ក្រោយពីមានការពន្លឿននិងធ្វើការណែនាំសម្របសម្រួលលើបញ្ហាយកកំរ៉ៃសេវាមិនប្រក្រតីផ្ទាល់ពីអភិបាលខេត្ត ក្រុមពលករមានការសប្បាយចិត្ត និងបានថ្លែងអំណរគុណដល់លោកអភិបាលខេត្ត ដែលបានជួយដោះបន្ទុកដល់ពួកគាត់កុំឲ្យខាតពេលនិងបង់លុយច្រើន ខណៈដែលពួកគាត់ម្នាក់ៗស្ទើររកលុយសល់ក្នុងខ្លួនមិនបាន បើសិនជាបង់ថ្លៃតាមមន្ត្រីទាមទារបន្ថែម៕ អត្ថបទ៖ សៅ សារិទ្ធ

## ពលករខ្មែរធ្វើការនៅថៃសម្រុកទៅវិញក្រោយបញ្ចប់បុណ្យចូលឆ្នាំខ្មែរ

https://www.kampucheathmey.com/local-news/498468 ថ្ងៃព្រហស្បតិ៍ ២០ មេសា ២០២៣ deth leng

រយៈពេលប៉ុន្មានថ្ងៃក្រោយសង្ក្រាន្តឆ្នាំថ្មីត្រូវបានបញ្ចប់ គេសង្កេតឃើញថា ពលករខ្មែរដែលបានមកលេងស្រុកកំណើត កំពុងធ្វើដំណើរត្រឡប់ចូលទៅក្នុងប្រទេសថៃវិញដើម្បីបម្រើការងារបន្តសារជាថ្មី។ បើតាមរបាយការណ៍របស់កម្លាំងទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ ប្រចាំច្រកអន្តរជាតិភ្នំដីក្នុងស្រុកសំពៅលូន ខេត្តបាត់ដំបង បានឱ្យដឹងថា រយៈពេលប៉ុន្មានថ្ងៃនេះ មានពលករចេញទៅប្រទេសថៃដោយស្របច្បាប់ក្នុងមួយថ្ងៃៗ មិនក្រោមពីមួយពាន់នាក់ឡើយ ពិសេសគឺនៅថ្ងៃទី ១៨ ខែមេសា កន្លងទៅនេះ។ ប្រភពដដែលបានបន្តថា នៅចំណុចច្រកអន្តរជាតិភ្នំដីមិនមានបញ្ហាអ្វីនោះឡើងសម្រាប់ការបំពេញឯកសារ ដើម្បីត្រឡប់ចូលទឹកដីថៃវិញរបស់បងប្អូនពលករខ្មែរពីសំណាក់មន្ត្រីជំនាញប្រចាំច្រក។

ដោយឡែកនៅច្រកអន្តរជាតិដូងប្រចាំស្រុកកំរៀង ក៏មានពលករវិលត្រឡប់ដូចគ្នា ប៉ុន្តែក៏មានភាពចម្រូងចម្រាស់បន្តិចដែរសម្រាប់មន្ត្រីជំនាញ ជាមួយក្រុមពលករ ដោយសារតែមានជនឆ្លៀតឱកាសកេងយកផលប្រយោជន៍ពីពលករ ខណៈពលករខ្មែរចាំបាច់ត្រូវតែវិលចូលប្រទេសថៃ ប៉ុន្តែដំណឹងដ៏សើបនេះក៏បានធ្វើឱ្យលោកអភិបាលខេត្ត សុខ លូ ចុះទៅដល់គោលដៅដើម្បីសម្របសម្រួល និងបញ្ចប់បញ្ហាភ្លាមៗនោះដែរ៕

# ថ្ងៃទី២៥ ខែ មេសា ឆ្នាំ២០២៣

## ក្រោយពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរហើយ ពលករបានចាប់ផ្ដើមត្រឡប់ចូលទៅប្រទេសថៃវិញ

https://www.tnb-news.com/news/365948.html?fbclid=IwAR3eLBviY7IP-h3kr16svy8AzD_u4GFc84T6GyePT8e5MT80hXxOgiBcNjM ចេញផ្សាយ ថ្ងៃទី19 ខែមេសា ឆ្នាំ2023

ខេត្តបន្ទាយមានជ័យ ៖ នៅចំណុចបំពេញបែបបទចេញក្រៅប្រទេស ច្រកទ្វារអន្តរជាតិប៉ោយប៉ែត គេឃើញមានពលករតម្រង់ជួរត្រៀបត្រា ដើម្បីបំពេញឯកសារឆ្លងចូលទៅទឹកដីថៃ ខណៈឥវ៉ាន់ ឬកាបូបរបស់ពួកគេជួលរទេះកម្មករអូសចូលព្រោងព្រៀត ។ ក្រោយពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរហើយ ពលករបានចាប់ផ្ដើមត្រឡប់ចូលទៅប្រទេសថៃវិញ ដើម្បីធ្វើការដោយស្របច្បាប់តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតជាហូរហែ ក្រោយពួកគេបានទៅជួបជុំក្រុមគ្រួសានៅស្រុកកំណើតរៀងខ្លួនៗ ខណៈពលករខុសច្បាប់បញ្ជូនពីថៃតាមរថយន្តទ្រុងមានជាង ២០០០នាក់ រយៈពេល៣ខែដើមឆ្នាំ២០២៣ ។

សមត្ថកិច្ចឈរជើងនៅមាត់ច្រកទ្វារអន្តរជាតិប៉ោយប៉ែតម្នាក់ប្រាប់ថា ចាប់ពីព្រឹកថ្ងៃទី១៧ ដល់ថ្ងៃទី១៩ មេសា នេះ ឃើញមានពលករត្រឡប់ទៅប្រទេសថៃជាបន្តបន្ទាប់ ប៉ុន្តែមិនច្រើនកកកុញ ដូចរយៈពេល២ទៅ៣ថ្ងៃមុនពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ដែលពួកគេត្រឡប់ពីប្រទេសថៃឡើយ។

ស្ត្រីពលករចេញពីកម្ពុជា ម្នាក់និយាយថា នាងនិងពលកររួមអាជីពបានសម្រេចចិត្តទៅធ្វើការលើទឹកដីថៃវិញ តាមការកំណត់របស់ក្រុមហ៊ុនខ្លួន។ ពលករខ្លះនិយាយថា មានពលករមួយចំនួនទៀត មិនទាន់វិលត្រឡប់ទៅប្រទេសថៃវិញនោះទេ ដោយពួកគេនៅជួបជុំក្រុមគ្រួសានៅឡើយ ៕

## ក្រសួងកិច្ចការនារី និងគណៈមេធាវីកម្ពុជា រៀបចំកិច្ចពិភាក្សាដើម្បីផ្តល់សេវាការពារក្តីជូនស្ត្រី និងក្មេងស្រីរងគ្រោះឱ្យកាន់តែប្រសើរ

https://www.postkhmer.com/national/2023-04-21-1000-249260.html សុខ វក្សា | Publication date 21 April 2023 | 17:00 ICT

ក្រសួងកិច្ចការនារី និងគណៈមេធាវីកម្ពុជា បានរៀបចំកិច្ចប្រជុំពិភាក្សាស្តីពីការផ្តល់សេវាការពារក្តីជូនស្ត្រី និងក្មេងស្រីក្រីក្ររងគ្រោះដោយអំពើហិង្សា ដើម្បីបង្ហាញពីសមិទ្ធផលការងារ និងបញ្ហាប្រឈមសំដៅស្វែងរកដំណោះស្រាយរួមឱ្យកាន់តែមានប្រសិទ្ធភាព។

កិច្ចប្រជុំនេះធ្វើឡើងក្រោមអធិតីភាពរដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី លោកស្រី អ៊ឹង កន្ថាផាវី និងមានការចូលរួមពីលោក លី ច័ន្ទតុលា ប្រធានគណៈមេធាវីកម្ពុជា ដែលជាដៃគូសហប្រតិបត្តិការរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងមន្ត្រីពាក់ព័ន្ធមួយចំនួនទៀត កាលពីថ្ងៃទី ២០ ខែមេសានេះ។ កិច្ចប្រជុំពិភាក្សានេះរៀបចំ និងសម្របសម្រួលដោយអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ ក.ជ.ក.ស ក្នុងគោលបំណង ទី១ ការពិនិត្យ និងវាយតម្លៃលើការផ្តល់សេវាការពារក្តីដល់ស្ត្រី និងក្មេងស្រីក្រីក្រ ដែលរងគ្រោះដោយអំពើហិង្សា និងការអប់រំច្បាប់ឆ្នាំ២០២២ និងផែនការការងារឆ្នាំ២០២៣។ ២ ពិនិត្យលើកិច្ចសហការដៃគូពាក់ព័ន្ធក្នុងការអនុវត្តគម្រោង និងវាយតម្លៃគុណភាពលើសេវាការពារសិទ្ធិស្ត្រី និងក្មេងស្រីរងគ្រោះឆ្នាំ២០២៣ និងកែសម្រួលការងារមួយចំនួន។ កិច្ចពិភាក្សាបានទទួលធាតុចូលពីអ្នកអនុវត្តផ្ទាល់ ក្នុងការរិះរកយុទ្ធសាស្ត្រដើម្បីបន្តអនុវត្តក្នុងតួនាទីជាអ្នក

ផ្តល់សេវាប្រកបដោយនិរន្តរភាពនិងប្រសិទ្ធភាពនិងសម្រេចនូវគោលដៅរួម ក្នុងការជួយស្ត្រីដែលជាជនរងគ្រោះក្នុងកម្រិតនៃកិច្ចព្រមព្រៀងដែលបានចុះក្នុងអនុស្សរណៈ។

លោក លី ច័ន្ទតុលា ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានថ្លែងថា កិច្ចពិភាក្សានេះ គឺជាកិច្ចប្រជុំដ៏មានសារៈសំខាន់ដើម្បីបង្ហាញពីសមិទ្ធផលការងារ កំណត់ចំណុចខ្លាំង និងបញ្ហាប្រឈមក្នុងការផ្តល់សេវាការពារក្តីជូនស្ត្រីនិងក្មេងស្រីក្រីក្ររងគ្រោះដោយអំពើហិង្សាក្នុងឆ្នាំ២០២២ កន្លងមក។ លោកបន្ថែមថា៖«ការជួបជុំនេះ ក៏ពិភាក្សាស្វែងរកដំណោះស្រាយ ដើម្បីពង្រីក និងពង្រឹងសេវាការពារក្តីប្រកបដោយប្រសិទ្ធភាព គុណភាព និងទាន់ពេលវេលា ក្នុងបេសកកម្មស្វែងរកយុត្តិធម៌ជូនស្ត្រី និងក្មេងស្រីក្រីក្ររងគ្រោះដោយអំពីហិង្សា»។ ជាមួយគ្នានោះដែរលោក លី ច័ន្ទតុលា បានថ្លែងអរគុណចំពោះលោកស្រី អ៊ឹង កន្ថាផាវី ដែលបានផ្តល់កិច្ចសហប្រតិបត្តិការជាមួយគណៈមេធាវី តាមរយៈអនុស្សរណៈនៃការយោគយល់ដែលស្ថាប័នទាំងពីរបានចុះជាមួយគ្នា៕

## តុលាការកំពូលជម្រះបណ្តឹងសាទុក្ខស្ត្រីជាប់ចោទម្នាក់ ពាក់ព័ន្ធនឹងការនាំពលករខ្មែរច្រើននាក់ ទៅធ្វើការនៅប្រទេសថៃខុសច្បាប់

https://cen.com.kh/archives/650364.html Posted ByPen Srey NeatApril 22, 2023

ភ្នំពេញ: តុលាការកំពូល កាលពីព្រឹកថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០២៣នេះ បានបើកសវនាការ ជំនុំជម្រះលើបណ្តឹងសាទុក្ខរបស់ ស្ត្រីជាប់ចោទម្នាក់ ដែលតុលាការថ្នាក់ក្រោម កាត់ទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ ជាប់ពាក់ព័ន្ធនឹងបទល្មើស ការនាំចេញដោយមិនស្របច្បាប់ សម្រាប់ឆ្លងដែន និង អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន ប្រព្រឹត្តនៅ ព្រំដែនកម្ពុជាថៃ ក្នុងឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ប្រព្រឹត្តកាលពីអំឡុងឆ្នាំ ២០២១ ។

លោក ជីវ កេង ជាប្រធានចៅក្រមប្រឹក្សាជំនុំជម្រះ នៃតុលាការកំពូល បានថ្លែងឲ្យដឹងថា ជនជាប់ចោទខាងលើមានឈ្មោះ ផាង គៀវ ភេទស្រី អាយុ ៣៩ ឆ្នាំ ។ នៅក្នុងសំណុំរឿងនេះ ជនជាប់ចោទ ឈ្មោះ ផាង គៀវ ត្រូវបានសាលាដំបូងខេត្តបាត់ដំបង កាលពីថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០២១ ផ្តន្ទាទោស ដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ ក្រោមការចោទប្រកាន់ពីបទ : នាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន តាមបញ្ញត្តិមាត្រា ១១ និង មាត្រា ១២ នៃ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ ។ ស្ត្រីជាប់ចោទប្តឹងឧទ្ធរណ៍ តែសាលាឧទ្ធរណ៍បាត់ដំបង បានតម្កល់ទណ្ឌកម្មរបស់គាត់រក្សាទុកជាបានការដែល ។ ជនជាប់ចោទ ក៏បានបន្តប្តឹងសារទុក្ខមកកាន់តុលាការកំពូលទៀត។ ស្ត្រីជាប់ចោទ ត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួន កាលពីថ្ងៃទី ១៧ ខែ មិនា ឆ្នាំ ២០២១ នៅឃុំ សេរីមានន័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ។ សំណុំរឿងក្តីនេះ, តុលាការកំពូលបានលើកពេលប្រកាសសាលដីកា នៅព្រឹកថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២៣ ខាងមុខ នេះ៕ រក្សាសិទ្ធដោយ ៖ ចន្ទា ភា

# សមត្ថកិច្ចកម្ពុជា បន្តទទួលបានបណ្តឹង ០៥ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៨នាក់

https://freshnewsasia.com/index.php/en/localnews/287905-2023-04-22-04-38-09.html 2023-04-22 11:38am

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី២០ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៥ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ចំនួន០៨នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៨៥៦ករណី មាននមនុស្ស ២,១៤១នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៨១៤សំណើ និងបិទសំណុំរឿង ២៧៧សំណើ (រកឃើញមនុស្ស ១,២២៨នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣០នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៤២ករណី៕

# លោកជំទាវ ហ៊ុន ស៊ីណាត ចេញមុខអន្តរាគមន៍ជួយរាស្ត្រជុំវិញរឿងយកលុយពលករខ្មែរនៅច្រកឡែម

https://kohsantepheapdaily.com.kh/article/1724336.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ភ្នំពេញ២២ ខែ មេសា ឆ្នាំ ២០២៣ ម៉ោង ១៥:៣៩

រាជធានីភ្នំពេញ ៖ លោកជំទាវ ហ៊ុន ស៊ីណាត ប្អូនស្រីបង្កើតសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា កាលពីពេលថ្មីៗនេះបានស្នើទៅអភិបាលខេត្តបាត់ដំបង លោក សុខ លូ ឱ្យជួយដោះស្រាយបញ្ហាដែលកើតមាននៅច្រកព្រំដែន ឡែម ជុំវិញរឿងរ៉ាវមន្ត្រីនៅច្រកទ្វារមួយនេះបានកៀបសង្កត់យកលុយពីពលករខ្មែរដែលធ្វើដំណើរទៅធ្វើការនៅប្រទេសថៃ ។ តាមរយៈសំណេរលើបណ្តាញសង្គមហ្វេសប៊ុក លោកជំទាវ ហ៊ុន ស៊ីណាត បានដាក់ចំៗទៅអភិបាលខេត្តបាត់ដំបងថា«ខ្ញុំសូមឯកឧត្តមគណៈអភិបាលខេត្តបាត់ដំបងសុខ លូ មេត្តាជួយមើលរឿងរ៉ាវរបស់រាស្ត្រច្រកឡែម ក្នុងស្រុកកំរៀងនៅតាមច្រកនេះបានធ្វើបាបរាស្ត្ររាល់ថ្ងៃ» ។

លោកជំទាវ ហ៊ុន ស៊ីណាត ដែលពលរដ្ឋខ្មែរគោរពស្រលាញ់ និងតែងហៅលោកជំទាវថា«លោកជំទាវចិត្តធម៌» បានមានប្រសាសន៍បន្តថា រឿងរ៉ាវយកលុយពីពលករខ្មែរនៅច្រកឡែមនេះ គឺរូបលោកជំទាវ ទទួលបានព័ត៌មានផ្ទាល់ពីប្រជាពលរដ្ឋដែលប្រជាពលរដ្ឋបានផាតមកឲ្យ ខ្ញុំជម្រាបជូនដល់ថ្នាក់លើផង តើរឿងនេះវាយ៉ាងណាដែរ?»។ «រឿងច្រកឡែមមួយនេះយូរហើយបែបរកលុយដូចពាក្យគេថា ត្រីចង្វាចិញ្ចឹមត្រីឆ្តោហើយមើលទៅ ។ សូមអស់លោកដែលពុករលួយល្មមឆ្អែតធ្ងន់ហើយ ។ ម្យ៉ាងទៀតមានក្មេងកំពុងតែស្រែករឿងនេះស្រាប់»។ នេះជាការលើកឡើងរបស់លោកជំទាវចិត្តធម៌ ហ៊ុន ស៊ីណាត ដែលរូបលោកជំទាវ តែងតែអន្តរាគមន៍ជារឿយៗ ដើម្បីរកយុត្តិធម៌ជូនពលរដ្ឋខ្មែរ ពិសេសលោកជំទាវតែងតែព្រលះមន្ត្រីខូចៗណាដែលពុករលួយ ធ្វើបាបរាស្ត្រកន្លងមករហូត ប្រជាពលរដ្ឋគោរពស្រលាញ់លោកជំទាវ និងតែងតែសុំលោកជំទាវជួយអន្តរាគមន៍រាល់ពេលមានបញ្ហាអយុត្តិធម៌កើតមានលើប្រជាពលរដ្ឋ ។

ជាក់ស្តែងរឿងរ៉ាវនៅច្រកឡែម ស្រុកកំរៀង ខេត្តបាត់ដំបង មានពលករខ្មែរជាច្រើនរូបបានលើកឡើងថា ក្រោយចូលឆ្នាំប្រពៃណីខ្មែររួចក៏ធ្វើដំណើរទៅថៃវិញ ដើម្បីបន្តការងារ ។ តែអ្វីដែលហួសចិត្តនោះមានពលករខ្មែរមួយរូបបានលាតត្រដាងរឿងរ៉ាវពុករលួយនៅច្រកឡែមថា រូបលោកត្រូវចំណាយលុយអស់១៣០០បាត (ប្រមាណជាង១៥ម៉ឺនរៀល) លើឯកសារដើម្បីបានឆ្លងច្រកឡែមចូលទឹកដីថៃ ។ ជាមួយគ្នានោះ លោកជំទាវ ហ៊ុន ស៊ីណាត ក៏បានចែកចាយវីដេអូដែលពលករខ្មែររៀបរាប់អំពីការយកលុយនៅច្រកឡែមផងដែរ។

តាមរយៈវីដេអូឃ្លីបមួយមានរយៈពេលមិនដល់១នាទីផងនោះយើងឃើញពលករខ្មែរមួយរូបដែលបានឆ្លងទៅប្រទេសថៃតាមច្រកឡែមបានថ្លែងថា បងប្អូនពលករខ្មែរយើងចូលឆ្នាំរួច បើចង់ឡើងមកថៃ ចងការលុយគេឱ្យច្រើនបន្តិចមក ។ ពលករខ្មែររូបនេះបន្តថា រូបលោកបានឆ្លងទៅមកដល់ប្រទេសថៃហើយ ដោយឆ្លងកាត់តាមច្រកឡែម ដោយពលករខាងលើអះអាងថា លោកត្រូវចំណាយលុយសរុបប្រមាណ១៣០០បាត ដោយដំបូងលោកយកអត្តសញ្ញាណបណ្ណទៅថតចម្លងលើក្រដាសសទំហំ A4 អស់ ១០០ បាត (ប្រមាណជា១១ ០០០ រៀល) បន្ទាប់មកពលករខាងលើបន្តថា លោកត្រូវតម្រង់ជួរជាមួយពលករខ្មែរជាច្រើនទៀត ទម្រាំអស់លោកនៅច្រកទ្វារចារលេខរៀងលើក្រដាសថតចម្លងអត្តសញ្ញាណបណ្ណ ទំហំ A4 គឺត្រូវចាយអស់ ១២០០បាត (ប្រមាណជាង១៤ម៉ឺនរៀល) បន្ថែមទៀតទម្រាំបានឆ្លងកាត់ច្រកឡែមចូលទឹកដីថៃ។

ក្រោយពេលលោកជំទាវ ហ៊ុន សែន ស្នើចំៗទៅអភិបាលខេត្តបាត់ដំបង លោក សុខ លូ ឱ្យពិនិត្យរឿងរ៉ាវជញ្ជក់ឈាមយកលុយពលករខ្មែរនៅច្រកឡែម ឃើញមានបងប្អូនអ្នកប្រើប្រាស់បណ្តាញសង្គមជាច្រើនបានចូលមកបញ្ចេញយោបល់អរគុណលោកជំទាវ ហ៊ុន ស៊ីណាតដែលបានជួយអន្តរាគមន៍ ។ ក្នុងនោះក៏មានបងប្អូនខ្លះទៀតសុំលោកជំទាវឱ្យជួយអន្តរាគមន៍បន្ថែមទៀត ដោយមានគណនីហ្វេសប៊ុកមួយឈ្មោះថា «Thida Ny» ក៏បានចូលទៅខមមិនសុំលោកជំទាវថា «សូមលោកជំទាវជួយផង ខ្ញុំធ្វើការមិនបានលុយច្រើនទេ ពេលទៅផ្ទះម្តងៗចំណាយច្រើនរឿងច្រក និងតែម្តងឆ្នាំនេះខ្ញុំមិនបានទៅលេងផ្ទះទេ ព្រោះច្រកចេញថ្លៃពេកមិនមែនតែច្រកឡែមទេគ្រប់ច្រកបើដូចពីមុនអត់លុយក៏ទៅផ្ទះបានដែរតែឥឡូវប្រើលុយច្រើនពេកទើបខ្ញុំមិនបានទៅផ្ទះ »។

ចំណែកគណនីហ្វេសប៊ុកឈ្មោះ «Kwan NiTa» ក៏បានថ្លែងប្រាប់លោកជំទាវ ហ៊ុន ស៊ីណាតថា«ខ្ញុំអស់ចង់ 2000បាត» ឬប្រមាណជិត២៣ម៉ឺនរៀល ។ ក្រោយឃើញសារបែបនេះលោកជំទាវ ហ៊ុន ស៊ីណាត ក៏បានបញ្ចេញប្រតិកម្មថា«អុញ!ម៉េចបានអស់លុយអញ្ចឹងខ្ញុំឃើញ ។ BAYON Radio នាំលោកធំ សុខ លូ ចុះទៅពេលនោះពលករខ្មែរ បានលើកឡើងដូចៗគ្នាថា រាល់ការបំពេញបែបបទ ឯកសារចេញចូលឆ្លងដែននាពេលបច្ចុប្បន្ននេះមានភាពលឿនរហ័សជាងមុន និងពុំមានការទារលុយកាក់ក្រៅផ្លូវការនោះទេ»។ លោកជំទាវហ៊ុន ស៊ីណាត បន្តថា «អញ្ចឹងបើរឿងដែលក្មួយអស់លុយមាន អស់លោកធំចុះទៅ ដើម្បីសម្តែងល្ខោនក្នុងពេលពលករខ្មែរស្រែកដេរ។ ថ្ងៃនេះជាថ្ងៃសីល សូមឲ្យអ្វីៗដែលអស់លោកបានជញ្ជក់ឈា.មពលករខ្មែរកន្លងមកសូមកុំឲ្យមានទៀត បើមិនបញ្ឈប់ការធ្វើបាបពលករទេ សូមទសបារមីលោកតាដំបងក្រញូងក្នុងខេត្តបាត់ដំបងចាត់ការអាអ្នកទាំងនោះផងចុះ»។

ជាមួយនឹងការខមមិនរបស់លោកជំទាវ ហ៊ុន ស៊ីណាត ដែលសូមទសបារមីលោកតាដំបងក្រញូងក្នុងខេត្តបាត់ដំបងចាត់ការមនុស្សខូចដែលយកលុយពលករក្រៅផ្លូវការនោះ ស្រាប់តែឃើញមានសារបែកធ្លាយ ដែលជាសារឆ្លើយឆ្លងរបស់លោក សុខ លូ និងសហការីរបស់គាត់ថា ដែលបានថតសាររបស់លោកជំទាវ ហ៊ុន ស៊ីណាត និងសំណេររបស់លោក ផែង វណ្ណៈ ដែលបានសរសេរស្រដៀងលោកជំទាវ ហ៊ុន ស៊ីណាតថាលោក«សុំដាក់បណ្តាសាឱ្យបុគ្គលថោកទាបណាប៊ីតជញ្ជក់ឈាមពលករ សូមឱ្យវាក្រឡាប់ឡានងាប់ទាំងពូជ» នោះចែកចាយក្នុងគ្រុបតេឡេក្រាមមួយដោយយើងឃើញថា ក្នុងសារបែកធ្លាយនោះ សហការីរបស់លោក សុខ លូ ម្នាក់បាននិយាយថា«ដាក់

ទំនាយគេដល់កហើយ ឯឧបង អត់ខ្លាចបាបកម្ម»។ រួចលោក សុខ លូ ក៏បានតបសារថា«ដាក់ទំនាយគេយូរៗ... គង់តែត្រូវខ្លួនឯងទេ» ។

យ៉ាងណាមិញ យើងមិនទាន់អាចទាក់ទងលោក សុខ លូ លើបញ្ហាពុករលួយនៅច្រកឡែម និងការប្រមាថលោកជំទាវ ហ៊ុន ស៊ីណាត បាននៅឡើយទេ គិតត្រឹមថ្ងៃទីសៅរ៍ ទី២២ ខែមេសានេះ ។ ក៏ប៉ុន្តែបើយើងក្រឡេកមើលសន្ទុះនៃការថ្លែងអំណរគុណលោកជំទាវ ហ៊ុន ស៊ីណាត រឿងមន្ត្រីមួយចំនួនយកលុយក្រៅផ្លូវការពីពលករខ្មែរយើងវិញឃើញមានបងប្អូនខ្មែរ សម្តែងការអរគុណលោកជំទាវជាបន្តបន្ទាប់ ។ ជាក់ស្តែង បងប្អូនពលរដ្ឋខ្មែរក៏បានចេញវីដេអូថ្មីមួយសម្តែងការអរគុណដល់សម្តេចតេជោ ហ៊ុន សែន និងភរិយា និងថ្លែងអំណរគុណចំពោះលោកជំទាវ ហ៊ុន ស៊ីណាត ដែលបានជួយអន្តរាគមន៍ដោះស្រាយរឿងរ៉ាវ ច្រកឡែម ដោយមិនឱ្យមានការយកលុយកាក់ពីបងប្អូនពលករខ្មែរដែលឆ្លងកាត់ច្រកឡែមទៅបំពេញការងារនៅថៃទៀតនោះទេ ។

ក្នុងវីដេអូឃ្លីបមួយទៀត បងស្រីម្នាក់បានលើកឡើងថា អ្នកដែលជាពលករខ្មែរទៅធ្វើការនៅថៃនោះមិនមែនជាបក្សប្រឆាំងទេ គឺនៅថៃក៏មានពលករខ្មែរដែលគោរពស្រលាញ់គណបក្សប្រជាជនដែរ ហើយបងប្អូនក៏បានជូនពរជំទាវម៉ែ ហ៊ុន ស៊ីណាត មានសុខភាពល្អផងដែរ៕

## នគរបាលព្រំដែនលេខ៨១៥ ឃាត់ខ្លួនមនុស្ស៣៩នាក់ ដែលបម្រុងលួចឆ្លងដែនខុសច្បាប់ ទៅប្រទេសថៃ ក្នុងភូមិសាស្ត្រស្រុកម៉ាឡៃ

https://freshnewsasia.com/index.php/en/localnews/287943-2023-04-22-13-17-05.html 2023-04-22 08:17pm

**(បន្ទាយមានជ័យ)៖** នគរបាលព្រំដែនគោកវរសេនាតូច៨១៥ បានឃាត់ខ្លួនប្រជាពលរដ្ឋចំនួន៣៩នាក់ ដែលបម្រុងលួចឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់ ដើម្បីរកការងារធ្វើ។ ការឃាត់ខ្លួននេះ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ ក្រោមការដឹកនាំបញ្ជាដោយផ្ទាល់របស់លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥។ កម្លាំងប៉ុស្តិ៍ស្ពានម៉ាឡៃដឹកនាំ ដោយលោកវរសេនីយ៍ត្រី ពៅ រតនា នាយប៉ុស្តិ៍នគរបាលការពារព្រំដែនគោកស្ពានម៉ាឡៃ សហការជាមួយកម្លាំងយោធា បានទប់ស្កាត់ប្រជាពលរដ្ឋចំនួន ៣៩នាក់ (ស្រី១៨នាក់ កុមារ០២នាក់) បម្រុងលួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ ត្រង់ចំណុចគោលដៅជំបូកវិល ស្ថិតក្នុងភូមិជំបូកវិល ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

លោកវរសេនីយ៍ត្រី ពៅ រតនា នាយប៉ុស្តិ៍នគរបាលការពារព្រំដែនគោកស្ពានម៉ាឡៃ នៃវរសេនាតូចលេខ ៨១៥ បានបញ្ជាក់ថា ប្រជាពលរដ្ឋដែលឃាត់បានមានទីលំនៅក្នុងខេត្តចំនួន៦ រួមមាន តាកែវ៤នាក់, កំពង់ធំ១៧នាក់, បាត់ដំបង១១នាក់, បន្ទាយមានជ័យ៥នាក់, ពោធិ៍សាត់១នាក់ និងប៉ៃលិន១នាក់។
បន្ទាប់ពីធ្វើការសួរនាំ និងធ្វើកិច្ចសន្យារួច សមត្ថកិច្ចបានប្រគល់ពួកគាត់ជូនផ្នែកជំនាញរបស់អធិការដ្ឋាននគរបាលស្រុកម៉ាឡៃ ដើម្បីអនុវត្តបន្តទៅតាមនីតិវិធី៕

# ថ្ងៃទី២៦ ខែ មេសា ឆ្នាំ២០២៣

## សម្តេចតេជោ ហ៊ុន សែន ជំរុញឱ្យក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ខិតខំដោះស្រាយបញ្ហារបស់ពលករ នៅក្រៅប្រទេសឱ្យបានល្អប្រសើរ

https://www.information.gov.kh/articles/102436 ចេញផ្សាយ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០២៣

ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានមានប្រសាសន៍ ជំរុញឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខិតខំដោះស្រាយបញ្ហារបស់ពលករនៅក្រៅប្រទេសឱ្យបានល្អប្រសើរ ជាពិសេសការពារសិទ្ធិកម្មករ ពីការរំលោភបំពានផ្សេងៗ។ សម្តេចតេជោនាយករដ្ឋមន្ត្រីបានថ្លែងដូច្នេះ ក្នុងពិធីជួបសំណេះសំណាល និងអបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣៧ ទិវាពលកម្មអន្តរជាតិ១ឧសភា ជាមួយសមាគមសហជីព កម្មករ និយោជិត តំណាងមន្ត្រីរាជការ គ្រូបង្រៀន និងតំណាងសមាគមសេដ្ឋកិច្ចក្រៅប្រព័ន្ធប្រមាណ ៣៥០០ នាក់ នាព្រឹកថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០២៣ នៅសាលមហោស្រពកោះពេជ្រ រាជធានីភ្នំពេញ។

សម្តេចតេជោ ហ៊ុន សែន បានសម្តែងនូវក្តីរីករាយ ដែលបានជួបសំណេះសំណាល ជាមួយ សហជីពកម្មករ តំណាងមន្ត្រីរាជការ គ្រូបង្រៀន និងតំណាងសមាគមសេដ្ឋកិច្ចក្រៅប្រព័ន្ធ ក៏ដូចជាការអបអរសាទរ ទិវាពលកម្មអន្តរជាតិ ១ឧសភា ដែលកម្ពុជាប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំ ដើម្បីលើកទឹកចិត្ត និងគាំទ្រចំពោះការខិតខំប្រឹងប្រែងរបស់កម្មករ កម្មការិនី ក្នុងវិស័យការងារ។ សម្តេចតេជោនាយករដ្ឋមន្ត្រី បានវាយតម្លៃខ្ពស់ចំពោះភាពរីកចម្រើន និងអភិវឌ្ឍន៍របស់ប្រទេសកម្ពុជាក្នុងរយៈពេលកន្លងមកនេះ។ សម្តេចតេជោក៏បានថ្លែងដោយក្តីមោទកភាព ចំពោះកត្តាសុខសន្តិភាពរបស់កម្ពុជា ដែលកត្តាសុខសន្តិភាពនេះ វាបានផ្តល់នូវផ្លែផ្កាជាច្រើនសម្រាប់ភាពរីកចម្រើនរបស់ប្រទេសជាតិយើង។ សម្តេចតេជោ ក៏បានវាយតម្លៃខ្ពស់ ចំពោះភាពជោគជ័យរបស់កម្ពុជាក្នុងការប្រយុទ្ធប្រឆាំង និងទប់ស្កាត់ជំងឺកូវីដ១៩ ដែលធ្វើឱ្យយើងបានបើកដំណើរការប្រទេសជាតិឡើងវិញ និងបានដំណើរការសកម្មភាពប្រទេសជាតិជាប្រក្រតីឡើងវិញតាមគន្លងថ្មី។

សម្តេចតេជោនាយករដ្ឋមន្ត្រី បានមានប្រសាសន៍ទៀតថា ការស្វែងរកប្រភពវ៉ាក់សាំងមកចាក់ជូនបងប្អូនប្រជាពលរដ្ឋយើង គឺជាភាពជោគជ័យដ៏ធំធេង ក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ ជាមួយនឹងការចូលរួមសហការទប់ស្កាត់ពីបងប្អូនប្រជាពលរដ្ឋទាំងអស់គ្នា ទើបយើងទទួលបាននូវភាពជោគជ័យក្នុងការងារនេះ។ សម្តេចតេជោក៏បានមានប្រសាសន៍ ពីភាពជោគជ័យនៃការដឹកនាំកិច្ចប្រជុំកំពូលអាស៊ីអឺរ៉ុប និងកិច្ចប្រជុំកំពូលអាស៊ាន ដែលកម្ពុជាយើងបានធ្វើជាម្ចាស់ផ្ទះកន្លងទៅថ្មីៗនេះ ដែលនោះជាមោទកភាពមួយសម្រាប់កម្ពុជា ដែលកិច្ចប្រជុំនោះមានការចូលរួមពីមេដឹកនាំបណ្តាប្រទេសមហាអំណាចធំៗច្រើន មកចូលរួមប្រជុំនៅទីក្រុងភ្នំពេញ ដែលបានប្រព្រឹត្តទៅដោយរលូន មិនមានបញ្ហាអ្វីរាំងស្ទះឡើយ។ សម្តេចតេជោនាយករដ្ឋមន្ត្រី នៅតែបន្តអំពាវនាវឱ្យបងប្អូនប្រជាពលរដ្ឋចូលរួមថែរក្សាសុខសន្តិភាពឱ្យបានគង់វង្ស។

ជាមួយគ្នានោះ ក៏ត្រូវខិតខំថែរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ទប់ស្កាត់អតិផរណា។ គ្រប់ស្ថាប័នទាំងអស់ត្រូវចេះសន្សំសំចៃក្នុងការចំណាយផ្សេងៗ និងត្រូវចូលរួមលុបបំបាត់ការរកស៊ីគេចពន្ធ ព្រមទាំងត្រូវខិតខំរកចំណូលសម្រាប់ជាតិឱ្យបានច្រើន។ សម្តេចតេជោ ហ៊ុន សែន ក៏បានអំពាវនាវឱ្យមានការចូលរួម ការការពារសន្តិសុខសណ្តាប់ធ្នាប់សង្គម បន្តការអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាពឱ្យបានខ្ជាប់ខ្ជួនជានិច្ច ដូចជាទប់ស្កាត់ការការជួញដូរ និងប្រើប្រាស់គ្រឿងញៀន ទប់ស្កាត់ល្បែងស៊ីសងគ្រប់ប្រភេទ និងរួមគ្នាទប់ស្កាត់បញ្ហាគ្រោះថ្នាក់ចរាចរណ៍ទាំងអស់គ្នា។ សម្តេចតេជោនាយករដ្ឋមន្ត្រី ក៏បានជំរុញបន្តយកចិត្តទុកដាក់ដោះស្រាយជីវភាពប្រជា

ពលរដ្ឋដែលខ្សត់ខ្សោយ ជាពិសេសប្រជាពលរដ្ឋដែលងាយរងគ្រោះផ្សេងៗ ដូចជាពលរដ្ឋដែលរងគ្រោះ ក្នុងវិបត្តិកូវីដ១៩ជាដើម។ ត្រូវចូលរួមក្នុងការដោះស្រាយការងារជូនប្រជាពលរដ្ឋ ទាំងការងារសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ គឺត្រូវបន្តយកចិត្តទុកដាក់ជាប់ជាប្រចាំ ជាពិសេសគោលនយោបាយគាំពារសង្គម ដូចជាការអនុវត្តគាំពារស្ត្រីមានផ្ទៃពោះរហូតដល់កូនអាយុ២ឆ្នាំ។

សម្តេចតេជោនាយករដ្ឋមន្ត្រីបានសង្កត់ធ្ងន់ថា ក្នុងនាមជាប្រធានគណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សដឹកនាំប្រទេសជាតិ គឺសម្តេចមិនបណ្តោយឱ្យប្រជាពលរដ្ឋណាម្នាក់ស្លាប់ដោយអត់បាយ ហើយដោយយើងមិនបានដឹងនោះទេ គឺយើងត្រូវតែយកចិត្តទុកដាក់មើលឱ្យបានគ្រប់ជ្រុងជ្រោយចំពោះប្រជាពលរដ្ឋដែលជួបទុក្ខលំបាក។ សម្តេចតេជោ បានមានប្រសាសន៍បន្ថែមថា គិតត្រឹមថ្ងៃទី២៣ ខែមេសា នេះ គឺសល់តែ១២ថ្ងៃទៀតតែប៉ុណ្ណោះ យើងនឹងដល់ព្រឹត្តិការណ៍ ស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេម ដែលកម្ពុជាត្រូវធ្វើជាម្ចាស់ផ្ទះ។ ដូច្នេះស្នើឱ្យស្ថាប័នពាក់ព័ន្ធរៀបចំព្រឹត្តិការណ៍នេះ ឱ្យបានល្អប្រសើរ និងរលូន ដើម្បីឱ្យភ្ញៀវអន្តរជាតិទាំងអស់ ពេលដែលមកដល់កម្ពុជាម្តងហើយ គេចង់មកម្តងទៀតនៅពេលក្រោយ។ ជាមួយគ្នានេះដែរបន្ទាប់ពីព្រឹត្តិការណ៍ស៊ីហ្គេមរួចហើយនោះ ព្រឹត្តិការណ៍នៃការបោះឆ្នោតជាតិ នឹងត្រូវចូលមកដល់ ដូច្នេះសម្តេចតេជោ បានអំពាវនាវ ធ្វើយ៉ាងណាឱ្យការបោះឆ្នោតជាតិនៅពេលខាងមុខនេះ បានប្រព្រឹត្តទៅដោយរលូន អព្យាក្រឹត្យ មិនមានការគាបសង្កត់ ដោយសេរី ត្រឹមត្រូវ យុត្តិធម៌ ពោលគឺស្ថិតក្នុងបរិយាកាសដ៏ល្អបំផុត៕ ដោយ៖ ជឹម ណារី

## ពលករបម្រុងលួចឆ្លងដែនទៅប្រទេសថៃ ត្រូវបានឃាត់ខ្លួននៅតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ នៅក្នុងស្រុកថ្មពួក

https://freshnewsasia.com/index.php/en/localnews/287990-2023-04-23-11-49-53.html 2023-04-23 06:49pm

**(បន្ទាយមានជ័យ)៖** លោក វរសេនីយ៍ឯក ឡុង សំណាង មេបញ្ជាការ វរសេនាតូចនគរបាលការពារព្រំដែនគោក លេខ៨០៧ បានឲ្យដឹងថា កាលពីយប់ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣ កម្លាំងប៉ុស្តិ៍អូរសាយចំនួន០៤នាក់ ដឹកនាំដោយលោក អនុសេនីយ៍ឯក ស៊ូ ពុទ្ធា នាយរងប៉ុស្តិ៍ សហការជាមួយកម្លាំងយោធាសឹករងស្រុកថ្មពួកចំនួន ០២នាក់ បានចុះល្បាត ត្រួតពិនិត្យ នៅបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រ រហូតមកដល់ ត្រង់ចំណុចដើមអង្រ្គងលិច ក៏ប្រទះឃើញ បង្អាក់ដំណើរឃាត់ខ្លួន ទប់ស្កាត់ពលករបម្រុងឆ្លងដែនទៅប្រទេសថៃ សរុបចំនួន៨នាក់ (ស្រី០៤នាក់) ស្ថិតក្នុងភូមិសាស្ត្រ ភូមិត្រពាំងសំរោង ឃុំគោកមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។

លោកវរសេនីយ៍ឯក ឡុង សំណាង បានបញ្ជាក់ថា បន្ទាប់មកកម្លាំងប៉ុស្តិ៍អូរសាយ បានធ្វើកិច្ចសន្យា រួចហើយបញ្ជូនពលករទាំងអស់ ទៅឲ្យប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំគោករមៀត របស់អធិការដ្ឋាននគរបាលស្រុកថ្មពួក ដើម្បីធ្វើការសួរនាំ និង អនុវត្តន៍ទៅតាមនីតិវិធី។ ឆ្លៀតក្នុងឱកាសនោះ លោកវរសេនីយ៍ឯក ឡុង សំណាង ក៏បានអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋ កុំបាញ់បោកមេខ្យល់ ដៃតែងតែបញ្ឆោះបញ្ចូល នាំពលករឆ្លងដែនខុសច្បាប់ ទាំងប្រថុយប្រថាន ដោយមិនគិតពីសុខសុវត្ថិភាព និង ខាតបង់ប្រាក់កាសជាបន្តបន្ទាប់៕

# ករណី បង្ខាំងនៅក្នុងទីតាំង និងដកយកលិខិតឆ្លងដែនប្រព្រឹត្ត នៅទីតាំងអគារកាស៊ីណូហ្គដដេស មានទីតាំងនៅភូមិ១ សង្កាត់លេខ៣ ក្រុង-ខេត្តព្រះសីហនុ

https://www.gdlf-kh.com/2023/04/23/ Pisey ខេត្តព្រះសីហនុ

ខេត្តព្រះសីហនុ ៖ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៣ Hotline របស់ ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុនិងបណ្តឹងលេខ(828) Hotline របស់ក្រុមការងារ សម្តេចក្រឡាហោម ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៣(ស្ទួនគ្នា) ពាក់ព័ន្ធករណីសង្ស័យករណីបង្ខាំងនៅក្នុងទីតាំង និងដកយកលិខិតឆ្លងដែន ប្រព្រឹត្ត នៅទីតាំងអគារកាស៊ីណូហ្គដដេស មានទីតាំងនៅភូមិ១ សង្កាត់លេខ៣ ក្រុង–ខេត្តព្រះសីហនុ ក្រោយទទួលបណ្តឹងនៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង១៦ និង ០០នាទី ដោយមានការចង្អុល ដឹកនាំពី លោកស្នងការនគរបាលខេត្ត និងសម្របសម្រួលនីតិវិធីពី តំណាងអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ កម្លាំងជំនាញការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់ បានចុះដល់អគារ ខៃស៊ីងត៍រដិ ( TRIUMPH INTERNATIONAL ) ស្ថិតក្នុងបរិវេណទីតាំងអគារកាស៊ីណូហ្គដដេស អហ្វ លីបឺធី (GOODES OF LIBERTY ENTERTAINMENT CITY COMPANY LIMITED) ស្ថិតក្នុងភូមិ១សង្កាត់លេខ៣ ក្រុង–ខេត្តព្រះសីហនុ។ ក្នុងកិច្ចប្រតិបត្តិបការនេះ បានរកឃើញជនក្នុងបណ្តឹងទាំង៦នាក់ កំពុងអង្គុយធ្វើការនៅបន្ទប់ជាន់ផ្ទាល់ដីនិង អាចមានតំរុយពាក់ពន្ធ័ករណីរងគ្រោះនូវ ជួញដូរបទសង្ស័យ អំពើជួញដូរ ទិញលក់ និងអំពើបង្ខាំង មនុស្សដោយមានគោលដៅ និងពាក់ពន្ធ័ករណីរក្សាទុកអាវុធខុសច្បាប់និងបាននាំខ្លួនមនុស្សចំនួន៥នាក់ មកធ្វើការសាកសួរនៅស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ជុំវិញករណីខាងលើនេះ។

សម្ភារៈដកហូតបានរួមមាន៖

១–កាំភ្លើងចំនួន០២ដើម: –ម៉ាកZORAKI 925 ចំនួន០១ដើម មានបង់ចំនួន០២(វែង០១–ខ្លី០១) និងបំពង់ ខ្ទប់សំឡេង ០១ដើម, និងម៉ាកROLO មានលេខDCH1527637-2 ចំនួន០១ដើម ។

២–គ្រាប់កាំភ្លើងចំនួន០២ប្រភេទគឺ៖ ម៉ាក៣៨០ មាន៤ប្រអប់ ចំនួន២០០គ្រាប់ និង គ្រាប់កាំភ្លើងម៉ាក សំរាប់ដាក់ ROLO មានចំនួន៩៨គ្រាប់ ។

៣–ដំបងឆក់ចំនួន០៤ដើម

៤–កាំបិតតាំងតោចំនួន០១ដើម

៥–លិខិតឆ្លងដែនចំនួន០៧

៦–កាបូបលុយចំនួន០១ និងកាតចំនួន០២

៧–ទូរស័ព្ទចំនួន០៤គ្រឿង

ក្រោយកិច្ចប្រតិបត្តិការ និងស្រាវជ្រាវស៊ើបអង្កេតយ៉ាងយកចិត្តទុកដាក់ សមត្ថកិច្ចជំនាញស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុអនុវត្តចំណាត់ការដូចខាងក្រោម៖

១–បញ្ជូនជនរងគ្រោះជាជនជាតិចិនទាំង០៦នាក់ ជូនផែនការងារនគរបាលអន្តោប្រវេសន៍បន្តនីតិវិធី។

២–បញ្ជូនសំណុំរឿងនិងជនសង្ស័យជាជនជាតិចិន ២នាក់ទៅសាលាដំបូងខេត្តព្រះសីហនុ មានតម្រុយក្នុងបទអំពើបង្ខាំង ,សង្ស័យជួញដូរមនុស្សដោយមានគោលដៅ និង បទកាន់កាប់រក្សាទុកអាវុធខុសច្បាប់ ។

៣–បញ្ជូនជនជាតិចិនឈ្មោះ JIN FU DOU ស្នាក់នៅ និងធ្វើការដោយខុសច្បាប់នៅកម្ពុជា (គ្មានលិខិតឆ្លង ដែន) ទៅផែនការងារនគរបាលអន្តោប្រវេសន៍បន្តនីតិវិធី ។

៤–បន្តស្វែងរក និងស្នើសុំដីកាចាប់ខ្លួន ជនជាតិចិន និងបក្ខពួក ជាចារីក្នុងអំពើបង្ខាំង និងអំពើជួញដូរមនុស្សដោយ មានគោដៅ និងអាចមានតម្រុយក្នុងបទល្មើសផ្សេងទៀត ។

# អាជ្ញាធរថៃចាប់ពលករខ្មែរឆ្លងដែនខុសច្បាប់ជាច្រើននាក់ក្រោយចប់ពិធីបុណ្យចូលឆ្នាំថ្មី

https://www.rfa.org/khmer/news/human-rights/thai-authorities-arrest-many-cambodian-illegal-crossers-after-khmer-new-year-04242023095419.html ដោយ មាន ឫទ្ធិ2023.04.24

អាជ្ញាធរថៃឃាត់ខ្លួនពលករខ្មែរដាក់ពន្ធនាគារជាច្រើននាក់ បន្ទាប់ពីពួកគេឆ្លងដែនខុសច្បាប់ ដើម្បីចូលទៅធ្វើការនៅប្រទេសថៃក្រោយពិធីបុណ្យចូលឆ្នាំខ្មែរ។ មន្ត្រីសង្គមស៊ីវិលថា បញ្ហាពុំរ៉ែមួយនេះអាចដោះស្រាយទៅបាន លុះត្រារដ្ឋាភិបាលកម្ពុជាមានវិធានការ និងកិច្ចសម្របសម្រួលដល់ការចេញចូលរបស់ពលករខ្មែរទៅក្រៅប្រទេសឱ្យបានប្រសើរជាងមុន។

ពិធីបុណ្យចូលឆ្នាំថ្មីបានបញ្ចប់ទៅ ពលករខ្មែរធ្វើការនៅប្រទេសថៃដែលមានឯកសារត្រឹមត្រូវបានត្រឡប់ទៅប្រទេសថៃ ជាបន្តបន្ទាប់។ ប៉ុន្តែពលករមួយចំនួននៅតែប្រើប្រាស់ផ្លូវកាត់ ដោយលួចឆ្លងដែនខុសច្បាប់ ព្រោះពួកគេគ្មានប្រាក់សម្រាប់ធ្វើឯកសារនិងរងសម្ពាធត្រូវសងបំណុលធនាគារជាដើម។ការឆ្លងដែនដោយប្រថុយប្រថាននេះ ពលករខ្លះអាចឆ្លងដែនបានសម្រេច និងខ្លះទៀតត្រូវអាជ្ញាធរថៃចាប់ខ្លួន និងយកទៅដាក់ក្នុងពន្ធនាគារ។

ពលករមានស្រុកកំណើតនៅខេត្តបន្ទាយមានជ័យ ដែលឆ្លងដែនទៅធ្វើការនៅប្រទេសថៃ និងត្រូវអាជ្ញាធរថៃចាប់ខ្លួន កញ្ញា យុត ស្រីតូច ប្រាប់វិទ្យុអាស៊ីសេរី នៅថ្ងៃទី២៤ មេសា ថា កញ្ញាបានជាប់ពន្ធនាគារនៅខេត្តស្រះកែវ (Sa Kaeo) ចំនួន៣ថ្ងៃហើយ ដោយសារឆ្លងដែនខុសច្បាប់។ កញ្ញាបន្តថា កញ្ញានិងពលរដ្ឋខ្មែរ៦នាក់ទៀតបានឆ្លងដែលខុសច្បាប់តាមច្រកបឹងត្រកួន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ដើម្បីរកការងារធ្វើយកប្រាក់សងធនាគារ ដោយឱ្យឈ្នួលទៅមេខ្យល់ក្នុងម្នាក់ ១ពាន់បាត ឬ៣០ដុល្លារ។ កញ្ញាប្រាប់ថា អាជ្ញាធរថៃបានយកប្រាក់ពីកញ្ញាចំនួន៤ពាន់បាត ឬជាង ១រយដុល្លារ(១១៦ដុល្លារ) ហើយពួកគេនឹងដោះលែងកញ្ញាវិញ នៅថ្ងៃទី២៥ មេសាស្អែក។

ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣ មេបញ្ជាការកងទ័ពជើងគោកប្រចាំតំបន់ ស្រុកអារញ្ញប្រាថេត (Aranyaprathet) ខេត្តស្រះកែវ បានចាប់ពលករចំណាកស្រុកខុសច្បាប់ជាង ១រយនាក់(១២៣នាក់) ពីកម្ពុជាចូលប្រទេសថៃក្រោយថ្ងៃសង្ក្រាន្ត ក្នុងនោះមានពលករខ្មែរចំនួន ១១២នាក់ ក្មេង៧នាក់ បង់ក្លាដែស (Bangladesh) ចំនួន១១នាក់ ចំណែកជនជាតិថៃ ២នាក់ទៀតគឺជាមេខ្យល់។ ដោយឡែក នៅឯច្រកព្រំដែនកាឈើង (Kap Choeng) ខេត្តសុរិន្ទ ជាប់នឹងព្រំដែនអូរស្មាច់ ខេត្តឧត្តរមានជ័យ អាជ្ញាធរថៃ បានចាប់ពលករខ្មែរឆ្លងដែនខុសច្បាប់ចំនួន ២នាក់។

ក្រុមពលករឆ្លងដែនខុសច្បាប់បានចំណាយប្រាក់ក្នុងម្នាក់ ៤ពាន់ ៥រយបាត ឬ១៣០ដុល្លារឱ្យមេខ្យល់។ ពលករត្រូវដើរដោយថ្មើរជើងរាប់សិបគីឡូម៉ែត្រ និងដេកលាក់ខ្លួនក្នុងព្រៃតាមវាលស្រែ ហាលមូស អត់បាយ យ៉ាងតិច២ថ្ងៃ ដើម្បីរង់ចាំរថយន្តពីឈ្មួញជួញដូរពលករខុសច្បាប់មកដឹកយកទៅធ្វើការនៅតាមបណ្តាខេត្ត។ នៅពេលរថយន្តមកទទួល ពលករទាំងនោះបានបង្កប់ខ្លួននៅក្នុងឃ្លុបរថយន្ត ឬបង្កប់ខ្លួនក្រោមសម្ភារៈ ដូចជាបន្លែ ផ្លែឈើ សំរាម ឬលាមកសត្វជាដើម។ ភាគច្រើននៃពលករខុសច្បាប់ ត្រូវបញ្ជូនទៅធ្វើការនៅតាមការដ្ឋានសំណង់ តាមចម្ការ និងកសិដ្ឋានចិញ្ចឹមសត្វជាដើម ព្រោះកន្លែងទាំងនោះ មិនទាមទារឯកសារស្របច្បាប់នោះទេ ជាថ្នូរមកវិញពលករទទួលបានកម្រៃពលកម្មទាប និងប្រឈមនឹងការកេងប្រវ័ញ្ចកម្លាំងពលកម្ម។

វិទ្យុអាស៊ីសេរី មិនអាចទាក់ទង អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ លោក កែវ វណ្ណថន និងអនុព័ន្ធការងារនៃស្ថានទូតខ្មែរប្រចាំប្រទេសថៃ លោក ឈឹម វិប៊ុល ដើម្បីសុំការបកស្រាយបានទេ នៅថ្ងៃទី២៤ មេសា។

ជុំវិញរឿងនេះ មន្រ្តីផ្នែកការពារសិទ្ធិពលករចំណាកស្រុក នៃអង្គការសង់ត្រាល់ (CENTRAL) ប្រចាំនៅប្រទេសថៃ លោក លឹង សុផុន ឱ្យដឹងថា ភាគច្រើននៃពលករដែលឆ្លងដែនខុសច្បាប់ ព្រោះពួកគេទាល់ច្រក និងប្រញាប់ត្រូវការប្រាក់ដើម្បីយកទៅសងធនាគារ។ លោកបន្តថា បញ្ហានេះជារឿងដដែលៗច្រើនកើតមានករណីរួចមកហើយ ខណៈលោកមិនទាន់ឃើញរដ្ឋាភិបាលកម្ពុជាមានដំណោះស្រាយជាក់លាក់ចំពោះបញ្ហានេះនៅឡើយ។ លោកស្នើឱ្យរដ្ឋាភិបាលកម្ពុជា និងក្រសួងពាក់ព័ន្ធ ចេញមុខទៅសម្របសម្រួលជាមួយភាគីប្រទេសថៃ ក៏ដូចជាផ្ដល់ភាពងាយស្រួលដល់ការចេញចូលរបស់ពលករខ្មែរឱ្យបានល្អប្រសើរជាងមុន។

លទ្ធផលបូកសរុបបណ្ដោះអាសន្ន របស់សមត្ថកិច្ចខេត្តស្រះកែវ ឱ្យដឹងថា គិតត្រឹមថ្ងៃបញ្ចប់នៃបុណ្យចូលឆ្នាំ មានពលករខ្មែរឆ្លងដែនខុសច្បាប់ជិត ៩រយនាក់(៨៧៨នាក់) ហើយដែលអាជ្ញាធរថៃចាប់ខ្លួន។ តាមការឱ្យដឹងពីពលករខ្មែរខុសច្បាប់ដែលកំពុងជាប់ឃុំក្នុងពន្ធនាគារប្រទេសថៃ មានពលរដ្ឋខ្មែរប្រុសស្រី ស្ថិតក្នុងវ័យកំពុងពេញកម្លាំងបានជាប់ឃុំក្នុងបន្ទប់រួម មានគ្នាប្រមាណជាង ១០នាក់ ក្នុងមួយបន្ទប់ ដោយស្ត្រីនៅដោយឡែកពីបុរស។ ពលរដ្ឋទាំងនោះភាគច្រើនបង្ខំចិត្តឆ្លងដែនទាំងខុសច្បាប់ ដោយសារនៅស្រុកកំណើតគ្មានការងារធ្វើ មានជីវភាពខ្វះខាត និងជំពាក់បំណុលធនាគារ ខណៈមួយចំនួនចាញ់បោកមេខ្យល់ និងខ្លះរង់ចាំឯកសារឆ្លងដែនយូរពេក។

របាយការណ៍ក្រសួងការងារឱ្យដឹងថា ត្រឹមដំណាច់ឆ្នាំ២០២២ មានពលករកម្ពុជាកំពុងស្នាក់នៅ និងធ្វើការនៅក្រៅប្រទេស សរុបជាង ១លាន៣សែននាក់ ក្នុងនោះប្រទេសថៃ មានចំនួនជាង ១លាន២សែននាក់។ ចំណែករបាយការណ៍របស់អង្គការសង់ត្រាល់ (Central) រកឃើញថា ពលករខ្មែរ ដែលកំពុងរស់នៅ និងធ្វើការក្នុងប្រទេសថៃ ទាំងស្របច្បាប់ និងមិនស្របច្បាប់មានជាងពីរលាននាក់។ ករណីអាជ្ញាធរថៃចាប់ពលករខ្មែរដែលឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ បានម្ដងរាប់រយនាក់នេះ បានធ្វើឱ្យប្រជាពលរដ្ឋខ្មែរ និងប្រជាពលរដ្ឋថៃមានចម្ងល់ថា លោកនាយករដ្ឋមន្រ្តី ហ៊ុន សែន ដែលជាមេដឹកនាំចិត្តល្អម្នាក់ និងតែងតែជួយយកអាសាអន្តោប្រវេសន៍ដែលមករស់នៅលើទឹកដីកម្ពុជា ហេតុអ្វីមិនព្រមដោះស្រាយបញ្ហាជួយពលករខ្លួនឯង និងបណ្ដោយឱ្យពួកគេឆ្លងដែនខុសច្បាប់ដែលធ្វើឱ្យប៉ះពាល់ដល់មុខមាត់កម្ពុជាយ៉ាងដូច្នេះ៕

# ថ្ងៃទី២៧ ខែ មេសា ឆ្នាំ២០២៣

## សមត្ថកិច្ចកម្ពុជា បន្តទទួលបានបណ្ដឹង ៤ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៤នាក់

https://freshnewsasia.com/index.php/en/localnews/288259-2023-04-25-03-45-40.html 2023-04-25 10:45am

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី២៣ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៤ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ចំនួន០៤នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្ដេចក្រឡាហោម សរុប ៨៥៩ករណី មានមនុស្ស ២,១៤៥នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៨១៤សំណើ និងបិទសំណុំរឿង ២៧៧សំណើ (រកឃើញមនុស្ស ១,២២៨នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣០នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៤៥ករណី៕

## តុលាការកំពូលបង្វិលសំណុំរឿង អតីតអ្នកតំណាងរាស្ត្រ អះម៉ាត់យ៉ះយ៉ា និង ក្មួយប្រុស ពាក់ព័ន្ធការលក់ដូរស្ត្រីខ្មែរ២នាក់ នៅទីបអារ៉ាប់ ទៅតុលាការឧទ្ធរណ៍ ដើម្បីជំនុំជម្រះ ជាថ្មីឡើងវិញ!!

https://cen.com.kh/archives/651822.html Posted ByPen Srey NeatApril 26, 2023

ភ្នំពេញៈ តុលាការកំពូល កាលពីព្រឹកថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០២៣ បានប្រកាសសាលដីកា លើបណ្ដឹងសារទុក្ខរបស់ជនជាប់ចោទ ឈ្មោះ អះម៉ាត់ យ៉ះយ៉ា និង ក្មួយប្រុសម្នាក់ ដែលត្រូវបានតុលាការជាន់ទាប កាលពីអំឡុងឆ្នាំ ២០១៩ កាត់ទោស ពួកគេទាំង២នាក់ដាក់គុក ក្នុងម្នាក់ៗ កំណត់ ១៥ ឆ្នាំ ជាប់ពាក់ព័ន្ធនឹងការសង្ស័យការនាំចេញដោយមិនស្របច្បាប់ នូវពលករខ្មែរចំនួនជាង៣០០នាក់ ទៅធ្វើការ នៅប្រទេសអារ៉ាប៊ីសាអូឌីត និងបានបណ្តាលឲ្យស្ត្រីខ្មែរចំនួន២នាក់(ជនរងគ្រោះ) ត្រូវបានគេលក់ដូរដូចសត្វធាតុ ពីគ្រួសារអារ៉ាប់មួយ ទៅគ្រួសារផ្សេងទៀត និងត្រូវបានគេបង្ខំឲ្យធ្វើការដូចទាសករ ដោយគ្មានប្រាក់ខែអស់រយៈពេលជិត ១៣ ឆ្នាំ នៅក្នុងអារ៉ាវសាអូឌីត ពីឆ្នាំ ២០០៤ រហូតដល់ឆ្នាំ ២០១៧។ តុលាការកំពូលបានសម្រេច បង្វិលសំណុំរឿងនេះ ត្រឡប់ទៅកាន់សាលាឧទ្ធរណ៍រាជធានីភ្នំពេញ ដើម្បី ធ្វើការជំនុំជម្រះសាជាថ្មីឡើងវិញ ដោយសារតែ មានចំណុចសង្ស័យ និងចន្លោះប្រហោង ជាច្រើន ដែលសាលាឧទ្ធរណ៍ មិនទាន់បានពិនិត្យ ពិចារណា នៅឡើយ។

លោក គង់ ស្រ៊ឹម ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ នៃតុលាការកំពូល បានថ្លែងថា៖ នៅក្នុងរឿងក្តីឧក្រិដ្ឋនេះ ជនជាប់ចោទឈ្មោះ អះម៉ាត់ យ៉ះយ៉ា ភេទ ប្រុស អាយុ ៧០ ឆ្នាំ ជាខ្មែរអ៊ីស្លាម , ជាអតីតអ្នកតំណាងរាស្ត្រ និងជារដ្ឋលេខាធិការ ក្រសួងសាធារណៈការនិងដឹកជញ្ជូន និង ជាប្រធានក្រុមហ៊ុនAccent Group និងឈ្មោះ អ៊ីស្មាអែល ពិនឧស្មាន ភេទ ប្រុស អាយុ ៥០ ឆ្នាំ ជនខ្មែរអ៊ីស្លាម និង ជាអតីតមន្ត្រីរាជការ ធ្វើការនៅក្រសួងសាធារណៈការនិងដឹកជញ្ជូន ត្រូវបានសាលាដំបូងខេត្តរាជធានីភ្នំពេញ កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៩ កាត់ទោស ដាក់ពន្ធនាគារ ក្នុង ម្នាក់ៗ កំណត់ ១៥ ឆ្នាំ និងបង្គាប់ឱ្យសងជំងឺចិត្តពួកគេទាំង២នាក់ ពូនិងក្មួយ ត្រូវរួមគ្នាសងជនរងគ្រោះចំនួន២នាក់ សរុប ២០០លានរៀល ពីបទៈ នាំចេញដោយមិនស្របច្បាប់ សម្រាប់ឆ្លងដែន តាមមាត្រា ១១ នៃ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិង ការធ្វើអាជីវកម្មផ្លូវភេទ។

ជនជាប់ចោទទាំង២នាក់ បានប្តឹងឧទ្ធរណ៍ ។ តែសាលាឧទ្ធរណ៍រាជធានីភ្នំពេញ បានតម្កល់ទណ្ឌកម្មរបស់ពួកគេរក្សាទុកជាបានការដដែល ។ ពួកគេក៏បានបន្តប្តឹងសាទុក្ខ មកកាន់តុលាការកំពូលទៀត។នៅក្នុងចំណោមពួកគេទាំង២នាក់ ជនជាប់ចោទឈ្មោះ អ៊ីស្មាអែល ពិនឧស្មាន ត្រូវបានឃាត់ខ្លួនកាលពីថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៨ នៅរាជធានីភ្នំពេញ រីឯជនជាប់ចោទឈ្មោះ អះម៉ាត់យ៉ះយ៉ា ត្រូវបានចាប់ឃាត់ និងឃុំខ្លួន កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០២១ បន្ទាប់ពី តុលាការរាជធានីភ្នំពេញ បានប្រកាសសាលក្រម និងសម្រេចផ្តន្ទាទោសគាត់ដាក់ពន្ធនាគារ កំណត់ ១៥ ឆ្នាំ។

គួរបញ្ជាក់ថាៈ នាពេលសវនាការ កន្លងមក ជនជាប់ចោទទាំង២នាក់ ពូ និង ក្មួយ បានឆ្លើយបដិសេធចំពោះការចោទប្រកាន់ និង ការផ្តន្ទាទោស ពួកគេ អំពើ សំណាក់ តុលាការរាជធានីភ្នំពេញ និងតុលាការឧទ្ធរណ៍

រាជធានីភ្នំពេញ។ ពួកគាត់ បានសំណូមពរដល់ថៅក្រមប្រឹក្សាជំនុំជម្រះតុលាការកំពូលមេត្តា ជួយរកយុត្តិធម៌ និងសម្រេចដោះលែងពួកគាត់ ឱ្យមានសេរីភាពវិញ៕ រក្សាសិទ្ធដោយៈ ចន្ទា ភា

## ពលករខ្មែរ១២៣នាក់ ដោយមានទាហានថៃ២នាក់នាំផ្លូវ លួចឆ្លងដែនទៅប្រទេសថៃ ត្រូវសមត្ថកិច្ចឃាត់ខ្លួន

https://freshnewsasia.com/index.php/en/localnews/288444-2023-04-26-05-25-30.html 2023-04-26 12:25pm

**(បន្ទាយមានជ័យ)៖** ពលករខ្មែរ១២៣នាក់ (មានប្រុស ស្រី ក្មេងចាស់) ដោយមានទាហានថៃ២នាក់ជាមេខ្យល់ បានលួចឆ្លងដែនទៅប្រទេសថៃ ត្រូវសមត្ថកិច្ចថៃឃាត់ខ្លួនបាននៅយប់ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ ក្នុងភូមិសាស្ត្រភូមិទី៨ ឃុំមឿងផៃ ស្រុកអារញ្ញប្រទេស ខេត្តស្រះកែវ។

តាមសេចក្ដីរាយការណ៍ពីភ្នាក់ងារព័ត៌មាន Fresh News បានឲ្យដឹងថា ក្រោយពីឃាត់ពលករទាំង១២៣នាក់ហើយ សមត្ថកិច្ចបានបញ្ជូនពលពលករទាំងអស់ទៅស្ថាប័នពាក់ព័ន្ធ ដើម្បីចាត់ការបន្តតាមនិតិវិធីផ្លូវច្បាប់។

តាមការសាកសួររបស់សមត្ថកិច្ចថៃ, ទើបដឹងថា ពលករខ្មែរទាំងនោះ បានព្យាយាមចូលទៅប្រទេសថៃ ដោយឲ្យមេខ្យល់ថៃនាំពួកខ្លួនចូលទៅបាងកកទាំងប្រថុយប្រថាន តាមច្រករបៀងដើម្បីទៅរកការងារធ្វើនៅប្រទេសថៃ ប៉ុន្តែក៏ត្រូវបានទាហានថៃចាប់ឃាត់ខ្លួនតែម្តង។

ពលករខ្មែរទាំងខាងលើបានឲ្យដឹងថា ពេលចូលឆ្នាំហើយពួកខ្លួនទាំងអស់គ្មានការងារធ្វើ ហើយក្នុងគ្រួសារជួបប្រទះការខ្វះខាត ទើបបបួលគ្នាបង្ខំចិត្តលួចឆ្លងដែនខុសច្បាប់ ប្រុងទៅរកការងារធ្វើនៅប្រទេសថៃ តាមរយៈមេខ្យល់ថៃឆ្លងដែនខុសច្បាប់៕

# ថ្ងៃទី២៨ ខែ មេសា ឆ្នាំ២០២៣

## រដ្ឋមន្ត្រីមហាផ្ទៃបញ្ជា អាជ្ញាធរបន្តបង្ក្រាបអំពើជួញដូរមនុស្ស និងស្រាវជ្រាវរកជនល្មើស មកផ្ដន្ទាទោស

https://dap-news.com/national/2023/04/26/327697/ BySS107Posted on April 26, 2023

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានបញ្ជាឲ្យអាជ្ញាធរ បន្តត្រួតពិនិត្យ និងបង្ក្រាបករណីបង្ខាំងមនុស្ស ការរឹតត្បិតសេរីភាព ការធ្វើទារុណកម្ម ព្រមទាំងអំពើជួញដូរមនុស្សគ្រប់ប្រភេទ ហើយស្រាវជ្រាវរកជនល្មើសមកផ្តន្ទាទោសតាមច្បាប់។

គិតចាប់ពីថ្ងៃទី១៨ ខែសីហា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ កន្លងទៅនេះ គណៈបញ្ជាការដឹកនាំប្រតិបត្តិការ នៃ គ.ជ.ប.ជ ដឹកនាំដោយ នាយឧត្តមសេនីយ៍នេត សាវឿន អគ្គស្នងការដ្ឋាននគរបាលជាតិ បានទទួលបញ្ជីតាមដានពាក់ព័ន្ធសំណើ និងសំណូមពរ តាមរយៈ Facebook សម្តេច និងប្រភពផ្សេងៗទៀត ចំនួន ៦៩២សំណើ ក្នុងនោះ សំណើ និងសំណូមពរ ស្ទួនមាន ៣១សំណើ ដូច្នេះសំណើជាក់ស្តែងមានចំនួន ៦៦១សំណើ។ ផ្អែកតាមប្រតិបត្តិការស្រាវជ្រាវ ស៊ើបអង្កេតលើសំណើ សំណូមពរ ដែលទទួលបានទាំង ៦៦១សំណើ បានស្រាវជ្រាវរកឃើញចំនួន ៤៣១សំណើ មនុស្សសរុប ១.០៣១នាក់។

តាមរយៈគេហទំព័រហ្វេសប៊ុក នៅយប់ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ សម្ដេច ស ខេង បានសរសេរថា តាមរយៈលទ្ធផល នៃកិច្ចប្រតិបត្តិការនេះ អាចសន្និដ្ឋាន និងវាយតម្លៃបានថា ឆ្លងកាត់រយៈពេលជាង ៤ខែ នៃចុងឆ្នាំ២០២២ កន្លងទៅ សមត្ថកិច្ចពាក់ព័ន្ធបានសហការគ្នាធ្វើសកម្មភាពយ៉ាងសស្រាក់សស្រាំ ដើម្បីប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវ កម្មផ្លូវភេទ ប្រកបដោយវិជ្ជាជីវៈ និងប្រសិទ្ធិភាព ធ្វើឲ្យសភាពការណ៍ ពាក់ព័ន្ធដល់សំណើសុំអន្តរាគមន៍ជួយដល់ជនបរទេស មានការថយចុះគួរឲ្យកត់សម្គាល់។

សម្តេច គូសបញ្ជាក់ថា «ខ្ញុំសូមបញ្ជាក់ជូនថា អាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចកម្ពុជា នៅតែបន្តជំរុញសកម្មភាពក្នុងការត្រួតពិនិត្យ និងបង្ក្រាបទីតាំងអាជីវកម្ម ក្នុងករណីមានសំណើ ឬមានព័ត៌មានជាក់លាក់ពាក់ព័ន្ធទៅនឹងបទល្មើស ការបង្ខាំងមនុស្ស ការរិតត្បិតសេរីភាព ការធ្វើទារុណកម្ម អំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ការលួចលាក់បើកអាជីវកម្មល្បែង ស៊ីសងខុសច្បាប់គ្រប់ប្រភេទ ព្រមទាំងស្រាវជ្រាវរកជនល្មើសដើម្បីផ្តន្ទាទោសតាមច្បាប់»។ សម្តេច បន្ថែមថា អាជ្ញាធរនឹងបន្តពិនិត្យលើសំណើសុំអន្តរាគមន៍ដែលត្រូវបានបិទជាបណ្តោះអាសន្ន ដើម្បីវាយតម្លៃ និងបន្តការងារស្រាវជ្រាវ ស្វែងរកតាមសំណើ ឬសំណូមពរ សំដៅធានាសុវត្ថិភាពឲ្យបានដាច់ខាតដល់ ជនបរទេសដែលស្នើសុំអន្តរាគមន៍ ព្រមទាំងស្រាវជ្រាវ ស៊ើបអង្កេតឲ្យបានហ្មត់ចត់ និងចាត់វិធានការឱ្យបានម៉ឺងម៉ាត់ចំពោះជនបទសដែលប្តឹងបំប៉ោងព័ត៌មាន ឬបំពុលបរិយាកាសសង្គម ដោយសារតែប្រយោជន៍ផ្ទាល់ខ្លួន។

សម្តេច បន្តថា ឈរលើការងារដ៏មានសារៈសំខាន់នេះ អាជ្ញាធរនឹងបន្តពិនិត្យ វាយតម្លៃលើសំណុំរឿង ដែលពាក់ព័ន្ធបទល្មើស ដើម្បីពន្លាតនីតិវិធីប្រឆាំងការសម្អាតប្រាក់ ពង្រឹងការងារគ្រប់គ្រង ត្រួតពិនិត្យតំបន់ព្រំដែន និងច្រកទ្វារព្រំដែន ពិកនៅតាមច្រក សមុទ្រ សំដៅទប់ស្កាត់ការលួចជ្រៀតចូលឆ្លងដែនដោយខុសច្បាប់របស់ជនបរទេស និងបង្កើនកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេស ដែលមានជនជាតិរបស់ខ្លួន។ ជាមួយគ្នានេះ សម្តេច ស ខេង បានជម្រាបជូនសាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ សហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព៕

## សម្ដេចក្រឡាហោម សខេង ៖ សំណូមពរ តាមរយៈ Facebook ខ្ញុំ និងប្រភពផ្សេងៗទៀត ដោះស្រាយបានសរុបចំនួន ៦៩២សំណើ

http://nokorwatnews.com/archives/994237 06/04/2023

ភ្នំពេញ ៖ សម្តេចក្រឡាហោម សខេង ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅយប់ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ បានមានប្រសាសន៍ថា, ថ្ងៃនេះក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមជម្រាបជូនសាធារណជនជាតិ-អន្តរជាតិ អំពីការបូកសរុបលទ្ធផលនៃការអនុវត្តផែនការប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ដែលជនរងគ្រោះ សាច់ញាតិ សមាគមអង្គការក្រៅរដ្ឋាភិបាល បណ្តាស្ថានទូតប្រទេសជាមិត្ត បានលើកសំណើ និងសំណូមពរ មក Facebook ខ្ញុំ និងប្រភពផ្សេងៗទៀត គិតចាប់តាំងពីថ្ងៃទី១៨ ខែសីហា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២កន្លងទៅនេះ។

សម្តេច ក្រឡាហោម សខេង បានបន្តថា គិតចាប់ពីថ្ងៃទី១៨ ខែសីហា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ កន្លងទៅនេះ គណៈបញ្ជាការដឹកនាំប្រតិបត្តិការ ដឹកនាំដោយឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ដែលជាប្រធានគណៈបញ្ជាការដឹកនាំប្រតិបត្តិការ នៃគណៈកម្មធិ

ការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានទទួលបញ្ជីតាមដាន ពាក់ព័ន្ធសំណើ និងសំណូមពរ តាមរយៈ Facebook ខ្ញុំ និងប្រភពផ្សេងៗទៀត សរុបចំនួន ៦៩២សំណើ មានជនបរទេសសរុបចំនួន ១.៦៨២នាក់ (ស្រី ១៧៥នាក់) ក្នុងនោះសំណើ និងសំណូមពរ ស្ទួនមាន៣១សំណើ ជនបរទេស ៨៦នាក់ (ស្រី៣នាក់)។ ដូច្នេះ សំណើជាក់ស្តែងមានចំនួន ៦៦១សំណើ ជនបរទេស ១.៥៩៦នាក់ (ស្រី ១៧២នាក់)ស្មើ១៦សញ្ជាតិ។

របាយការណ៍បានលម្អិតថាក្នុងចំណោមអ្នកដែលបានដាក់សំណើ និងសំណូមពរ សុំកិច្ចអន្តរាគមន៍នោះ រួមមានៈ ជនជាតិខ្មែរ៩នាក់, ចិន ៦៦៨នាក់, ជប៉ុន១នាក់, ថៃ៩នាក់, នេប៉ាល់១នាក់, បង់ក្លាដេស ២២នាក់, ប៉ាគីស្ថាន១នាក់, ម៉ាឡេស៊ី១៤៤នាក់, មីយ៉ាន់ម៉ា៥នាក់, វៀតណាម៤៦៦នាក់, សិង្ហបូរី ១នាក់, ស្រីលង្កា៤នាក់, ហ្វីលីពីន២នាក់, ឥណ្ឌា ៨៣នាក់, ឥណ្ឌូនេស៊ី១៧៨នាក់ និង អាមេរិក ២នាក់។

ចំណែក រាជធានី-ខេត្ត ដែលពាក់ព័ន្ធនឹងសំណើ ឬសំណូមពរឲ្យជួយអន្តរាគមន៍ សរុបចំនួន ១២ រួមមានៈ រាជធានីភ្នំពេញ, ខេត្តព្រះសីហនុ, កណ្តាល, ឧត្តរមានជ័យ, កោះកុង, ស្វាយរៀង, ពោធិ៍សាត់, កំពត, បន្ទាយមានជ័យ, ប៉ៃលិន, កំពង់ស្ពឺ និងខេត្តត្បូងឃ្មុំ។ ផ្អែកតាមប្រតិបត្តិការស្រាវជ្រាវ ស៊ើបអង្កេតលើសំណើ សំណូមពរដែលទទួលបានទាំង ៦៦១សំណើ រួមមានដូចខាងក្រោមៈ

១.បានស្រាវជ្រាវរកឃើញចំនួន ៤៣១សំណើ មនុស្សសរុប ១.០៣១នាក់ (ស្រី ១០៩នាក់) ស្មើ ១៣ សញ្ជាតិ ដោយក្នុងប្រតិបត្តិការខាងលើ សមត្ថកិច្ចបានរកឃើញករណីពាក់ព័ន្ធបទល្មើសចំនួន ២៩ករណី ក្នុងនោះជួយសង្គ្រោះជនរងគ្រោះសរុបចំនួន១៧០នាក់ និងស្លាប់១នាក់ ស្មើនឹង៦សញ្ញាតិ រួមមានចិន ៤៦នាក់, ម៉ាឡេស៊ី ៥នាក់, វៀតណាម១០៤នាក់, ឥណ្ឌា៦នាក់, ឥណ្ឌូនេស៊ី៨នាក់ និង អាមេរិក២នាក់។ សមត្ថកិច្ចបានបញ្ជូនទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ១២៦នាក់ ស្មើ៦សញ្ជាតិ ធ្វើកិច្ចសន្យាធានាឱ្យមានសេរីភាព៥នាក់ ប្រគល់ជូនស្ថានទូតវៀតណាម៨នាក់, បញ្ជូនចេញភ្លាមៗ៣១នាក់, និងប្រគល់សាកសព១នាក់ (ចិន) ជូនក្រុមគ្រួសារធ្វើបុណ្យតាមប្រពៃណី។

ក្នុងកិច្ចប្រតិបត្តិការខាងលើនេះ សមត្ថកិច្ចបាន ឃាត់ខ្លួនជនសង្ស័យចំនួន១២០នាក់ ស្មើ៤សញ្ជាតិ រួមមានៈ ចិន៩០នាក់, ខ្មែរ១៧នាក់, វៀតណាម ១០នាក់ និងថៃ៣នាក់ កសាងសំណុំរឿងបញ្ជូន ទៅតុលាការ។ សមត្ថកិច្ចក៏ រកឃើញក្រុមហ៊ុន និងទីតាំងអាជីវកម្មចំនួន៩ក្រុមហ៊ុន ដែលសង្ស័យពាក់ព័ន្ធបទល្មើស ក្នុងនោះ ត្រូវបានរដ្ឋបាលខេត្តព្រះសីហនុ ចេញ ស.ជ.ណ បិទអាជីវកម្មទាំងស្រុងចំនួន ៥ក្រុមហ៊ុន (ហ្គាឡាក់ស៊ីវើល, ឆាងធឹង, ស៊ីនហ័រខឺ ម៉ោនចិន, ជើងឆាយ៥ និងប៉ាវយ៉ុង តិចណូឡូជី) និងផ្អាក អាជីវកម្មបណ្តោះអាសន្ន ចំនួន៤ទីតាំង (ប៊ីឆេងស៊ីណាធើណេសិនណល អេនធើធេនមែន, លិស៊ីង, ហ័ងគន និងរស្មីសេរីមង្គល) ដើម្បីបន្តនីតិវិធីស្រាវជ្រាវ និងស៊ើបអង្កេតបន្ថែម។

២.សំណើចំនួន ២៣០សំណើមនុស្សចំនួន៥៦៥នាក់ (ស្រី៦១នាក់) ក្នុងនោះ ខ្មែរ១នាក់, ចិន២៣២នាក់, ថៃ ២នាក់, បង់ក្លាដេស២នាក់, ប៉ាគីស្ថាន១នាក់, ម៉ាឡេស៊ី ៣៤នាក់, វៀតណាម១៩០នាក់, សិង្ហបូរី១នាក់ ហ្វីលីពីន២នាក់, ឥណ្ឌា៤០នាក់ និងឥណ្ឌូនេស៊ី ៦០នាក់ ពុំបានរកឃើញនៅក្នុងទីតាំងតាមសំណើសុំអន្តរាគមន៍ គឺអាស្រ័យដោយទីតាំងមិនដំណើរការ ឬបិទអាជីវកម្ម សាម៉ីខ្លួនបានលាឈប់ពីការងារ ឬបានចាកចេញពីទីតាំងដោយ ខ្លួនឯងមុនកិច្ចប្រតិបត្តិការរបស់សមត្ថកិច្ច ព័ត៌មានមិនគ្រប់គ្រាន់ ឬគ្មានតម្រុយក្នុងការស្រាវជ្រាវ។ សំណើទាំងអស់នេះត្រូវបានបិទការស្រាវជ្រាវ ស៊ើបអង្កេតបណ្តោះអាសន្ន ប៉ុន្តែក្នុងករណីមានតម្រុយ សង្ស័យបន្ថែម សមត្ថកិច្ចនឹងបើកប្រតិបត្តិការស្រាវជ្រាវ ស៊ើបអង្កេតបន្តទៀត។

ឆ្លងតាមរយៈលទ្ធផលនៃកិច្ចប្រតិបត្តិការនេះ យើងអាចសន្និដ្ឋាន និងវាយតម្លៃបានថាឆ្លងកាត់រយៈពេលជាង ៤ខែនៃចុងឆ្នាំ២០២២កន្លងទៅ សមត្ថកិច្ចពាក់ព័ន្ធបានសហការគ្នាធ្វើសកម្មភាពយ៉ាងសស្រាក់សស្រាំ ដើម្បី

ប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវ កម្មផ្លូវភេទប្រកបដោយវិជ្ជាជីវៈនិងប្រសិទ្ធិភាពដែលបានធ្វើឲ្យសភាពការណ៍ដែលពាក់ព័ន្ធដល់សំណើសុំអន្តរាគមន៍ជួយដល់ជនបរទេស មានការថយចុះគួរឲ្យកត់សម្គាល់។

ខ្ញុំសូមបញ្ជាក់ជូនថាអាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចកម្ពុជា នៅតែបន្តជំរុញសកម្មភាពក្នុងការត្រួតពិនិត្យ និងបង្ក្រាបទីតាំងអាជីវកម្ម ក្នុងករណីមានសំណើ ឬមានព័ត៌មានជាក់លាក់ពាក់ព័ន្ធទៅនឹងបទល្មើស ការបង្ខាំងមនុស្ស ការរិតត្បិតសេរីភាព ការធ្វើ ទារុណកម្ម អំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ការលួចលាក់បើកអាជីវកម្មល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ព្រមទាំងស្រាវជ្រាវរកជនល្មើស ដើម្បីផ្តន្ទាទោសតាមច្បាប់។ យើងនឹងបន្តពិនិត្យលើសំណើសុំអន្តរាគមន៍ដែលត្រូវបានបិទជាបណ្តោះអាសន្ន ដើម្បីវាយតម្លៃ និងបន្តការងារស្រាវជ្រាវ ស្វែងរកតាមសំណើ ឬសំណូមពរ សំដៅធានាសុវត្ថិភាពឲ្យបានដាច់ខាតដល់ ជនបរទេសដែលស្នើសុំអន្តរាគមន៍ ព្រមទាំងស្រាវជ្រាវ ស៊ើបអង្កេតឲ្យបានហ្មត់ចត់ និងចាត់វិធានការឱ្យបានម៉ឺងម៉ាត់ចំពោះជនបទសដែលប្តឹងបំប៉ោងព័ត៌មាន ឬបំពុលបរិយាកាសសង្គម ដោយសារតែប្រយោជន៍ផ្ទាល់ខ្លួន។

ឈរលើការងារដ៏មានសារៈសំខាន់នេះដែរ យើងក៏នឹងបន្តពិនិត្យ វាយតម្លៃលើសំណុំរឿងដែលពាក់ព័ន្ធបទល្មើស ដើម្បីពន្លាតនីតិវិធីប្រឆាំងការសម្អាតប្រាក់ ពង្រឹងការងារគ្រប់គ្រង ត្រួតពិនិត្យតំបន់ព្រំដែន និងច្រកទ្វារព្រំដែន ពិកនៅតាមច្រក សមុទ្រ សំដៅទប់ស្កាត់ការលួចជ្រៀតចូលឆ្លងដែនដោយខុសច្បាប់របស់ជនបរទេស និងបង្កើនកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសដែលមានជនជាតិរបស់ខ្លួន ប្រកាសថា ជាជនរងគ្រោះហើយស្នើសុំអន្តរាគមន៍ ដើម្បីធ្វើការស្រាវជ្រាវ អង្កេត និងបង្ក្រាបឲ្យបាននូវមេខ្លោង ខ្សែរយៈបណ្តាញមានអង្គការចាត់តាំងដែលធ្វើការអូសទាញ ឬកបញ្ឆោតជនបរទេស ឲ្យ ឆ្លងដែនដោយស្របច្បាប់ ខឹងមិនស្របច្បាប់ចូលមកកម្ពុជា ធ្វើការងារដោយខុសច្បាប់។

ជាថ្មីម្តងទៀតក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមជម្រាប់ជូនសាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ សហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព៕

## សម្តេចក្រឡាហោម ស ខេង ឱ្យអាជ្ញាធរបន្តបង្ក្រាបអំពើជួញដូរមនុស្ស និងស្រាវជ្រាវរកជនល្មើសមកផ្តន្ទាទោសតាមច្បាប់

https://www.information.gov.kh/articles/102796 ចេញផ្សាយ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២៣

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ.) បានបញ្ជាឱ្យអាជ្ញាធរបន្តត្រួតពិនិត្យ និងបង្ក្រាបករណីបង្ខាំងមនុស្ស ការរិតត្បិតសេរីភាព ការធ្វើទារុណកម្ម ព្រមទាំងអំពើជួញដូរមនុស្សគ្រប់ប្រភេទ ហើយស្រាវជ្រាវរកជនល្មើសមកផ្តន្ទាទោសតាមច្បាប់ផងដែរ។

គិតចាប់ពីថ្ងៃទី១៨ ខែសីហា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២កន្លងទៅនេះ គណៈបញ្ជា ការដឹកនាំប្រតិបត្តិការ នៃ គ.ជ.ប.ជ. ដឹកនាំដោយនាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការដ្ឋាននគរបាលជាតិ បានទទួលបញ្ជីតាមដានពាក់ព័ន្ធសំណើ និងសំណូមពរ តាមរយៈ Facebook សម្តេច និងប្រភពផ្សេងៗទៀត ចំនួន ៦៩២សំណើ ក្នុងនោះ សំណើ និងសំណូមពរ ស្ទួនមាន ៣១សំណើ ដូច្នេះសំណើជាក់ស្តែងមានចំនួន ៦៦១សំ

ណើ។ ផ្អែកតាមប្រតិបត្តិការស្រាវជ្រាវ ស៊ើបអង្កេតលើសំណើ សំណូមពរ ដែលទទួលបានទាំង ៦៦១សំណើ បាន ស្រាវជ្រាវរកឃើញចំនួន ៤៣១សំណើ មនុស្សសរុប ១ ០៣១នាក់។

តាមរយៈគេហទំព័រហ្វេសប៊ុក នៅយប់ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ សម្តេច ស ខេង បានសរសេរថា តាមរយៈលទ្ធផល នៃកិច្ចប្រតិបត្តិការនេះ អាចសន្និដ្ឋាន និងវាយតម្លៃបានថា ឆ្លងកាត់រយៈពេលជាង ៤ខែ នៃចុង ឆ្នាំ២០២២កន្លងទៅ សមត្ថកិច្ចពាក់ព័ន្ធបានសហការគ្នាធ្វើសកម្មភាពយ៉ាងសស្រាក់សស្រាំ ដើម្បីប្រយុទ្ធប្រឆាំង គ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ប្រកបដោយវិជ្ជាជីវៈ និងប្រសិទ្ធភាព ។ ធ្វើ ឱ្យសភាពការណ៍ ពាក់ព័ន្ធដល់សំណើសុំអន្តរាគមន៍ ជួយដល់ជនបរទេស មានការថយចុះគួរឱ្យកត់សម្គាល់។

សម្តេចក្រឡាហោម គូសបញ្ជាក់ថា « ខ្ញុំសូមបញ្ជាក់ជូនថា អាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចកម្ពុជា នៅតែបន្តជំរុញសកម្មភាពក្នុងការត្រួតពិនិត្យ និងបង្ក្រាបទីតាំងអាជីវកម្ម ក្នុងករណីមានសំណើ ឬមានព័ត៌មានជាក់ លាក់ពាក់ព័ន្ធទៅនឹងបទល្មើស ការបង្ខាំងមនុស្ស ការរឹតត្បិតសេរីភាព ការធ្វើទារុណកម្ម អំពើជួញដូរមនុស្ស ជួញ ដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ការលួចលាក់ បើកអាជីវកម្មល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ព្រមទាំង ស្រាវជ្រាវរកជនល្មើស ដើម្បីផ្តន្ទាទោសតាមច្បាប់ »។ សម្តេច បន្ថែមថា អាជ្ញាធរនឹងបន្តពិនិត្យលើសំណើសុំ អន្តរាគមន៍ ដែលត្រូវបានបិទជាបណ្តោះអាសន្ន ដើម្បីវាយតម្លៃ និងបន្តការងារស្រាវជ្រាវ ស្វែងរកតាមសំណើ ឬ សំណូមពរ សំដៅជានាសុវត្ថិភាពឱ្យបានដាច់ខាត ដល់ជនបរទេស ដែលស្នើសុំអន្តរាគមន៍ ព្រមទាំងស្រាវជ្រាវ ស៊ើបអង្កេតឱ្យបានហ្មត់ចត់ និងចាត់វិធានការឱ្យបានម៉ឺងម៉ាត់ចំពោះជនបរទេស ដែលប្តឹងបំប៉ោងព័ត៌មាន ឬបំពុល បរិយាកាសសង្គម ដោយសារតែប្រយោជន៍ផ្ទាល់ខ្លួន។

សម្តេច បានបន្តទៀតថា ឈរលើការងារដ៏មានសារៈសំខាន់នេះ អាជ្ញាធរនឹងបន្តពិនិត្យ វាយតម្លៃលើសំណុំ រឿង ដែលពាក់ព័ន្ធបទល្មើស ដើម្បីពន្លាតនីតិវិធីប្រឆាំងការសម្អាតប្រាក់ ពង្រឹងការងារគ្រប់គ្រង ត្រួតពិនិត្យតំបន់ព្រំ ដែន និងច្រកទ្វារព្រំដែន ពិតនៅតាមច្រកសមុទ្រ សំដៅទប់ស្កាត់ការលួចជ្រៀតចូលឆ្លងដែនដោយខុសច្បាប់ របស់ ជនបរទេស និងបង្កើនកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេស ដែលមានជនជាតិរបស់ខ្លួន។ ជាមួយគ្នានេះ សម្តេចក្រឡាហោម ស ខេង ក៏បានជម្រាបជូនសាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និង អាជ្ញាធរមានសមត្ថកិច្ច នៃបណ្តាប្រទេសពាក់ព័ន្ធ សហការផ្តល់ព័ត៌មាន ពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្ម ឆ្លងដែនផ្សេងទៀត ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព ៕ដោយអ៊ាង ប៊ុនរិទ្ធ សម្រួលផ្សាយដោយ៖ ធូ កុសល

## ឯកអគ្គរាជទូតថៃ ស្នើអគ្គស្នងការនគរបាលជាតិ ពង្រឹងកិច្ចសហប្រតិបត្តិការ ប្រយុទ្ធ ប្រឆាំងបទល្មើសឆ្លងដែនគ្រប់ប្រភេទ និងល្បែងអនឡាញខុសច្បាប់

https://cen.com.kh/archives/652302.html Posted ByPen Srey NeatApril 27, 2023

ភ្នំពេញ ៖ នារសៀលថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ នេះ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានទទួលស្វាគមន៍ ឯកឧត្តម ឈើតគៀ ត អាត់ថាក័រ (Cherdkiat ATTHAKOR) ឯកអគ្គរាជទូតថៃប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលអញ្ជើញចូលជួប សម្តែងការគួរសម និងស្នើសុំបន្ថែមកិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់ នៅជុំវិញស្ថានទូតថៃ និងស្ថានកុងស៊ុលនៅ ខេត្តសៀមរាប ខណៈពេលដែលប្រទេសថៃនឹងរៀបចំការបោះឆ្នោតនៅថ្ងៃទី២៨-២៩ ខែមេសា ឆ្នាំ២០២៣ ខាង មុខនេះ។ក្នុងជំនួបនេះ ឯកឧត្តម ឈើតគៀត អាត់ថាក័រ (Cherdkiat ATTHAKOR) ឯកអគ្គរាជទូតថៃប្រចាំកម្ពុជា បានស្នើសុំកិច្ចសហប្រតិបត្តការ និងការជួយជ្រោមជ្រែងពីអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា ក្នុងអំឡុងពេល

ដែល ប្រទេសថៃរៀបចំព្រឹត្តិការណ៍បោះឆ្នោតថ្នាក់ជាតិ ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៨-២៩ ខែមេសា ឆ្នាំ២០២៣ ខាងមុខនេះ។

ដើម្បីឲ្យដំណើរការបោះឆ្នោតក្រៅប្រទេស ប្រព្រឹត្តទៅប្រកបដោយសុខសុវត្ថិភាព ឯកឧត្តមឯកអគ្គរាជទូតថៃ បានស្នើសុំឲ្យជួយគាំទ្រការពារទាំងផ្នែកសន្តិសុខ និងសណ្ដាប់ធ្នាប់នៅបរិវេណ និងទីតាំងដែលមានរៀបចំការបោះឆ្នោតនៅរាជធានីភ្នំពេញ និងខេត្តសៀមរាប។ ក្នុងជំនួបនេះ ភាគីថៃបានចែករំលែកនូវបទពិសោធន៍ពាក់ព័ន្ធកិច្ចការពារព្រឹត្តិការណ៍កីឡាស៊ីហ្គេម ដែលថៃធ្លាប់ទទួលធ្វើជាម្ចាស់ផ្ទះរៀបចំកន្លងមក។ ក្រៅពីនោះ ឯកឧត្តម ឈើត គៀត អាត់ថាក័រ (Cherdkiat ATTHAKOR) ក៏បានលើកឡើងពីកិច្ចការនគរបាល និងកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងបទល្មើសឆ្លងដែនគ្រប់ប្រភេទ ជាពិសេសបទល្មើសដែលកំពុងមាននិន្នាការកើនឡើងជាសកលគឺល្បែងអនឡាញខុសច្បាប់ជាដើម។

ជាការឆ្លើយតប ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានថ្លែងអំណរគុណចំពោះ ឯកឧត្តមឯកអគ្គរាជទូតថៃប្រចាំកម្ពុជា និងទទួលយកនូវរាល់បទពិសោធន៍ និងការប្រឹក្សាយោបល់ពាក់ព័ន្ធដំណើរការនៃកិច្ចការពារសន្តិសុខ សណ្ដាប់ធ្នាប់ និងសុវត្ថិភាព នៅក្នុងអំឡុងពេលនៃការប្រកួតកីឡាស៊ីហ្គេម រីឯពាក់ព័ន្ធនិងការស្នើសុំកិច្ចការពារសន្តិសុខ សណ្ដាប់ធ្នាប់ និងសុវត្ថិភាព ក្នុងអំឡុងពេលបោះឆ្នោតថ្នាក់ជាតិរបស់ប្រទេសថៃ នៅរាជធានីភ្នំពេញ និងខេត្តសៀមរាប ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន ក៏បានសម្ដែងការស្វាគមន៍ និងបានរៀបចំចាត់ចែងកម្លាំងនាយកដ្ឋានជំនាញសហការជាមួយនិងកម្លាំងនគរបាលមូលដ្ឋាន ដើម្បីផ្តល់ជូននៅកិច្ចការពារតាមការស្នើសុំឲ្យបានល្អប្រសើរ។

ពាក់ព័ន្ធនិងការប្រយុទ្ធប្រឆាំងល្បែងហ្គេមអនឡាញ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន បានគូសបញ្ជាក់ថា ដោយអនុវត្តតាមយុទ្ធនាការរបស់រាជរដ្ឋាភិបាលនៅប្រទេសកម្ពុជា បានធ្វើការបង្ក្រាបបានស្ទើរតែទាំងស្រុងនៅទីតាំងហ្គេមអនឡាញធំៗគ្រប់ប្រភេទ លើកលែងតែមានករណីមួយចំនួនតូចដែលបានលួចលាក់ជ្រកក្រោមអាជ្ញាប័ណ្ណកាស៊ីណូ ក៏ប៉ុន្តែកិច្ចការនេះនគរបាលជាតិកម្ពុជានៅតែបន្តបង្ក្រាបដូចភ្លៀងរលឹម។

ក្នុងឱកាសនោះដែរ ឯកឧត្តមឯកអគ្គរាជទូតថៃ បានសម្ដែងនូវមនោសញ្ចេតនា និងការដាក់ជំនឿចិត្តខ្ពស់អរគុណចំពោះអគ្គស្នងការដ្ឋាននគរបាលជាតិ និងបានថ្លែងការកោតសរសើរ ចំពោះការដាក់ចេញនូវបទបញ្ជាបង្ក្រាបបទល្មើសឆ្លងដែន និងការចង្អុលដឹកនាំអនុវត្តកិច្ចប្រតិបត្តិការ ដោយផ្ទាល់ក្នុងការប្រយុទ្ធប្រឆាំងល្បែងអនឡាញខុសច្បាប់ ដែលទទួលបាលលទ្ធផលល្អ គួរឲ្យកត់សម្គាល់ ធ្វើឲ្យបទល្មើសគ្រប់ប្រភេទមានការថយចុះ៕ រក្សាសិទ្ធដោយ ៖ សុទ្ធលី

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្ដឹង ២ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ១០នាក់

https://freshnewsasia.com/index.php/en/localnews/288666-2023-04-27-11-29-07.html 2023-04-27 06:29pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី២៤ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០២ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ចំនួន ១០នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៨៥៩ករណី មានមនុស្ស ២,១៤៨នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៨១៨សំណើ និងបិទសំណុំរឿង ២៧៧សំណើ (រកឃើញមនុស្ស ១,២៣៦នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣១នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៤១ករណី៕

## កិច្ចប្រជុំតាមដានការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប

https://www.facebook.com/100064753144540/posts/pfbid0mpZUf2AQKWv7yWj2dxkLJTePTxAzCKchc8UscRo3XwZEMbebrycmnsby2nY2VLtcl/?sfnsn=mo&mibextid=6aamW6 27/04/2023

ខេត្តសៀមរាប៖ ថ្ងៃព្រហស្បតិ៍ ៨កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព ស ២៥៦៦ ត្រូវនឹងថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប (គ ខ ប ជ) បានរៀបចំកិច្ចប្រជុំប្រចាំខែមេសា ក្រោមអធិបតីភាព លោកស្រី យូ សុភា អភិបាលរងខេត្ត ជាប្រធានលេខាធិការដ្ឋាន គ ខ ប ជ តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត និងប្រធានគណៈកម្មាធិការ គ ខ ប ជ ព្រមទាំងមានការអញ្ជើញចូលរួមពីតំណាងមន្ទីរ អង្គភាព រដ្ឋបាលក្រុង ស្រុក និងអង្គការដៃគូជាតិ អន្តរជាតិ សរុប ៦១នាក់ ស្រី ៣៥ នាក់ អញ្ជើញចូលរួមផងដែរ។ កិច្ចប្រជុំបានពិនិត្យនិងពិភាក្សាតាមរបៀបវារៈរួមមាន៖

១. ពិនិត្យលើសេចក្តីរបាយការណ៍លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំខែមេសា ឆ្នាំ ២០២៣

២. ពិនិត្យនិងពិភាក្សាលើបញ្ហាប្រឈម ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយបានផ្តោតសំខាន់ទៅលើ៖

- ការគាំទ្របន្តដល់កុមារដែលទប់ស្កាត់ពីការប្រើប្រាស់កម្លាំងពលកម្ម នៅក្នុងសិប្បកម្មផលិតឥដ្ឋ ចំនួន៩០នាក់ ដែលមន្ទីរការងារបានធ្វើការគាំទ្រកាលពីឆ្នាំ២០២២ និងស្នើឱ្យមានការចូលរួមគាំទ្របន្តនៅក្នុងឆ្នាំ២០២៣ ទៅលើសម្ភារសិក្សា សម្លៀកបំពាក់ និងការរៀនបំប៉ែនបន្ថែម។

- ការពិភាក្សាទៅលើករណីគ្រួសារទារកអាយុ៤ខែ ដែលម្តាយពុំមានលទ្ធភាពចិញ្ចឹម និងមានបំណងប្រគល់ទៅឱ្យគ្រួសារផ្សេងដើម្បីចិញ្ចឹមជំនួស (ម្តាយពុំមានទឹកដោះនិងពុំមានលទ្ធភាពទិញទឹកដោះគោ)។ ករណីនេះ អង្គប្រជុំបានស្នើឱ្យមន្ទីរសង្គមកិច្ច រដ្ឋបាលក្រុង សង្កាត់ស្លក្រាម និងអង្គការកល្យាណមិត្ត ធ្វើការពិនិត្យបន្ថែម និងប៉ាន់ប្រមាណអំពីភាពខ្វះខាត និងលទ្ធភាពក្នុងការផ្តល់ការគាំទ្រឱ្យបានសមស្រប និងចៀសវាងការផ្តល់ឱ្យទៅគ្រួសារចិញ្ចឹមផ្សេងទៀត ដោយពុំការស្នុំកូនតាមនីតិវិធី ដែលជាហេតុធ្វើឱ្យមានបញ្ហាទៅថ្ងៃក្រោយទៀត ពិសេសកុមារ។

- បានជំរុញដល់មន្ទីរសង្គមកិច្ច មន្ទីរកិច្ចការនារីខេត្ត ស្នងការដ្ឋាននគរបាលខេត្ត និងអង្គការដៃគូពាក់ព័ន្ធ ត្រូវពិនិត្យឡើងវិញ និងសហការគ្នាក្នុងការប្រមូលពត៌មាន និងផ្តល់ប្រឹក្សាយោបល់ទៅដល់កុមារីដែលសង្ស័យរងគ្រោះដោយការរំលោភបំពានតាមប្រព័ន្ធអនឡាញ និងដាក់ពាក្យបណ្តឹងមកសមត្ថកិច្ច ដើម្បីអនុវត្តតាមនីតិវិធី។

- បានជំរុញដល់អាជ្ញាធរក្រុង ស្រុក និងអ្នកពាក់ព័ន្ធ ត្រូវពិនិត្យ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ អំពីកលល្បិចរបស់ជនខិលខូចដែលបានចុះជ្រើសរើសប្រជាពលរដ្ឋដើម្បីរៀនភាសាជប៉ុន សម្រាប់នាំចេញទៅធ្វើការនៅប្រទេសជនដោយខុសច្បាប់។

- បានជំរុញដល់រដ្ឋបាលស្រុកស្រីស្នំ និងអង្គការហាការ ដើម្បីសហការរួមគ្នាក្នុងអនុវត្តគម្រោងស្តារជីវៈភាព ជូនដល់ពលករដែលរងគ្រោះ និងងាយគ្រោះដោយអំពើជួញដូរមនុស្ស ដោយត្រូវធ្វើការផ្សព្វផ្សាយនិងចុះជួបផ្ទាល់ ជាមួយបងប្អូនពលករដែលបានវិលត្រឡប់មកពីក្រៅប្រទេសវិញ និងធ្វើការប៉ាន់ប្រមាណឱ្យបានសមស្រប។

- បានជំរុញឱ្យមានការរួមពីដៃគូពាក់ព័ន្ធ ក្នុងការរួមបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់មន្ត្រីនគរបាល អាជ្ញាធរមូលដ្ឋាន លើការពៗអនុវត្តច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ស្តីពី យុត្តិធម៌អនីតិជន កិច្ចការពារកុមារ ការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការផ្តល់សេវាសមស្រប។

បន្ថែមពីនោះ លោកស្រីប្រធានអង្គប្រជុំបានជំរុញឱ្យគ្រប់ស្ថាប័ន និងអង្គការដៃគូទាំងអស់បន្តយកចិត្ត ទុកដាក់បន្ថែមទៅការផ្សព្វផ្សាយទាំងគ្រប់រូបភាព អំពីហានិភ័យនៃការធ្វើចំណាកស្រុកខុសច្បាប់ នីតិវិធីនៃការធ្វើ ការចំណាកស្រុកដោយសុវត្ថិភាព គុណវិបត្តិនៃការធ្វើចំណាកស្រុក និងត្រូវផ្សព្វផ្សាយអំពីឱកាសការងារក្នុងស្រុក និងការទទួលការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដើម្បីធ្វើការទប់ស្កាត់ការធ្វើចំណាកស្រុកស្វែងរកការងារនៅក្រៅ ប្រទេស។

## សេចក្តីប្រកាសព័ត៌មាន! ក្រុមប្រតិបត្តិការស៊ើបអង្កេត ស្រាវជ្រាវ បណ្តាញនាំមនុស្សឆ្លង ដែនខុសច្បាប់ ដែលបានស្នើសុំអន្តរាគមន៍ តាមរយៈទំព័រហ្វេសបុកសម្តេចក្រឡាហោម (ករណីលេខ ៨០៣)

http://nokorwatnews.com/archives/994584 27/04/2023

ភ្នំពេញ៖ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣នេះ បានចេញសេចក្តីប្រកាសព័ត៌មាន ក្រុមប្រតិបត្តិការស៊ើបអង្កេត ស្រាវជ្រាវបណ្តាញនាំមនុស្សឆ្លងដែនខុសច្បាប់ នៃ អគ្គស្នងការ នគរបាលជាតិ សូមជម្រាបជូនដល់សាធារណជនអំពីលទ្ធផលប្រតិបត្តិការស្វែងរកជនបរទេស ដែល បាន ស្នើសុំអន្តរាគមន៍ តាមរយៈ ទំព័រហ្វេសប៊ុកសម្តេចក្រឡាហោម (ករណីលេខ ៨០៣)។

នៅក្នុងសេចក្តីប្រកាសព័ត៌មានខាងលើនេះ បានបញ្ជាក់ថា នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ ក្រុមប្រតិបត្តិ ការទទួលបានសំណើសុំអន្តរាគមន៍ពីឪពុករបស់ ឈ្មោះ ZHANG TAO ភេទប្រុស ជនជាតិចិន កើតថ្ងៃទី១៥ ខែ តុលា ឆ្នាំ១៩៩៣ លិខិតឆ្លងដែនលេខ EC4295159 ដោយផ្តល់ព័ត៌មានថា កូនរបស់ខ្លួនត្រូវបានគេបង្ខាំងក្នុងទី តាំងមួយកន្លែង ក្នុងភូមិសាស្ត ខេត្តកណ្តាល។ ក្រោយទទួលបានសំណើនៅថ្ងៃដដែល កម្លាំងស្នងការដ្ឋាន នគរបាលខេត្តកណ្តាល បានចុះ ធ្វើការស្រាវជ្រាវដល់ទីតាំងរកឃើញបុរសជនជាតិចិនរូបនេះ កំពុងបម្រើការងារ ក្នុងក្រុមហ៊ុនមួយ ស្ថិត ក្នុងភូមិជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល និងបានអញ្ជើញទៅស្នងការដ្ឋាន ដើម្បីធ្វើការសាកសួរ។

បន្ទាប់ពីស្តាប់ការបំភ្លឺរបស់សាមីខ្លួន បានឱ្យដឹងថា រូបគេបានចូលមកប្រទេសកម្ពុជា កាលពីថ្ងៃទី០១ ខែមី នា ឆ្នាំ២០២៣ តាមច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ក្នុងគោលបំណងស្វែងរកការងារ និងបានចូលធ្វើ ការ ក្នុងក្រុមហ៊ុនខាងលើ ជាអ្នកទំនាក់ទំនងអតិថិជន ដោយរូបគេពុំធ្លាប់បានផ្តល់ព័ត៌មានដល់ក្រុមគ្រួសារ នោះទេ រហូតដល់ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២៣ ក្រុមគ្រួសារបានទាក់ទងមក ហើយរូបគេបានប្រាប់អំពីស្ថាន ភាពនៃការរស់ នៅ និងធ្វើការនៅក្នុងប្រទេសកម្ពុជាដល់ក្រុមគ្រួសារនៅឯប្រទេសចិន។

លុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣ ឪពុករបស់គេបានទាក់ទងមកប្រាប់ថា គាត់បានដាក់ពាក្យប្តឹងស្នើសុំ អន្តរាគមន៍ទៅទំព័រហ្វេសប៊ុក សម្តេចក្រឡាហោម ដោយប្រាប់ថាកូនរបស់ខ្លួនត្រូវបានគេបង្ខាំងក្នុងទីតាំង។ ផ្អែក តាមការបំភ្លឺ និងពិនិត្យ លើស្ថានភាពជាក់ស្តែង ក្រុមប្រតិបត្តិការពិនិត្យឃើញថា ករណីនេះពុំមែនជាករណីបង្ខាំង

ដូចទៅនឹង សំណើសុំអន្តរាគមន៍នោះទេ ប៉ុន្តែដោយសេចក្តីបារម្ភពីក្រុមគ្រួសារ ទើបស្នើសុំការអន្តរាគមន៍ដើម្បីឲ្យឈ្មោះ ZHANG TAO បានវិលត្រឡប់ទៅប្រទេសចិនវិញ ដោយសាមីខ្លួនពុំបានដឹង។

បច្ចុប្បន្នសមត្ថកិច្ចបានបញ្ជូនឈ្មោះ ZHANG TAO ទៅមណ្ឌលត្រៀមបណ្តេញចេញរបស់អគ្គ នាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីបន្តនីតិវិធី។ អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនជាតិ និងអន្តរជាតិជ្រាបជាព័ត៌មាន៕

# តៃវ៉ាន់ធ្វើវិសោធនកម្មច្បាប់ស្តីពីការជួញដូរមនុស្សបន្ទាប់ពីមានករណីបែបនេះនៅកម្ពុជា

https://www.khmertimeskh.com/501281119// Khmer Times April 28, 2023

គណៈកម្មាធិការនីតិប្បញ្ញត្តិរបស់កោះតៃវ៉ាន់ បានអនុម័តលើវិសោធនកម្មលើកទីមួយ ដែលនឹងបង្កើនការពិន័យចំពោះជនល្មើសដែលប៉ុនប៉ងជ្រើសរើសមនុស្សឱ្យប្រព្រឹត្តបទឧក្រិដ្ឋនៅបរទេស បន្ទាប់ពីមានការចុះផ្សាយព័ត៌មានជាច្រើនកាលពីឆ្នាំមុនពាក់ព័ន្ធនឹងបទល្មើសល្បួងអ្នកស្វែងរកការងារធ្វើមកប្រទេសកម្ពុជា។ សំណើរធ្វើវិសោធនកម្មច្បាប់ស្តីពីការទប់ស្កាត់ឧក្រិដ្ឋកម្មដែលបានរៀបចំទុកជាមុនដែលព្រាងដោយនាយកប្រតិបត្តិ Yuan កំណត់ការផាកពិន័យរហូតដល់៦៥១,២៥៤ ដុល្លារ និងជាប់ពន្ធនាគាររហូតដល់ ៧ ឆ្នាំ ខណៈដែលនឹងដាក់ពិន័យកាន់តែខ្លាំងនៅពេលដែលជនរងគ្រោះមិនទាន់គ្រប់អាយុ។ វិសោធនកម្មនេះត្រូវបានព្រាងបន្ទាប់ពីអ្នកស៊ើបអង្កេតបានរកឃើញថា ក្រុមជួញដូរបានល្បួងជនជាតិតៃវ៉ាន់មកកម្ពុជាដោយសន្យាថាពួកគេទទួលបានការងារដែលមានប្រាក់ខែខ្ពស់ ប៉ុន្តែជាក់ស្តែងបានបង្ខំពួកគេឱ្យធ្វើការងារបោកប្រាស់ និងទទួលរងការកេងប្រវ័ញ្ចផ្លូវភេទ។ ករណីនៃការជួញដូរសរីរាង្គក៏ត្រូវបានរាយការណ៍ផងដែរ។

សមាជិកក្រុម Four Seas Gang និងក្រុម Bamboo Union Gang ដែលគេសង្ស័យថាមានជាប់ពាក់ព័ន្ធនឹងការជួញដូរមនុស្សមកកម្ពុជា ត្រូវបានមន្ត្រីការិយាល័យស៊ើបអង្កេតឧក្រិដ្ឋកម្មតាមចាប់ខ្លួនកាលពីថ្ងៃទី៣ ខែមីនា។ វិសោធនកម្មនេះក៏នឹងហាមឃាត់អ្នកដែលត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋកម្មដែលបានរៀបចំទុកជាមុនពីការឈរឈ្មោះធ្វើជាមន្ត្រីរាជការផងដែរ។

Ker Chien-ming មកពីគណបក្សប្រជាធិបតេយ្យបាននិយាយថា អ្នកដែលត្រូវបានជាប់ទោស ប៉ុន្តែមិនត្រូវបានគេដាក់ទោសទណ្ឌ ក៏នឹងត្រូវបានហាមឃាត់មិនឱ្យឈរឈ្មោះក្នុងការបោះឆ្នោតដែរ។ វិសោធនកម្មនេះចែងអំពីការដាក់ទោសទណ្ឌកម្រិតធ្ងន់សម្រាប់មន្ត្រីសាធារណៈ ដែលត្រូវបានរកឃើញថាមានពិរុទ្ធពីបទជាប់ពាក់ព័ន្ធក្នុងឧក្រិដ្ឋកម្មដែលបានរៀបចំទុកជាមុនរួមទាំងការផ្តល់ហិរញ្ញប្បទាននិងការជ្រើសរើសមនុស្សសម្រាប់ក្រុមឧក្រិដ្ឋកម្ម។ នៅក្រោមវិសោធនកម្មនេះ មន្ត្រីសាធារណៈដែលរកឃើញថាមានពិរុទ្ធពាក់ព័ន្ធនឹងបទល្មើសបែបនេះ អាចនឹងត្រូវរឹបអូសយកទ្រព្យសម្បត្តិ និងប្រាក់ខុសច្បាប់។ វិសោធនកម្មច្បាប់ត្រួតពិនិត្យការលាងលុយក៏ត្រូវបានពិភាក្សាកាលពីម្សិលមិញដែរ ប៉ុន្តែខ្វះការគាំទ្រ។ ការពិភាក្សាលើសំណើនេះគឺនៅតែបន្តទៅមុខទៀត។

សំណើមួយបានកំណត់ពីការជាប់ពន្ធនាគាររហូតដល់៥ឆ្នាំនិងពិន័យជាប្រាក់រហូតដល់៤លានដុល្លារតៃវ៉ាន់សម្រាប់មន្ត្រីរាជការសាធារណៈណាដែលប្រើប្រាស់ការិយាល័យរបស់ពួកគេប្រមូលព័ត៌មានអំពីគណនីរបស់មនុស្សជាមួយនឹងស្ថាប័នហិរញ្ញវត្ថុ រូបិយប័ណ្ណគ្រីបតូ ឬវេទិកាទូទាត់ភាគីទី៣។ សមាជិកសភាគណបក្សជាតិនិយមចិន លោក William Tseng បានជំទាស់នឹងសំណើនេះ ដោយនិយាយថា ការផាកពិន័យគួរតែមានរហូតដល់១០០លានដុល្លារតៃវ៉ាន់។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ Tsai Ching-hsiang បានស្នើឱ្យបង្កើនការផាកពិន័យជាអតិបរមាដល់ ៥០ លានដុល្លារតៃវ៉ាន់ ប៉ុន្តែដកឃ្លាដែលចែងពីការផាកពិន័យដាច់ដោយឡែកពីគ្នា "ប្រសិនបើមនុស្ស៣ នាក់ ឬច្រើនជាងនេះ បានប្រព្រឹត្តបទឧក្រិដ្ឋរួមគ្នា"៕